តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia



# ការយល់ឃើញអំពីអំពើពុករលួយ ក្នុងសហគ្រាសធុនតូចនិងមធ្យម នៅប្រទេសកម្ពុជា

អង្គការតម្លាភាពកម្ពុជា
ផ្ទះលេខ ៩បេ ផ្លូវលេខ ៤៦៦ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ១២៣០១ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ (+៨៥៥) ២៣ ២១ ៤៤ ៣០ / ២៣ ២១ ៤២ ១១

info@ticambodia.org
www.ticambodia.org
www.facebook.com/ticambodia
www.twitter.com/ticambodia
www.youtube/ticambodia.com

រូបថតក្របមុខ ៖ © Conor Wall

ខ្លឹមសារទាំងឡាយនៅក្នុងការបោះពុម្ពផ្សាយនេះ ឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អង្គការតម្លាភាពកម្ពុជាប៉ុណ្ណោះ។ ការខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើង ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មាន ដែលមាននៅក្នុងរបាយការណ៍នេះ។ ព័ត៌មានទាំងអស់ ត្រូវបានជឿជាក់ថាមានភាពត្រឹមត្រូវ គិតត្រឹមខែ ឧសភា ឆ្នាំ ២០១៥។ ទោះជាយ៉ាងណាក៏ដោយ អង្គការតម្លាភាពកម្ពុជា មិនទទួលខុសត្រូវចំពោះផលវិបាកផ្សេងៗដែលបណ្តាលមកពីការប្រើប្រាស់របាយការណ៍នេះក្នុងគោលបំណងផ្សេង ឬក្នុងបរិបទផ្សេងឡើយ។

© ២០១៥ អង្គការតម្លាភាពកម្ពុជា។ រក្សាសិទ្ធិគ្រប់យ៉ាង។

# ការយល់ឃើញអំពីអំពើពុករលួយ
# ក្នុងសហគ្រាសធុនតូចនិងមធ្យម
# នៅប្រទេសកម្ពុជា

ថ្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

អង្គការតម្លាភាពអន្តរជាតិ គឺជាចលនាទូទាំងពិភពលោកមួយ ដែលមានចក្ខុវិស័យរួមមួយ ពោលគឺពិភពលោកមួយ ដែលរដ្ឋាភិបាល ពាណិជ្ជកម្ម សង្គមស៊ីវិល និងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ពុំមាននូវអំពើពុករលួយ។ តាមរយៈអង្គការសាខាជាង១០០នៅទូទាំងពិភពលោក និង លេខាធិការដ្ឋានអន្តរជាតិមួយនៅទីក្រុងប៊ែរឡាំង អង្គការតម្លាភាពអន្តរជាតិ កំពុងធ្វើការឥតឈប់ឈរដើម្បីប្រែក្លាយនូវចក្ខុវិស័យនេះឲ្យក្លាយទៅជាការពិត។

អង្គការតម្លាភាពកម្ពុជា គឺជាអង្គការសាខាប្រចាំព្រះរាជាណាចក្រកម្ពុជារបស់អង្គការតម្លាភាពអន្តរជាតិ។ ដោយត្រូវបានផ្តើតឡើងជាផ្លូវការ នៅឆ្នាំ ២០១០ អង្គការយើងបានធ្វើការជាមួយស្ថាប័ន និងបុគ្គលនានា នៅគ្រប់កម្រិតទាំងអស់ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងលើកកម្ពស់ភាពសុចរិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

---


គម្រោង ដែលដឹកនាំដោយក្រុមស្រាវជ្រាវរបស់អង្គការគោលដៅយុត្តិធម៌
ប្រធានទីប្រឹក្សា និង អ្នកនិពន្ធនាំមុខ ៖ ពុធ ថារិនដា
អ្នកស្រាវជ្រាវ និង អ្នកនិពន្ធ ៖ លឹម រដ្ឋា
ជំនួយការស្រាវជ្រាវ ៖ មុំ សុផាន្នី
ឈីន ឆៃយ៉ា


---

របាយការណ៍ស្តីពីការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជានេះ ត្រូវបានសរសេរឡើងជាភាសាអង់គ្លេស។
របាយការណ៍ជាភាសាខ្មែរនេះ គឺជាការបកប្រែមិនផ្លូវការពីរបាយការណ៍ដើម។

# បុព្វកថា

"អារសាច់ជូនខ្លា ទើបនៅស្រុកបាន"។ ដោយលើកពីភាសិតបុរាណខ្មែរនេះឡើង អ្នកទទួលបទសម្ភាសន៍ម្នាក់ ដែលបានទទួលយកនូវការអង្កេតសម្រាប់ផ្នែកមួយនៃការសិក្សានេះ បានបង្ហាញតម្រុយអំពីតថភាពដ៏ព្រួយបារម្ភនៃការអនុវត្តនានាក្នុងវិស័យធុរកិច្ចរបស់ប្រទេសកម្ពុជា។ ដើម្បីឲ្យជំនួញរស់រានមានជីវិតបាន សហគ្រាសធុនតូច និងមធ្យមនានា មិនអាចជៀសវាងពីការឲ្យប្រាក់ទឹកតែទៅដល់អាជ្ញាធរបានទេ ដោយសហគ្រាសទាំងនោះ យល់ឃើញថា អាជ្ញាធរគឺជាអ្នកប្រមាញ់ដែលមានអំណាចឋានៈខ្ពស់នៅក្នុងខ្សែចង្វាក់ផលិតអាហារមនោគត ជាជាងជាអ្នកការពារ។

អំពើពុករលួយធ្វើឲ្យមានការប៉ះពាល់ដល់ជំនួញ ហើយខ្លាំងជាពិសេសសំរាប់សហគ្រាសធុនតូច និងមធ្យមដែលធនធានមានកម្រិត ជាហេតុធ្វើឲ្យពួកគេទទួលរងគ្រោះខ្លាំងពីការសូកប៉ាន់ និងការបង់ប្រាក់ក្រៅផ្លូវការ។

សហគ្រាសធុនតូច និងមធ្យម បានប្រតិបត្តិការជាលក្ខណៈស្រមោលជាយូរណាស់មកហើយ ដែលប្រតិបត្តិការនោះមានលក្ខណៈតាមទម្រង់ការពាក់កណ្តាល និងមិនតាមទម្រង់ការពាក់កណ្តាល។ ការណ៍នេះ បានបើកទ្វារអោយមានអំពើពុករលួយគ្រប់ប្រភេទ។ បញ្ហានេះជាឧបសគ្គ ដែលធ្វើឲ្យរាំងស្ទះដល់ការលូតលាស់របស់ជំនួញពួកគេ ក៏ដូចជាការទទួលបាននូវដើមទុន និងការឈានដល់ទីផ្សារថ្មីៗ ហើយភាគច្រើនបានធ្វើឲ្យពួកគេគ្មានលទ្ធភាពប្រកួតប្រជែងជាមួយទីផ្សារក្នុងតំបន់។ ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងដើម្បីស្វែងយល់ថា តើសហគ្រាសធុនតូចនិងមធ្យម ដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចនោះយល់ឃើញអំពីអំពើពុករលួយ និង ផលប៉ះពាល់របស់វាយ៉ាងដូចម្តេចដែរ។

ការរកឃើញដ៏សំខាន់មួយពីការសិក្សានេះគឺ សហគ្រាសធុនតូច និងមធ្យម មានការយល់ដឹងនៅមានកម្រិតនៅឡើយ អំពីក្របខណ្ឌគតិយុត្តិដែលពួកគេត្រូវធ្វើប្រតិបត្តិការតាម ហើយសហគ្រាសភាគតិចណាស់ដែលដឹងអំពីតម្លៃសេវាផ្លូវការ ដែលពួកគេត្រូវបង់សម្រាប់សេវាសាធារណៈ។ ជាលទ្ធផល សហគ្រាសជាច្រើន មានការលំបាកក្នុងការកំណត់អំពីការចំណាយ ដែលអំពើពុករលួយអាចធ្វើអោយពួកគេខាតបង់។ យ៉ាងណាមិញ ដើម្បីដំណើរការអាជីវកម្មស្អាតស្អំមួយ សហគ្រាសត្រូវយល់ដឹងអំពីសិទ្ធិរបស់ខ្លួនឲ្យបានច្បាស់ ក៏ដូចជាកាតព្វកិច្ចរបស់ខ្លួនដែរ។ ដើម្បីដោះស្រាយនូវការខ្វះខាតផ្នែកចំណេះដឹងនេះ វាមានសារៈសំខាន់ណាស់ ដែលព័ត៌មានស្តីអំពីក្របខណ្ឌគតិយុត្តិ តម្រូវការអធិការកិច្ច និងតម្លៃសេវាផ្លូវការត្រូវដាក់ ប្រកាសជាសាធារណៈ។

សហគ្រាសធុនតូច និងមធ្យមភាគច្រើន ដែលបានទទួលយកការអង្កេត មិនមានចំណេះដឹង ឬមានចំណេះដឹងនៅមានកម្រិតនៅឡើយ អំពីសញ្ញាណនៃសុចរិតភាពធុរកិច្ច។ សហគ្រាសទាំងនេះ មិនដឹងថាតើត្រូវបញ្ចូលនូវសញ្ញាណនេះទៅក្នុងការអនុវត្តយ៉ាងដូចម្តេចនោះទេ។ ដើម្បីដោះស្រាយពីបញ្ហានេះ អង្គការតម្លាភាពកម្ពុជា បានប្តេជ្ញាយ៉ាងមុតមាំ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ក្នុងការជួយជម្រុញសហគ្រាសធុនតូច និងមធ្យមនានា ហើយជួយពួកគេក្នុងការបង្កើតនូវគោលការណ៍ និងនីតិវិធីប្រតិបត្តិការ ដែលនឹងជួយពួកគេកាត់បន្ថយនូវការរងគ្រោះថ្នាក់អំពីអំពើពុករលួយ។

ជំហាននៃការជួយជម្រុញជាច្រើន ត្រូវបានដាក់ចេញដោយភ្នាក់ងារសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងពាណិជ្ជកម្ម និងក្រសួងទេសចរណ៍ សម្រាប់ផ្តល់នូវការទទួលបានព័ត៌មានជាងមុន ក៏ដូចជាការបង្កើតនូវនីតិវិធីអនឡាញដើម្បីកម្រិតនូវកាលានុវត្តភាពនៃការកើតឡើងនូវអំពើពុករលួយ។

ជារួម បរិស្ថានធុរកិច្ចក្នុងប្រទេសកម្ពុជា កំពុងតែប្រសើរឡើង ហើយរាជរដ្ឋាភិបាល ក៏អនុវត្តយ៉ាងសកម្មនូវក្របខណ្ឌគតិយុត្តិ ដែលជំរុញឲ្យមានតម្រូវការក្នុងការគោរពច្បាប់។ ដោយហេតុថា ការគោរពច្បាប់យ៉ាងម៉ឺងម៉ាត់បង្កើននូវការទទួលបានហិរញ្ញប្បទាន ក៏ដូចជាកម្រិតនូវហានិភ័យនៃអំពើពុករលួយ អង្គការយើង ជម្រុញយ៉ាងខ្លាំងក្លាដល់សហគ្រាសធុនតូចនិងមធ្យម អោយអនុលោមតាមច្បាប់ និងជំរុញឲ្យរាជរដ្ឋាភិបាលបង្កើតនូវក្របខណ្ឌគោលនយោបាយ ដែលអាចអោយសហគ្រាសទាំងនោះអាចអនុលោមតាមច្បាប់។ អនុសាសន៍លម្អិតផ្សេងៗ ត្រូវបានលើកឡើងជាគោលៗក្នុងរបាយការណ៍នេះ។

ខ្ញុំសង្ឃឹមថា ភាគីពាក់ព័ន្ធ ពីសំណាក់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងធុរកិច្ច ទាំងអស់ នឹងយល់ឃើញថារបាយការណ៍នេះមានតម្លៃ ហើយវានឹងបង្កើតនូវកិច្ចជជែកពិភាក្សាដែលមានផ្លែផ្កា ដែលនឹងជំរុញឲ្យមានបរិយាកាសក្នុងការធ្វើជំនួញក្នុងប្រទេសកម្ពុជាមានភាពងាយស្រួល និង ល្អជាងមុនបន្ថែមទៀត។



ព្រាប កុល
នាយកប្រតិបត្តិ
អង្គការតម្លាភាពកម្ពុជា

# សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវនេះ នឹងមិនអាចត្រូវបានបញ្ចប់ឡើយ ប្រសិនបើពុំមានកិច្ចសហការដ៏ល្អពីសំណាក់ នាយកប្រតិបត្តិទាំងអស់របស់សហគ្រាសធុនតូច និងមធ្យម រាល់រូបវន្តបុគ្គល និងរាល់ស្ថាប័ននានា ដែលបានយល់ព្រមទទួលយកកិច្ចសម្ភាស។

យើងសូមថ្លែងអំណរគុណ ដល់ក្រុមប្រឹក្សាស្រាជ្រាវរបស់យើង និងអ្នកនិពន្ធដ៏សំខាន់នៃរបាយការណ៍ពីអង្គការគោលដៅយុត្តិធម៌ ជាពិសេស អ្នកនាង ពុធ ថារិនដា និង អ្នកនាង លឹម រដ្ឋា ចំពោះការងារដ៏លំបាក និង ការលះបង់របស់ពួកគេ។

យើងសូមថ្លែងអំណរគុណផងដែរ ចំពោះក្រុមប្រឹក្សាភិបាលប្រឹក្សាយោបល់នៃការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូច និងមធ្យម ដែលជាក្រុមអ្នកជំនាញវិជ្ជាជីវៈផ្សេងៗ ដែលបានផ្តល់នូវការចូលរួម និងការណែនាំដ៏មានតម្លៃ ក្នុងដំណើរការស្រាវជ្រាវនេះ ដោយក្នុងនោះរួមមាន លោក លី វិសាល ប្រធានប្រតិបត្តិនៃសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា លោក ហុក វិចិត្រា មន្ត្រីប្រតិបត្តិការិយាល័យនៃសមាគមសហគ្រិនវ័យក្មេងកម្ពុជា លោកស្រី ហ្គូសធ្យឺរ គ្រីស្ទីន ក្រុមប្រឹក្សាភិបាលនៃសមាគមសហគ្រិនស្ត្រីកម្ពុជា និង លោក សៀង សុទ្ធរា ប្រធានផ្នែកទីផ្សារ និងនាំចេញនៃសមាគមសិប្បករកម្ពុជា។

លើសពីនេះទៀត យើងសូមថ្លែងអំណរគុណដល់ លោក លឹម សុកលី អ្នកជំនាញផ្នែកត្រួតពិនិត្យ និងវាយតម្លៃ របស់អង្គការតម្លាភាពកម្ពុជា ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសលើការវិភាគនីតិវិធី និងទិន្នន័យគំរូ។

អ្នកគ្រប់គ្រងជាន់ខ្ពស់របស់អង្គការតម្លាភាពកម្ពុជា លោក ព្រាប កុល នាយកប្រតិបត្តិ និង លោក ប៉ិច ពិសី នាយកកម្មវិធី បានផ្តល់ការណែនាំ និងការគាំទ្រនៅរាល់ជំហាននៃគម្រោងនេះ ហើយបានចែករំលែកពេលវេលាខ្លះ ពីការរវល់ខ្លាំងរបស់ពួកគាត់ដើម្បីពិនិត្យស្រាវជ្រាវ និងបានផ្តល់នូវនីតិវិធីដែលមានសារៈសំខាន់បំផុត។

យើងក៏សូមធ្វើការថ្លែងអំណរគុណផងដែរដល់ លោក តុប វិសាលឡូ ជំនួយកម្មវិធីរបស់អង្គការតម្លាភាពកម្ពុជា ក្នុងការគាំទ្រដ៏ល្អឥតខ្ចោះ និងសម្រាប់ការដែលតែងតែស្ថិតនៅចំនុចកំពូលចំពោះរាល់កិច្ចការ។

សូមអរគុណដល់ ក្រុមការងារនៃអង្គការតម្លាភាពអន្តរជាតិកម្ពុជា ជាពិសេសគឺ លោក សៀង ម៉េងអួន និង អ្នកស្រី ជា សុគន្ធា ដែលដឹកនាំដោយ លោក ស៊ិន ឡុង ក្នុងការធានាថា អ្វីៗគ្រប់យ៉ាង នឹងដំណើរការបានយ៉ាងរលូន និង អរគុណសម្រាប់រាល់ការផ្តល់នូវការណែនាំផ្នែកបច្ចេកទេស។

ជាចុងក្រោយនេះ យើងមិនអាចធ្វើការស្រាវជ្រាវនេះ ឬ នាំយកមកនូវការរកឃើញនេះអោយលេចចេញជារូបរាងបានឡើង ប្រសិនបើគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីសំណាក់ម្ចាស់ជំនួយរបស់យើង គឺក្រសួងការបរទេស និងពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលី (DFAT) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA)។

ជាថ្មីម្តងទៀត យើងសូមសំដែងនូវការដឹងគុណដោយស្មោះ ដល់បុគ្គលទាំងអស់ដែលបានចូលរួមនៅក្នុងគម្រោងនេះ ដែលបានជួយពួកយើងក្នុងការបំភ្លឺអំពីបញ្ហាប្រឈមនឹងអំពើពុករលួយ របស់សហគ្រាសធុនតូច និងមធ្យម និងរួមចំណែកដល់ការតស៊ូមតិឱ្យមានបរិយាកាសល្អក្នុងវិស័យអាជីវកម្ម។ ការបញ្ចប់នូវភាពស្ងៀមស្ងាត់ ចំពោះអំពើពុករលួយរបស់វិស័យឯកជន គឺជាគន្លឹះសំខាន់ក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

# អារម្ភកថា

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ នៅក្នុងរយៈពេលមួយទសវត្សកន្លះកន្លងទៅនេះ ប្រទេសមានការរីកចំរើនផ្នែកសេដ្ឋកិច្ចដ៏សំខាន់មួយ ដែលមានកំណើនសេដ្ឋកិច្ចជាមធ្យម ៨% ជារៀងរាល់ឆ្នាំ (KPMG ឆ្នាំ ២០១៣ ទំព័រ ៣)។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា ប្រទេសកម្ពុជាមានកំណើនពី ៧,៣% ក្នុងឆ្នាំ ២០១២ ដល់ ៧,៦% ក្នុងឆ្នាំ២០១៣ (គេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។ បើយោងតាមរបាយការណ៍របស់ធនាគារពិភពលោកស្តីពីប្រទេសកម្ពុជា ចុះខែតុលា ឆ្នាំ២០១៤ កំណើនពិតប្រាកដរបស់ប្រទេសកម្ពុជាសម្រាប់ ឆ្នាំ២០១៤ ត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន ៧,២% ហើយអត្រាពិតប្រាកដនៃការកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំនេះ ត្រូវបានគេរំពឹងថានឹងឈានដល់ ៧,៥% (គេហទំព័រធនាគារពិភពលោក)។[១]

ទោះបីជាប្រទេសកម្ពុជា បានជួបប្រទះនូវកំណើនដ៏សន្ធឹកសន្ធាប់នេះក៏ដោយ តែកំណើននេះ ត្រូវបានរាំងស្ទះដោយមានការប្រឈមមួយចំនួន ដែលប្រទេសនេះកំពុងជួបប្រទះ ក្នុងនោះរួមមានការគាំទ្រនៅមានកម្រិតដល់វិស័យធុរកិច្ច និងកង្វះនៃប្រសិទ្ធិភាពពីស្ថាប័នរបស់ខ្លួន។

ជាការពិតណាស់ វិស័យធុរកិច្ច បានប្រឈមនឹងអំពើពុករលួយ ដែលធ្វើឲ្យសហគ្រាសធុនតូច និងមធ្យមមានភាពយឺតយ៉ាវក្នុងការលូតលាស់ និងដំណើរការការងារដោយប្រសិទ្ធិភាព។

របាយការណ៍របស់ធនាគារពិភពលោក ស្តីអំពីភាពងាយស្រួលក្នុងការធ្វើធុរកិច្ច ឆ្នាំ២០១៥ បានធ្វើចំណាត់ថ្នាក់ប្រទេសកម្ពុជា នៅលំដាប់ទី១៣៥ ក្នុងចំណោមប្រទេសចំនួន ១៨៩ ពោលគឺធ្លាក់ចុះមួយចំណាត់ថ្នាក់ពីចំណាត់ថ្នាក់ឆ្នាំមុន (ធនាគារពិភពលោក ឆ្នាំ២០១៥) ។ ដោយផ្អែកលើរបាយការណ៍ដដែលនេះ តាងរាងទី១ ធ្វើការប្រៀបធៀបអំពីភាពងាយស្រួលនៃការចាប់ផ្តើមអាជីវកម្មនៅកម្ពុជាជាមួយនឹងតំបន់អាស៊ីបូព៌ា និងតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយតារាងនេះ បានបង្ហាញឲ្យឃើញថា រយៈពេលក្នុងការបង្កើតអាជីវកម្មមួយនៅប្រទេសកម្ពុជាគឺ មានចំនួនបីដងច្រើនជាងនៅប្រទេសដ៏ទៃទៀតក្នុងតំបន់នេះ។ លើសពីនេះទៅទៀត វាមានតម្លៃដល់ទៅ ១៤០% នៃប្រាក់ចំណូលក្នុងម្នាក់ ចំពោះនីតិវិធី ខណៈដែល

---

[១] សូមមើលផងដែរនូវ "Cambodia: Entering a New Phase of Growth" (ប្រទេសកម្ពុជាចូលក្នុងដំណាក់កាលរីកចម្រើនថ្មី), មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលមាននៅលើគេហទំព័រ http://www.imf.org/external/pubs/cat/longres.aspx?sk=40878.0.

តម្លៃមធ្យមនៅក្នុងតំបន់នេះ គឺមានចំនួនត្រឹមតែ ២៧,៧%ប៉ុណ្ណោះ ។ នៅទូទាំងពិភពលោក ប្រទេសកម្ពុជា ជាប់ចំណាត់ថ្នាក់ទី១៨៤ ក្នុងចំណោមប្រទេសចំនួន ១៨៩ នៅក្នុងភាពងាយស្រួលក្នុងការចាប់ផ្តើមអាជីវកម្ម (ធនាគារពិភពលោក ឆ្នាំ២០១៥)។

**តារាងទី១៖ ការចាប់ផ្តើមអាជីវកម្មនៅក្នុងប្រទេសកម្ពុជាប្រៀបធៀបនឹងប្រទេសដទៃទៀត**
(ធនាគារពិភពលោក ឆ្នាំ២០១៥)

| សូចនាករ | ប្រទេសកម្ពុជា | តំបន់អាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីភិច | សមាជិកអង្គការ OECD* |
|---|---|---|---|
| នីតិវិធី (ចំនួន) | ១១.00 | ៧.៣ | ៤.៨ |
| ពេលវេលា (ថ្ងៃ) | ១០១.0 | ៣៤.៤ | ៩.២ |
| ការចំណាយ (% នៃប្រាក់ចំណូលក្នុងម្នាក់) | ១៣៩.៥ | ២៧.៧ | ៣.៤ |
| ការចំណាយអប្បបរមានៅក្នុងដើមទុន (% នៃប្រាក់ចំណូលក្នុងម្នាក់) | ២៦.១ | ២៥៦.៤ | ៨.៨ |

* អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD)

លើសពីនេះទៅទៀត វិស័យធុរកិច្ច ក៏មានការប្រឈមនឹងការប្រព្រឹត្តអំពើពុករលួយផងដែរ ដែលធ្វើឲ្យសហគ្រាសធុនតូច និងមធ្យមជាច្រើន មានភាពយឺតយ៉ាវក្នុងការលូតលាស់និងដំណើរការងារមានប្រសិទ្ធិភាព បើទោះបីជា សហគ្រាសធុនតូច និងមធ្យម ត្រូវបានគេទទួលស្គាល់ថាជាឆ្អឹងខ្នងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជា (Raynard និង Forstater ឆ្នាំ ២០០២) និង (OECD ២០០៤)។

សន្ទស្សន៍ស្តីពីការយល់ឃើញអំពីអំពើពុករលួយ ឆ្នាំ២០១៤ ដែលរៀបចំដោយអង្គការតម្លាភាពអន្តរជាតិ បានចាត់ចំណាត់ថ្នាក់ប្រទេសកម្ពុជាក្នុងលេខរៀងទី ១៥៦ ក្នុងចំណោមប្រទេសចំនួន ១៧៥ ដោយមានពិន្ទុចំនួន ២១ លើ ១០០ ដោយពិន្ទុនេះ ទទួលបានកើនឡើងមួយពិន្ទុប្រៀបធៀបនឹងឆ្នាំមុន។ ប្រទេសកម្ពុជា មានចំណាត់ថ្នាក់ដូចគ្នាជាមួយនឹងប្រទេសភូមា ដែលជាប្រទេសដែលមានលំដាប់ថ្នាក់ទាបបំផុតនៅក្នុងតំបន់អាស៊ាន។[២] សន្ទស្សន៍នេះ បានវាស់វែងអំពីអំពើពុករលួយនៅក្នុងវិស័យសាធារណៈ

[២] អង្គការតម្លាភាពអន្តរជាតិ, Corruption Perceptions Index 2014 (សន្ទស្សន៍ស្តីពីការយល់ឃើញអំពីអំពើពុករលួយ ២០១៤)– លទ្ធផលអាចរកបាននៅលើគេហទំព័រ ៖ [https://www.transparency.org/cpi2014 [បានចូលធ្វើការស្រាវជ្រាវនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥]។

និងបានបង្ហាញថា វិស័យសាធារណៈរបស់ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃការប្រព្រឹត្តអំពើពុករលួយច្រើនជាងគេបំផុតនៅក្នុងតំបន់អាស៊ាន។ ទោះបីជាមានការរីកចម្រើនដ៏តិចតួចស្តួចស្តើងនេះក្តី ប្រទេសកម្ពុជានៅត្រូវជំនះលើបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធជាមួយនឹងអំពើពុករលួយ។

លើសពីនេះទៅទៀត ដោយផ្អែកលើសន្ទស្សន៍គោលនយោបាយសហគ្រាសធុនតូច និងមធ្យម នៅអាស៊ាន ប្រចាំឆ្នាំ២០១៤ ប្រទេសកម្ពុជា គឺជាប្រទេសសមាជិកអាស៊ានមួយដែលមានការប្រតិបត្តិការ និងការអនុវត្តដ៏អាក្រក់បំផុត។ ប្រទេសកម្ពុជា រួមជាមួយនឹងប្រទេសព្រុយណេ និងប្រទេសឡាវ គឺជាប្រទេសក្នុងតំបន់អាស៊ានដែលទទួលបានពិន្ទុសរុបទាបបំផុតសម្រាប់ក្របខណ្ឌស្ថាប័នជាតិ (វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា(ERIA) ឆ្នាំ២០១៤ ទំព័រ១៧)។

ក្នុងរបាយការណ៍សុចរិតភាពជាសកលប្រចាំឆ្នាំ ២០១២ ប្រទេសកម្ពុជាទទួលបានពិន្ទុសរុបចំនួន ៤២ លើ ១០០ ដែលជាពិន្ទុខ្សោយបំផុត ជាមួយនឹងក្របខណ្ឌគតិយុត្តិទន់ខ្សោយ (៦០ ពិន្ទុ) និងភាពទន់ខ្សោយខ្លាំងក្នុងការដាក់អោយអនុវត្ត (២៣ពិន្ទុ)។[៣] ទាក់ទងទៅនឹងក្របខ័ណ្ឌគតិយុត្តិស្តីពីការប្រឆាំងអំពើពុករលួយ ភាពអនាគតិនៃប្រព័ន្ធតុលាការ និងការអនុវត្តច្បាប់ដោយវិជ្ជាជីវៈ ប្រទេសកម្ពុជា ទទួលបានពិន្ទុសរុបចំនួន ៥៩ ដែលក្នុងនោះ ៣៨ ពិន្ទុសម្រាប់ការអនុវត្តច្បាប់ ៖ ការធានាអំពីទំនាស់ផលប្រយោជន៍ និងភាពមានវិជ្ជាជីវៈ។[៤] ចំណាត់ថ្នាក់នេះ បង្ហាញឲ្យឃើញថា ប្រទេសកម្ពុជា និងសហគ្រាសធុនតូច និងមធ្យមរបស់ខ្លួន នឹងត្រូវប្រឈមជាមួយនឹងបញ្ហាដ៏សំខាន់ នៅពេលដែលប្រទេសកម្ពុជា ចូលរួមជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំនេះ។

ដើម្បីធានាឱ្យបានថា សហគ្រាសធុនតូច និងមធ្យម នៅតែបន្តដើរតួនាទីយ៉ាងសកម្មនៅក្នុងកំណើនលូតលាស់របស់ប្រទេសកម្ពុជា សហគ្រាសទាំងនោះ ត្រូវតែត្រូវបានផ្តល់អោយនូវសម្លេងក្នុងការអភិវឌ្ឍនូវរាល់ក្របខណ្ឌ និងគោលនយោបាយ ដែលពាក់ព័ន្ធនឹងពួកគេ។ គោលនយោបាយសមរម្យ ត្រូវតែអភិវឌ្ឍឡើងនៅគ្រប់កម្រិតទាំងអស់៖ សង្គម នយោបាយ និងសេដ្ឋកិច្ច (OECD ឆ្នាំ២០០៤) ហើយវិធានការដែលមានប្រសិទ្ធិភាព ត្រូវតែដាក់ឲ្យអនុវត្តដើម្បីធានាឱ្យបានថា អំពើពុករលួយ នឹងមិនបានក្លាយជាជំងឺមហារីកដែលបញ្ឈប់នូវការអភិវឌ្ឍរបស់សហគ្រាសធុនតូច និងមធ្យមចាស់ និងថ្មី។

---

[៣] 2012 Global Intergrety Report (របាយការណ៍សុចរិតភាពជាសកលប្រចាំឆ្នាំ ២០១២), ដែលអាចរកបាននៅលើគេហទំព័រ https://www.globalintegrity.org/global_year/2012/ [បានចូលធ្វើការស្រាវជ្រាវនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥]។

[៤] ដូចខាងលើ។

# មាតិកា


## បញ្ជីរូបភាព និងតារាង ............ ១

## វាក្យស័ព្ទប្រើនៅក្នុងការសិក្សានេះ ............ ២

វាក្យស័ព្ទទាក់ទងនឹងច្បាប់និងបទបញ្ញាផ្សេងៗ ............ ២

វាក្យស័ព្ទទាក់ទងនឹងកម្មសិទ្ធិរបស់សហគ្រាស ............ ៣

វាក្យស័ព្ទផ្សេងទៀត ............ ៦

## ១. សេចក្តីសង្ខេបរួម ............ ៧

បរិបទ ............ ៧

ការរកឃើញសំខាន់ៗ ............ ៧

អនុសាសន៍គន្លឹះ ............ ៩

## ២. វិធីសាស្រ្តគំរូ ............ ១០

អំពីការសិក្សាស្រាវជ្រាវ ............ ១០

ការប្រមូលទិន្នន័យ ............ ១១

សីលធម៌នៃការសិក្សាស្រាវជ្រាវ ............ ១៥

បទវិភាគទិន្នន័យ និង របាយការណ៍លទ្ធផល ............ ១៥

សុពលភាព ភាពអាចជឿជាក់ និង ឧភាសកម្មនៃលទ្ធផល ............ ១៦

## ៣. ទិដ្ឋភាពទូទៅនៃសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា ............ ១៨

ក. គុណវុឌ្ឍិនៃសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា ............ ១៨

ខ. ចំណែកនៃសហគ្រាសធុនតូចនិងមធ្យមក្នុងទីផ្សារកម្ពុជា ............ ១៩

គ. គំនិតផ្តួចផ្តើមសម្រាប់ការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម នៅប្រទេសកម្ពុជា ............ ២១

ឃ. វិធាននិងក្របខណ្ឌគតិយុត្តិអនុវត្តចំពោះសហគ្រាសធុនតូច និង មធ្យម ............ ២៥

## ៤. ការរកឃើញ៖ សហគ្រាសធុនតូច និងមធ្យម និងបញ្ហាអំពើពុករលួយក្នុងប្រទេសកម្ពុជា ............ ៣០

ក. អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយ ............ ៣០

ខ. ការយល់ឃើញនិងចំណេះដឹងអំពីអំពើពុករលួយរបស់សហគ្រាស ធុនតូច និងមធ្យម ............ ៣២

គ. វិធីសាស្ត្រប្រើដោយសហគ្រាសធុនតូចនិងមធ្យម ក្នុងការតទល់នឹង អំពើពុករលួយ ............ ៤៨

**៥. សេចក្តីសន្និដ្ឋាន** ........ ៥៥

**៦. អនុសាសន៍គោលនយោបាយ** ........ ៥៦

ក. អនុសាសន៍ទូទៅ ........ ៥៦

ខ. អនុសាសន៍ចំពោះវិស័យឯកជន ........ ៥៦

គ. អនុសាសន៍ចំពោះរដ្ឋាភិបាលនិងស្ថាប័នសាធារណៈ ........ ៥៧

**គន្ថនិទ្ទេស** ........ ៥៩

**ឧបសម្ព័ន្ធ** ........ ៦១

កម្រងសំណួរសម្រាប់នាយកប្រតិបត្តិ ........ ៦២

កម្រងសំណួរសម្រាប់សភាពាណិជ្ជកម្មនិងសមាគម ........ ៧៩

បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាភិបាលប្រឹក្សាយោបល់ ........ ៨២

# បញ្ជីរូបភាព និងតារាង


រូបភាពទី ១៖ វិស័យសកម្មភាពពាណិជ្ជកម្មនៃសហគ្រាសធុនតូច និងមធ្យមក្នុងប្រទេសកម្ពុជា ....................... ២០
រូបភាពទី ២៖ ទីតាំងភូមិសាស្ត្រនៃសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា ................................ ២១
រូបភាពទី ៣៖ ភេទនៃម្ចាស់សហគ្រាស ........................................................................................ ៣២
រូបភាពទី ៤៖ តើអ្វីជាកត្តាដែលបណ្ដាលអោយមានការបង់កម្រៃសេវាក្រៅផ្លូវការក្នុងវិស័យឯកជន ? ................ ៣៤
រូបភាពទី ៥៖ តើអ្នកចូលរួមបទសម្ភាសន៍ បានចុះបញ្ជីក្រុមហ៊ុនរបស់ពួកគេ ដោយរបៀបណា ? ..................... ៤១

តារាងទី១ ៖ ការចាប់ផ្ដើមអាជីវកម្មនៅក្នុងប្រទេសកម្ពុជាប្រៀបធៀបនឹងប្រទេសដទៃទៀត.............................. vi
តារាងទី ២ ៖ អាត្រាផលប៉ះពាល់នៃអំពើពុករលួយលើអាជីវកម្មសហគ្រាសធុនតូចនិងមធ្យម ........................... ៨
តារាងទី៣ ៖ ចំនួននាយកប្រតិបត្តិដែលត្រូវបានសម្ភាសតាមតំបន់និងវិស័យអាជីវកម្ម................................. ១២
តារាងទី៤ ៖ ចំនួននាយកប្រតិបត្តិដែលត្រូវបានសម្ភាសតាមតំបន់និងអនុវិស័យអាជីវកម្ម ............................ ១៣
តារាងទី៥ ៖ និយមន័យនៃសហគ្រាសធុនតូចនិងមធ្យមក្នុងប្រទេសកម្ពុជា............................................ ១៨
តារាងទី ៦៖ ចំនួនគ្រឹះស្ថាននៅកម្ពុជាជាមួយនឹងចំនួនក្រុមហ៊ុនចុះបញ្ជី និងចំនួននិយោជិត ........................ ២០
តារាងទី ៧៖ ប្រភេទសហគ្រាសដែលនាយកប្រតិបត្តិឬអ្នកតំណាងត្រូវបានសម្ភាស ................................... ៣១
តារាងទី ៨ ៖ ពេលវេលាត្រូវការសំរាប់ដំណើរការចុះបញ្ជី ................................................................ ៤១
តារាងទី ៩ ៖ ចំនួនអ្នកឆ្លើយតប ដែលមាននូវបទពិសោធន៍ជួបនឹងបញ្ហាអំពើពុករលួយ
និងផលប៉ះពាល់ លើសហគ្រាសធុនតូចនិងមធ្យម ................................................................. ៤២
តារាងទី ១០ ៖ កំរិតនៃភាពប៉ះពាល់លើជំនួញរបស់ពួកគេ ................................................................ ៤៣
តារាងទី១១ ៖ ការយល់ដឹងរបស់ម្ចាស់សហគ្រាសធុនតូចនិងមធ្យម
ពីវិធានប្រឆាំងអំពើពុករលួយដែល បានដាក់ចេញដោយរាជរដ្ឋាភិបាល ................................................ ៥៣

# វាក្យស័ព្ទប្រើនៅក្នុងការសិក្សានេះ

វាក្យស័ព្ទ ដែលបានប្រើប្រាស់នៅក្នុងការសិក្សានេះ ត្រូវបានកំណត់ក្នុងផ្នែកនេះ។ ចំពោះវាក្យស័ព្ទ ដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិនៃសហគ្រាស វាក្យស័ព្ទទាំងនោះ ត្រូវបានកំណត់នៅក្នុងជំរឿនសេដ្ឋកិច្ចកម្ពុជា។[៥]

## វាក្យស័ព្ទទាក់ទងនឹងច្បាប់និងបទបញ្ញាផ្សេងៗ

១ **ច្បាប់** (**ក្រម**) ៖ គឺជាសេចក្តីព្រាងច្បាប់ ដែលបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា និងឡាយព្រះហត្ថលេខាដោយព្រះមហាក្សត្រ ឬ ប្រមុខរដ្ឋស្តីទី ក្នុងករណីដែលព្រះមហាក្សត្រទ្រង់អវត្តមាន។ ក្រមត្រូវអនុលោម ទៅតាមរដ្ឋធម្មនុញ្ញ។[៦]

២ **ព្រះរាជក្រឹត្យ** ៖ គឺជាបទប្បញ្ញត្តិដែលបានដាក់ចេញដោយអំណាចនីតិប្រតិបត្តិ ដើម្បីរៀបចំដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័នណាមួយ ឬបង្កើតនូវស្ថាប័នរដ្ឋាភិបាលថ្មីមួយ ឬតែងតាំងមន្ត្រីរាជការ ឯកអគ្គរដ្ឋទូត និងចៅក្រម។ ព្រះរាជក្រឹត្យ ត្រូវបានចុះព្រះហត្ថលេខាដោយព្រះមហាក្សត្រ ឬ ប្រមុខរដ្ឋស្តីទី ក្នុងករណីដែលព្រះមហាក្សត្រទ្រង់អវត្តមាន ហើយព្រះរាជក្រឹត្យត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញ។[៧]

៣ **អនុក្រឹត្យ** ៖ គឺជាបទប្បញ្ញត្តិនៃអង្គនីតិប្រតិបត្តិ ដែលបានអនុម័តដោយនាយករដ្ឋមន្ត្រី និងមានការចុះហត្ថលេខាដោយរដ្ឋមន្ត្រីនៃក្រសួងដែលពាក់ព័ន្ធ។ អនុក្រឹត្យ ត្រូវបានប្រើប្រាស់សំរាប់ធ្វើការបញ្ជាក់នូវបទប្បញ្ញត្តិនៃច្បាប់ បង្កើតនូវតួនាទីនិងកាតព្វកិច្ចរបស់ស្ថាប័នរដ្ឋាភិបាល ឬតែងតាំងមន្ត្រីរដ្ឋាភិបាល។

---

[៥] Economic Census of Cambodia 2011 Analysis of the Census Results Report No.4 Analysis on Large, Medium & Small, and Micro industry (ជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១១៖ ការវិភាគលើលទ្ធផលជំរឿន, របាយការណ៍ទី ៤ ការវិភាគលើឧស្សាហកម្មធុនមីក្រូ តូច មធ្យម និង ធំ) http://www.stat.go.jp/info/meetings/cambodia/pdf/c11ana04.pdf. [បានចូលធ្វើការស្រាវជ្រាវនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៥]។

[៦] រដ្ឋធម្មនុញ្ញ មាត្រា ២៨ ១១៣ និង ១៥០ ថ្មី (១៩៩៣)។ សូមមើលផងដែរនូវមាត្រា ៣៣ ៨៥ ៨៨ ៩១ ៩៣ ១១១ និង ១៥៨ នៃរដ្ឋធម្មនុញ្ញ។

[៧] រដ្ឋធម្មនុញ្ញ មាត្រា ២៨ថ្មី និង ១១៣ (១៩៩៣ ដូចវិសោធនកម្មឆ្នាំ ១៩៩៤ និង ១៩៩៩) និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី មាត្រា ៦ និង១៤ (១៩៩៤)។

អនុក្រឹត្យ គឺជាសេចក្តីសម្រេចទូទៅបំផុតរបស់រដ្ឋាភិបាល។ អនុក្រឹត្យ ត្រូវអនុលោមទៅ តាមរដ្ឋធម្មនុញ្ញ និង ច្បាប់ទាំងឡាយណាដែលអនុក្រឹត្យនោះបានធ្វើការយោងលើ។[៨]

៤ **ប្រកាស** ៖ គឺជាបទប្បញ្ញត្តិនៃអង្គនីតិប្រតិបត្តិ ដែលត្រូវបានអនុម័តក្នុងកំរិតក្រសួងដោយរដ្ឋមន្ត្រី ឬដោយនាយកដ្ឋាន ដើម្បីអនុវត្ត បញ្ជាក់ពីបទប្បញ្ញត្តិជាក់លាក់ណាមួយ ដែលមានកំណត់ក្នុងច្បាប់ (រួមទាំងច្បាប់ និងអនុក្រឹត្យ) និងផ្តល់ការណែនាំ។ ប្រកាស ត្រូវតែអនុលោមទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ឬអនុក្រឹត្យ ដែលប្រកាសនេះ សំដៅទៅលើ។[៩]

៥ **សេចក្តីសម្រេច** ៖ ជាទូទៅត្រូវបានចេញដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីក្រសួងដែលពាក់ព័ន្ធ ហើយត្រូវបានប្រើដើម្បីផ្តល់ព័ត៌មានលម្អិតចំពោះវិធានច្បាប់ (រួមទាំងក្រឹត្យ និងអនុក្រឹត្យ)។[១០] នៅពេលដែលសេចក្តីសម្រេចមួយត្រូវបានចេញផ្សាយដោយក្រុមប្រឹក្សាធម្មនុញ្ញ នោះវាគឺជាសេចក្តីសម្រេចចុងក្រោយដែលត្រូវតែគោរព និងមានលក្ខណៈកំពូលក្នុងប្រព័ន្ធច្បាប់ មានន័យថារាល់ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ត្រូវតែអនុលោមយ៉ាងតឹងរ៉ឹងតាមសេចក្តីសម្រេចនេះ។

៦ **សារាចរ** ៖ ជាលិខិត ដែលនាយកដ្ឋានមួយ ឬអាជ្ញាធរមានសមត្ថកិច្ចជាន់ខ្ពស់ ប្រើប្រាស់ដើម្បីបញ្ជាក់ចំណុចមួយជាក់លាក់នៃច្បាប់ ឬដើម្បីផ្តល់នូវសេចក្តីណែនាំ។ សារាចរ មានមុខងារតែមួយគត់ គឺដើម្បីធ្វើការផ្តល់ប្រឹក្សា ហើយវាមិនមានលក្ខណៈចាប់បង្ខំតាមផ្លូវច្បាប់ឡើយ។[១១]

## វាក្យស័ព្ទទាក់ទងនឹងកម្មសិទ្ធិរបស់សហគ្រាស

១. **ក្រុមហ៊ុនឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី)** គឺសំដៅដល់ក្រុមហ៊ុនឯកកម្មសិទ្ធិក្រៅពី ក្រុមហ៊ុនឯកកម្មសិទ្ធិដែលបានបង្ហាញដូចខាងក្រោម។

[៨] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី មាត្រា ១៣ ១៥ ២៨ និង៣០ (១៩៩៤)។

[៩] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី មាត្រា ១៥ ២៨ ២៩ និង៣០ (១៩៩៤)។

[១០] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី មាត្រា ១៣ (១៩៩៤)។ សូមមើលផងដែរនូវអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី មាត្រា ១៣ (១៩៩៤) និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួង។

[១១] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី មាត្រា ២៩ (១៩៩៤)។

២. **ក្រុមហ៊ុនឯកកម្មសិទ្ធិ (បានចុះបញ្ជី)**គឺសំដៅទៅលើរូបវន្តបុគ្គលដែលជាម្ចាស់កម្មសិទ្ធិ ឬសហគ្រិន ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្ម ស្របតាមច្បាប់ស្តីពីសារពើពន្ធ (ឬច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម) ។

៣. **ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ** គឺសំដៅទៅដល់រចនាសម្ព័ន្ធសេដ្ឋកិច្ចមួយ ដែលប្រតិបត្តិការក្រោមកិច្ចសន្យាមួយ ដែលធ្វើឡើងរវាងបុគ្គលពីរ ឬច្រើននាក់ ដើម្បីដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពរបស់ខ្លួន ដើម្បីប្រកបពាណិជ្ជកិច្ចរួម ក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ដូចមានចែងក្នុង មាត្រា ៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

៤. **ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត** គឺសំដៅទៅដល់រចនាសម្ព័ន្ធសេដ្ឋកិច្ចមួយ ដែលប្រតិបត្តិការក្រោមកិច្ចសន្យាមួយ រវាងសហកម្មសិទ្ធិករម្នាក់ ឬច្រើននាក់ ដែលត្រូវបានអនុញ្ញាតឲ្យគ្រប់គ្រង និងបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ក៏ដូចជារវាងសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬច្រើននាក់ ដែលចូលភាគទុន ទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ ដូចមានចែងក្នុង មាត្រា ៦៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

៥. **ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត** គឺជាទម្រង់នៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតមួយ ដែលបានបំពេញនូវល័ក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ៨៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដូចខាងក្រោមនេះ ៖

ក. ក្រុមហ៊ុននេះអាចមាននូវសមាជិកភាគហ៊ុនពី ២ ទៅ ៣០ នាក់។ ប៉ុន្តែបុគ្គលម្នាក់ក៏អាចបង្កើតជាក្រុមហ៊ុនមួយបានដែរ ដែលគេឲ្យឈ្មោះថា សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។

ខ. ក្រុមហ៊ុននេះមិនអាចអនុញ្ញាតឲ្យលក់ភាគហ៊ុន ឬ មូលបត្រដទៃទៀតរបស់ខ្លួន ជាសាធារណៈបានឡើយ ប៉ុន្តែអាចអនុញ្ញាតឲ្យធ្វើអនុប្បទានទៅសមាជិកភាគហ៊ុន សមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន។

៦. **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** គឺជាទម្រង់នៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតមួយ ដែលត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីបោះចេញនូវមូលបត្រជាសាធារណៈបាន ដូចដែលមានចែងក្នុងមាត្រា ៨៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

**៧. បុត្រសម្ព័ន្ធក្រុមហ៊ុនបរទេស**

ក. គឺជាក្រុមហ៊ុនមួយ ដែលបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេស និងដែលមានភាគហ៊ុនយ៉ាងតិច ៥១ភាគរយ កាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ។

ខ. លើសពីនេះទៀត បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត។

គ. បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើម ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីពាណិជ្ជកម្មដោយអនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម។

ឃ. បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចធ្វើគ្រប់សកម្មភាពពាណិជ្ជកម្មជាមុខរបរជាប្រចាំរបស់ខ្លួនដូចក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកដែរ លើកលែងតែសកម្មភាពណា ដែលច្បាប់ហាមឃាត់ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលបរទេស។

ង. ល័ក្ខខណ្ឌទាំងនេះត្រូវបានចែងក្នុងមាត្រា ២៨៣ និង ២៨៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

## ៨. សាខាក្រុមហ៊ុនបរទេស

ក. គឺជាសាខារបស់ក្រុមហ៊ុនបរទេសមួយ។ នាមករណ៍របស់សាខាគឺជានាមករណ៍របស់ក្រុមហ៊ុនដើម និង ត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុន"។

ខ. សាខាក្រុមហ៊ុនអាចធ្វើសកម្មភាពបាន ដូចជាអាចទិញ លក់ ឬផ្តល់ ជាប្រចាំនូវទំនិញ និងសេវាកម្ម ព្រមទាំងធ្វើសកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែឆ្នៃ និងការស្ថាបនាដូចសហគ្រាសក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់ហាមឃាត់ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលបរទេស ដូចមានចែងក្នុងមាត្រា ២៧៨ និង ២៨២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ សកម្មភាព ដែលអាចធ្វើបាននោះមានដូចជា៖

- ក) ទំនាក់ទំនងជាមួយអតិថិជននានា ក្នុងគោលដៅណែនាំអតិថិជនទាំងនោះឲ្យក្រុមហ៊ុនដើមរបស់ខ្លួន។
- ខ) ស្រាវជ្រាវអំពីព័ត៌មានពាណិជ្ជកម្ម និងផ្តល់ពត៌មានទាំងនោះជូនទៅក្រុមហ៊ុនដើមនៅបរទេស។
- គ) ធ្វើការស្រាវជ្រាវផ្នែកទីផ្សារ។
- ឃ) ឃោសនាផលិតផល នៅក្នុងពិពណ៌ពាណិជ្ជកម្ម និងបង្ហាញផលិតផលនៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិពណ៌ដទៃទៀត ។ល។
- ង) ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឲ្យការនៃការតាំងពិពណ៌ពាណិជ្ជកម្ម។
- ច) ជួលការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក។
- ង) ចុះកិច្ចសន្យាជាមួយអតិថិជនក្នុងស្រុក ក្នុងនាមរបស់ក្រុមហ៊ុនដើម។

## ៩. ការិយាល័យតំណាងក្រុមហ៊ុនបរទេស

ក. ការិយាល័យតំណាងនេះ រួមបញ្ចូលទាំង "ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម" របស់ក្រុមហ៊ុនបរទេស។

ខ. នាមករណ៍ត្រូវជានាមករណ៍របស់ក្រុមហ៊ុនដើមនៅឯបរទេស ហើយនាមករណ៍នេះត្រូវសរសេរដាក់ថា “ការិយាល័យតំណាងពាណិជ្ជកម្ម” ឬ “ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម”។

គ. ការិយាល័យនេះ អាចប្រតិបត្តិការសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម ប៉ុន្តែពុំអាចទិញ លក់ ឬផ្តល់ ជាប្រចាំនូវទំនិញ ឬសេវាកម្ម ឬធ្វើការផលិត ការកែច្នៃ និងការស្ថាបនា ដូចមានចែងក្នុងមាត្រា ២៧៤ និង ២៧៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ សកម្មភាពដែលអាចធ្វើបាននោះមានដូចជា៖

ក) ទំនាក់ទំនងជាមួយអតិថិជននានា ក្នុងគោលដៅណែនាំអតិថិជនទាំងនោះឲ្យក្រុមហ៊ុនដើមរបស់ខ្លួន។

ខ) ស្រាវជ្រាវអំពីព័ត៌មានពាណិជ្ជកម្ម និងផ្តល់ពត៌មានទាំងនោះជូនទៅក្រុមហ៊ុនដើមនៅបរទេស។

គ) ធ្វើការស្រាវជ្រាវផ្នែកទីផ្សារ។

ឃ) ឃោសនាផលិតផល នៅក្នុងពិពណ៌ពាណិជ្ជកម្ម និងបង្ហាញផលិតផលនៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិពណ៌ដទៃទៀត ។ល។

ង) ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឲ្យការនៃការតាំងពិពណ៌ពាណិជ្ជកម្ម។

ច) ជួលការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក។

ង) ចុះកិច្ចសន្យាជាមួយអតិថិជនក្នុងស្រុក ក្នុងនាមរបស់ក្រុមហ៊ុនដើម។

# វាក្យស័ព្ទផ្សេងទៀត

**សង្កាត់** សំដៅដល់រដ្ឋបាលថ្នាក់ក្រោមនៃសាលារាជធានី/ក្រុង។

# ១. សេចក្តីសង្ខេបរួម

## បរិបទ

អំពើពុករលួយ បានធ្វើអោយមានការខាតបង់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច ព្រមទាំងប៉ះពាល់ដល់គោលនយោបាយ និងការប្រកួតប្រជែងរបស់សហគ្រាសធុនតូចនិងមធ្យមផងដែរ។

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានផ្អែកលើការស្រាវជ្រាវលើឯកសារ និងបទសម្ភាសន៍ជាមួយនាយកប្រតិបត្តិ ១០០ នាក់ របស់សហគ្រាសធុនតូច និងមធ្យម។ របាយការណ៍នេះ (i)ពិពណ៌នាអំពីបរិស្ថានដែលអាជីវកម្មធ្វើប្រតិបត្តិការនៅក្នុងនោះ ជាពិសេសក្របខណ្ឌគតិយុត្តិ និងការប្រព្រឹត្តទៅនៃស្ថាប័នដែលពាក់ព័ន្ធទៅនឹងអាជីវកម្ម (ii)កំណត់អត្តសញ្ញាណ និងវិភាគអំពីស្ថានភាពផ្សេងៗគ្នា ដែលសហគ្រាសធ្លាប់មានបទពិសោធន៍ជួបប្រទះអំពីអំពើពុករលួយ និងផលប៉ះពាល់នៃអំពើពុករលួយទាំងនោះទៅលើសហគ្រាស (iii)វាយតម្លៃពីប្រតិកម្ម និងការឆ្លើយតប របស់វិស័យអាជីវកម្ម ទៅនឹងអំពើពុករលួយ និងអត្ថិភាពនៃគោលនយោបាយ ឬ ការអនុវត្តជាក់លាក់ផ្សេងៗ ហើយចុងបញ្ចប់ (iv) ផ្តល់អនុសាសន៍គោលនយោបាយថាតើសហគ្រាសធុនតូច និងមធ្យម និងរដ្ឋាភិបាលអាចដោះស្រាយបញ្ហាអំពើពុករលួយបានយ៉ាងដូចម្តេច។

## ការរកឃើញសំខាន់ៗ

ការស្រាវជ្រាវនេះ បានបង្ហាញអោយឃើញថា អំពើពុករលួយ គឺជាកត្តាដែលរាំងដល់ការរីកលូតលាស់របស់សហគ្រាសធុនតូចនិងមធ្យមជាច្រើននៅក្នុងប្រទេសកម្ពុជា។ បើទោះជាភាគច្រើននៃអ្នកចូលរួមក្នុងការសិក្សានេះ បានយល់ថាអ្វីទៅគឺជាអំពើពុករលួយនៅក្នុងទ្រឹស្តី ក៏ប៉ុន្តែវាមានភាពខុសគ្នានៅក្នុងការអនុវត្ត ហើយភាគច្រើននៃអ្នកចូលរួមទាំងនោះ មិនអាច ឬមិនដឹងថា តើធ្វើដូចម្តេចដើម្បីអោយមានការប្រកបអាជីវកម្មស្អាតស្អំ និងមិនចាំបាច់បង់ប្រាក់សំណូក។

អំពើពុករលួយក្នុងសហគ្រាសធុនតូចនិងមធ្យម ត្រូវបានកើតឡើង នៅក្នុងចំណោមធាតុដទៃទៀត ដោយកង្វះនូវចំណេះដឹងពីសំណាក់វិស័យឯកជន ក៏ដូចជាកង្វះនៃការអនុវត្តដ៏មានប្រសិទ្ធិភាពរបស់ច្បាប់ដែលមានស្រាប់ដែរ។ ម្ចាស់អាជីវកម្មមួយចំនួន ថែមទាំងមានភាពស្ទាក់ស្ទើរក្នុងការចុះបញ្ជីក្រុមហ៊ុនរបស់ពួកគេដោយសារតែការចំណាយក្រៅផ្លូវការ ដែលអាចកើតមានដោយសារនីតិវិធីនេះ។

ហេតុដូច្នេះ សហគ្រាសធុនតូចនិងមធ្យមនៅក្នុងប្រទេសកម្ពុជា ត្រូវប្រឈមមុខជាមួយនឹងការប្រព្រឹត្តអំពើពុករលួយនៅគ្រប់ដំណាក់កាល ដោយរាប់បញ្ចូលក្នុងអំឡុងពេលនៃនីតិវិធីចុះបញ្ជីពាណិជ្ជកម្ម និងការធ្វើពាណិជ្ជកម្មរបស់ខ្លួនប្រចាំថ្ងៃ។ ដូចបង្ហាញក្នុងតារាងទី ២ អ្នកចូលរួមបទសម្ភាសន៍ចំនួន៥៥% បានចែករំលែកឲ្យយើងដឹងថា អំពើពុករលួយមានផលប៉ះពាល់ទៅលើអាជីវកម្មរបស់ពួកគេ។

**តារាងទី ២៖ អាត្រាផលប៉ះពាល់នៃអំពើពុករលួយលើអាជីវកម្មសហគ្រាសធុនតូចនិងមធ្យម**

| | ១ ផលប៉ះពាល់តិចតួចបំផុត | ២ | ៣ | ៤ | ៥ ផលប៉ះពាល់ខ្លាំង | គ្មានយោបល់ | គ្មានព័ត៌មាន |
|---|---|---|---|---|---|---|---|
| ភាគរយនៃអ្នកចូលរួម | ៣% | ៣% | ៣% | ១៥% | ១៦% | ១៦% | ២៩% |

លើសពីនេះទៅទៀត ៥៧% នៃអ្នកចូលរួម បានឆ្លើយថា អំពើពុករលួយគឺជាឧបសគ្គផ្នែកខាងក្រៅមួយនៃការរីកចំរើនរបស់ក្រុមហ៊ុនរបស់ពួកគេ។ ម្ចាស់សហគ្រាសធុនតូចនិងមធ្យម មិនបានដឹង ឬមាននូវចំណេះដឹងដែលមានកំណត់ អំពីក្របខណ្ឌអនុវត្ត ដែលទាក់ទងនឹងនីតិវិធីចុះបញ្ជីក្រុមហ៊ុន នីតិវិធីអធិការកិច្ច ឬកាតព្វកិច្ចផ្សេងទៀតដែលពួកគេមាន។ ហេតុដូចនេះហើយ បានជាពួកគេឆ្លងកាត់តាមរយៈភាគីទីបីដែលអន្តរការី (ជាទូទៅគឺ ជាមន្ត្រីដែល ធ្វើការនៅក្រសួងនោះ)។ ការណ៍នេះធ្វើឱ្យម្ចាស់អាជីវកម្មងាយរងគ្រោះចំពោះការស្នើសុំការចំណាយក្រៅផ្លូវការរបស់មន្ត្រី។ ទឹកប្រាក់នេះ មិនមានចំនួនច្រើននោះទេ ប៉ុន្តែវាអាចមានលក្ខណៈសន្ទឹកសន្ធាប់សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងរយៈពេលវែង។ លើសពីនេះទៀត ក្រុមហ៊ុនជាច្រើនមិនធ្វើការចុះបញ្ជីពាណិជ្ជកម្មទេ ប៉ុន្តែនឹងជួបប្រទះជាមួយនឹងបញ្ហាជាច្រើន នៅពេលដែលពួកគេត្រូវបំពេញនូវកាតព្វកិច្ចដែលអនុលោមតាមច្បាប់ ឬនៅពេលដែលពួកគេចង់ស្នើសុំការផ្តល់ឥណទាន មូលនិធិវិនិយោគ ឬការចូលរួមជាដៃគូអាជីវកម្មណាមួយ។

ច្បាប់ និងធនធាននានា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីប្រឆាំងនឹងអំពើពុករលួយ។ ប៉ុន្តែ កត្តាដែលការអនុវត្តច្បាប់នៅមានកំរិត និងកង្វះចំណេះដឹងពីសំណាក់សហគ្រាសធុនតូចនិងមធ្យម ក្នុងចំណោមកត្តាដទៃទៀត គឺជាលទ្ធផលនៃតថភាពដែលវិធានទាំងនេះមិនត្រូវបានប្រើប្រាស់។ លើសពីនេះទៀត អ្នកចូលរួមបទសម្ភាសន៍ជាច្រើនបានប្រាប់យ៉ាងច្បាស់ថា ពួកគេនឹងមិនប្តឹងទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយទេ ហើយក៏មិនទំនាក់ទំនងទៅលេខទូរស័ព្ទហ៊ុតឡាញ (ហ៊ុតឡាញ) ប្រឆាំងអំពើពុករលួយដែរ ប្រសិនបើមានការប្រឈមមុខជាមួយនឹងការប្រព្រឹត្តអំពើពុករលួយ ព្រោះថាពួកគេមិនជឿជាក់ទៅលើវិធានទាំងនោះ។

បន្ថែមពីលើកង្វះនូវចំណេះដឹងនៃវិធានដែលមានស្រាប់ ទាក់ទងទៅនឹងរបៀបដោះស្រាយនៃអំពើពុករលួយ សហគ្រាសធុនតូច និងមធ្យម ជាច្រើន មិនបានអនុម័តនូវវិធាន ឬនីតិវិធីផ្ទៃក្នុងដើម្បីប្រើប្រាស់នៅពេល

ប្រឈមមុខនឹងបញ្ហានេះទេ។ ក្នុងករណីភាគច្រើន ម្ចាស់ ឬ អ្នកគ្រប់គ្រងទូទៅ របស់សហគ្រាស នឹងដោះស្រាយជាមួយនឹងបញ្ហាទាំងនោះ។

# អនុសាសន៍គន្លឹះ

### អនុសាសន៍ទូទៅ

- ធានាឲ្យមានសកម្មភាព និងកិច្ចសហការរួមគ្នា រវាងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចបាននូវការអនុវត្តដ៏មានប្រសិទ្ធិភាពនៃក្របខ័ណ្ឌ និងគោលនយោបាយ សម្រាប់សហគ្រាសធុនតូច និងមធ្យម។
- ផ្តល់ជំនួយដល់សហគ្រាសធុនតូច និងមធ្យម ដោយផ្អែកលើគោលនយោបាយ ដែលមានលក្ខណៈយូរអង្វែង ពិស្តារ ស៊ីសង្វាក់គ្នា និងមានសង្គតិភាព ដើម្បីធានាអោយបាននូវភាពស្មើគ្នាសម្រាប់ម្ចាស់អាជីវកម្មទាំងអស់។

### ចំពោះវិស័យឯកជន

- ធ្វើការលើកទឹកចិត្តដល់ម្ចាស់អាជីវកម្ម ក្នុងការផ្តើមគំនិតសិក្សាបន្ថែមអំពីច្បាប់ បទបញ្ជា និង នីតិវិធីដែលអនុវត្តចំពោះអាជីវកម្មរបស់ខ្លួន និងចាត់វិធានការដើម្បីធានាឱ្យមានសុចរិតភាពអាជីវកម្មនៅក្នុងក្រុមហ៊ុនរបស់ខ្លួន។
- ផ្តល់សិទ្ធិអំណាចដល់ម្ចាស់អាជីវកម្ម ក្នុងការធ្វើការបដិសេធយ៉ាងសកម្មលើការបង់ប្រាក់សូកប៉ាន់ និងក្នុងការប្រើប្រាស់វិធានការដែលបានដាក់ចេញដោយរដ្ឋាភិបាល នាពេលដែលពួកគេប្រឈមនឹងបញ្ហាអំពើពុករលួយ។

### ចំពោះរដ្ឋាភិបាល និងស្ថាប័នសាធារណៈ

- ធ្វើសុខដុមនីយកម្មនូវរាល់ច្បាប់ និងក្របខ័ណ្ឌនានា ដែលត្រូវអនុវត្តចំពោះសហគ្រាសធុនតូច និងមធ្យម ដើម្បីជៀសវាងនូវភាពផ្ទុយគ្នាណាមួយនៅក្នុងច្បាប់ទាំងនោះ។
- បង្កើន និងធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មាន និងបង្កើនចំណេះដឹងលើគោលនយោបាយ និងច្បាប់នានា របស់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យកាន់តែល្អប្រសើរ។
- ធ្វើកំណែទម្រង់លើការចុះបញ្ជីពាណិជ្ជកម្ម ការផ្តល់អាជ្ញាប័ណ្ណ និងនីតិវិធីជាធរមានផ្សេងទៀត

# ២. វិធីសាស្ត្រគំរូ

## អំពីការសិក្សាស្រាវជ្រាវ

ការសិក្សានេះ បង្ហាញពីការរកឃើញនៃសមាសភាគបរិមាណ និងសមាសភាគគុណភាព នៃការសិក្សាស្រាវជ្រាវលើការយល់ឃើញអំពីអំពើពុករលួយក្នុងសហគ្រាសធុនតូច និងមធ្យម នៅប្រទេសកម្ពុជា ដែលរួមមាននូវការសិក្សាស្រាវជ្រាវជាឯកសារ និងការសម្ភាសស៊ីជម្រៅជាមួយនាយកប្រតិបត្តិសហគ្រាសធុនតូច និងមធ្យមចំនួន១០០រូប។

មូលហេតុពីក្រោយសមាសភាគបរិមាណ និងសមាសភាគគុណភាព នៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីផ្តល់នូវការយល់ដឹង និងបរិបទលម្អិតលើបញ្ហាថា តើនាយកប្រតិបត្តិនៃសហគ្រាសទាំងអស់នោះ មានការយល់ឃើញពីបញ្ហាអំពើពុករលួយទាក់ទងនឹងសហគ្រាសរបស់ពួកគាត់ក្នុងប្រទេសកម្ពុជាយ៉ាងណាដែរ។ ខណៈដែលការស្ទាបស្ទង់មតិផ្តល់នូវទិន្នន័យស្ថិតិ ដែលពាក់ព័ន្ធលើការយល់ឃើញរបស់នាយកប្រតិបត្តិទៅលើស្ថានទម្ងន់ដែលអំពើពុករលួយអាចមានមកលើអាជីវកម្មរបស់ពួកគេ កិច្ចសម្ភាសគុណភាពនឹងផ្តល់នូវព័ត៌មានយ៉ាងច្រើនថាតើបញ្ហានៃអំពើពុករលួយនេះមានន័យយ៉ាងដូចម្តេចចំពោះពួកគេ។ លើសពីនេះទៅទៀត តាមរយៈជំហាននៃកិច្ចសម្ភាសនេះ នាយកប្រតិបត្តិសហគ្រាសទាំងនោះ អាចធ្វើការចែករំលែក នូវបទពិសោធន៍ផ្ទាល់ខ្លួន ឬ របស់អ្នកផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងអំពើពុករលួយ ក៏ដូចជាចែករំលែកនូវវិធានពិសេសៗណា ដែលពួកគេប្រកាន់យកដើម្បីកំចាត់ និង/ឬ ជៀសវាងនូវការប្រព្រឹត្តិអំពើពុករលួយ។

ទិន្នន័យនៃបទសម្ភាសន៍ ត្រូវបានចាត់ទុកតាមរយៈការវិភាគជាបណ្តុំទិន្នន័យតែមួយ ដែលបានឆ្លងកាត់ការវិភាគប្រទាក់គ្នាជាមួយនឹងបណ្តុំវិមាត្ររួម។

ដើម្បីទទួលបាននូវទស្សនៈពីភាគីទាំងអស់ សភាពាណិជ្ជកម្ម និង សមាគមពាណិជ្ជកម្ម ក៏ត្រូវបានសម្ភាសផងដែរលើប្រធានបទនេះ។ ការធ្វើបទសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធផ្សេងៗគ្នា អនុញ្ញាតអោយក្រុមសិក្សាស្រាវជ្រាវមានការយល់ដឹងទូលាយលើបញ្ហានេះ។

# ការប្រមូលទិន្នន័យ

ជម្រើសគំរូ និងនីតិវិធីគំរូ ត្រូវបានបង្កើតឡើងដោយឆ្លងកាត់ការពិភាក្សា និងតាមការសំណូមពរ ពីអ្នកជំនាញលើការធ្វើការសិក្សាជាគំរូ និងពីអង្គការតម្លាភាពកម្ពុជា។

អ្នកដែលត្រូវសម្ភាសទាំង ១០០ នាក់ ត្រូវបានជ្រើសរើសព្រាវ ដោយឆ្លងកាត់ការពិចារណាលើចំនុចដូចតទៅ[១២] ៖

១. វិស័យពាណិជ្ជកម្ម ត្រូវបានជ្រើសរើសដោយផ្អែកលើការវិភាគលើទិន្នន័យនៃជំរឿនសេដ្ឋកិច្ចកម្ពុជា២០១១ ដែលបានបង្កើតឡើងក្នុងឆ្នាំ ២០១១ និង ត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៣។[១៣]

២. អត្រាចំនួនអ្នកដែលត្រូវសម្ភាសក្នុងតំបន់នីមួយៗត្រូវបានកំណត់ដោយផ្អែកលើ៖ ជម្រើសគំរូដែលត្រូវបានធ្វើឡើង ដោយផ្អែកលើតំបន់ដែលមានសហគ្រាសធុនតូច និងមធ្យមច្រើនជាងគេក្នុងប្រទេសកម្ពុជា ដោយហេតុថា ក្រុមស្រាវជ្រាវមិនអាចធ្វើដំណើរទៅកាន់គ្រប់តំបន់បានព្រោះពេលវេលា និង ហិរញ្ញវត្ថុមានកម្រិត។ [១៤]

ដោយផ្អែកលើនីតិវិធីខាងលើ ខាងក្រោមនេះជាតួលេខចំនួននាយកប្រតិបត្តិ ដែលត្រូវបានសម្ភាសក្នុងតំបន់ និង វិស័យសំខាន់ៗបំផុត។

---

[១២] ក្រុមស្រាវជ្រាវចង់ធ្វើការជ្រើសរើសគំរូដោយផ្អែកលើបញ្ជីឈ្មោះសហគ្រាសធុនតូច និងមធ្យមទាំងអស់ ប៉ុន្តែការណ៍នេះ មិនអាចធ្វើទៅរួចទេ ដោយសារតែបញ្ជីឈ្មោះសហគ្រាសធុនតូចនិងមធ្យមទាំងអស់ក្នុងប្រទេសកម្ពុជា មិនអាចទទួលបានជាសាធារណៈនោះទេ។ នៅក្នុងកិច្ចជំនួបឯកជនមួយជាមួយរដ្ឋលេខាធិការទទួលបន្ទុកសហគ្រាសធុនតូចនិងមធ្យមនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រុមស្រាវជ្រាវត្រូវបានប្រាប់ឲ្យដឹងថា ក្រសួងកំពុងតែដំណើរការបង្កើតនូវប្រព័ន្ធទិន្នន័យមួយ ដែលមាននូវព័ត៌មានរបស់សហគ្រាសទាំងអស់ ហើយទិន្នន័យនេះនឹងដាក់ជូនជាសាធារណៈនាពេលខ្លីខាងមុខ។

[១៣] ការបែងចែកអ្នក ដែលត្រូវបានសម្ភាសទាំងអស់តាមវិស័យពាណិជ្ជកម្មគឺត្រូវបានពឹកផ្អែកលើទិន្នន័យនៃរបាយការណ៍ទាំងអស់នេះ ដោយ គិតត្រឹមឆ្នាំ២០១១៖ (១) ជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១១៖ ការវិភាគលើលទ្ធផលជំរឿន, របាយការណ៍ទី ១ ការវិភាគលើវិស័យឧស្សាហកម្មចំនួន១៧ អាចស្វែងរកបានតាមរយៈគេហទំព័រ http://www.stat.go.jp/info/meetings/cambodia/pdf/c11ana01.pdf និង (២) ជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១១៖ ការវិភាគលើលទ្ធផលជំរឿន, របាយការណ៍ទី ៤ ការវិភាគលើឧស្សាហកម្មធុនមីក្រូ តូច មធ្យម និង ធំ អាចស្វែងរកបានតាមរយៈគេហទំព័រ http://www.stat.go.jp/info/meetings/cambodia/pdf/c11ana04.pdf.។ កំណត់ចំណាំ៖ ព័ត៌មានសំរាប់ ឆ្នាំ ២០១៤ នឹងត្រូវចេញក្នុងខែកក្កដាឆ្នាំ ២០១៥។

[១៤] មើលរបាយការណ៍ដែលបានរៀបរាប់ខាងលើ។

**តារាងទី៣៖ ចំនួននាយកប្រតិបត្តិដែលត្រូវបានសម្ភាសតាមតំបន់និងវិស័យអាជីវកម្ម**

| វិស័យ | ភ្នំពេញ | សៀមរាប | កំពង់ចាម | កណ្តាល | បាត់ដំបង | សរុប |
|---|---|---|---|---|---|---|
| អប់រំ | ៩ | ៣ | ៦ | ៥ | ៥ | ២៨ |
| សេវាកម្ម ស្នាក់នៅ និងម្ហូបអាហារ | ១៧ | ៦ | ២ | ១ | ២ | ២៨ |
| កម្មន្តសាល | ៩ | ១ | ៣ | ៤ | ២ | ១៩ |
| អាជីវកម្មលក់ដុំនិងរាយ ជួសជុលយានយន្តនិងទោចក្រយានយន្ត | ១៤ | ២ | ១ | ១ | ១ | ១៩ |
| ហិរញ្ញវត្ថុ និង ធានារ៉ាប់រង | ២ | ១ | ១ | ១ | ១ | ៦ |
| សរុប | ៥១ | ១៣ | ១៣ | ១២ | ១១ | ១០០ |

សៀវភៅលឿង (យេលឡូផេចស៍) ត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការស្រាវជ្រាវ និងធ្វើការណាត់ជួបជាមួយអ្នកដែលត្រូវសម្ភាស មុនពេលក្រុមស្រាវជ្រាវចុះទៅតំបន់នីមួយៗ។ ដើម្បីធានានូវភាពចៃដន្យនៃគំរូ ក្រុមស្រាវជ្រាវបានធ្វើការទាក់ទងទៅកាន់ក្រុមហ៊ុន រវាងលំដាប់លេខរៀងទី១០ម្តងក្នុងបញ្ជីឈ្មោះសៀវភៅលឿង ដោយចាប់ផ្តើមពីលេខចៃដន្យ ដូចជាផ្តើមពីលេខ ៣ (គឺក្រុមហ៊ុនបន្ទាប់នឹងជាលេខ ១៣ ២៣ ។ល។)។ ក្នុងករណីដែលសហគ្រាសទាំងអស់ក្នុងបញ្ជីឈ្មោះសម្រាប់សម្ភាសលើវិស័យ និងតំបន់ពាក់ព័ន្ធនីមួយៗ ដែលក្រុមស្រាវជ្រាវបានទាក់ទងទៅ ប៉ុន្តែចំនួនអ្នកដែលត្រូវសម្ភាសមិនទាន់រកបានគ្រប់ចំនួននោះ ក្រុមស្រាវជ្រាវនឹងចាប់ដំណើរការសារជាថ្មី ដោយធ្វើការទាក់ទងទៅក្រុមហ៊ុនណាដែលស្ថិតក្នុងលំដាប់លេខរៀងទី៥ ក្នុងបញ្ជីសៀវភៅលឿង។ ដោយមានការបែងចែកវិស័យពាណិជ្ជកម្មខុសៗគ្នាក្នុងសៀវភៅលឿង ជាមួយនឹងវិស័យពាណិជ្ជកម្មគំរូ ដែលត្រូវបានជ្រើសរើសដើម្បីធ្វើការសម្ភាសនោះ អនុវិស័យពាណិជ្ជកម្ម ដែលត្រូវបានប្រើប្រាស់ក្នុងជំរឿនសេដ្ឋកិច្ចឆ្នាំ ២០១១ និង ភាគរយសមាមាត្រនៃអនុវិស័យពាណិជ្ជកម្មនោះ (ឧទាហរណ៍ដូចជា វិស័យអប់រំ ត្រូវបានបែងចែកទៅជាអនុវិស័យថ្នាក់មធ្យមសិក្សាទូទៅ ថ្នាក់ឧត្តមសិក្សាជាដើម ។ល។) ត្រូវបានយកមកប្រើប្រាស់ដើម្បីធានាថាគ្រប់សហគ្រាសធុនតូច និងកណ្តាលទាំងអស់ដែលត្រូវបានទាក់ទងសម្រាប់សម្ភាស តំណាងអោយគំរូទិន្នន័យ។ នៅពេលណាដែលមានអនុវិស័យច្រើនដូចជាផ្នែករោងចក្រផលិត ពេលនោះមានតែអនុវិស័យដែលតំណាងអោយគំរូចំនួនខ្ពស់បំផុតទេ ដែលត្រូវបានប្រើប្រាស់ ដោយហេតុថាចំនួនអ្នកត្រូវសម្ភាសសរុបមាន

ចំនួនកម្រិត។ ចំនួនសមាមាត្រតំណាងនៃអនុវិស័យ បានបង្ហាញពីចំនួនថ្នាក់ជាតិ ដោយហេតុថាគ្មានទិន្នន័យអំពីចំនួនតំណាងប្រចាំតំបន់នៃអនុវិស័យនីមួយៗ ត្រូវអាចស្វែងរកបានជាសាធារណៈ។

**តារាងទី៤៖ ចំនួននាយកប្រតិបត្តិដែលត្រូវបានសម្ភាសតាមតំបន់និងអនុវិស័យអាជីវកម្ម**

| វិស័យ និងអនុវិស័យ | ភ្នំពេញ | សៀមរាប | កំពង់ចាម | កណ្តាល | បាត់ដំបង |
|---|---|---|---|---|---|
| ១. អប់រំ | ៩ | ៣ | ៦ | ៥ | ៥ |
| ផ្នែកថ្នាក់មត្តេយ្យនិងថ្នាក់បឋម | ៧ | ២ | ៤ | ៣ | ៣ |
| ផ្នែកមធ្យមសិក្សា | ១ | ១ | ១ | ១ | ១ |
| ផ្នែកអប់រំផ្សេងទៀត | ១ | | ១ | ១ | ១ |
| ២. សេវាកម្មស្នាក់នៅនិងសេវាម្ហូបអាហារ | ១៧ | ៦ | ២ | ១ | ២ |
| ផ្នែកស្នាក់នៅរយៈពេលខ្លី | ១ | | | | |
| ផ្នែកភោជនីយដ្ឋាន និងសេវាកម្មម្ហូបអាហារចល័ត | ១១ | ៤ | ១ | ១ | ២ |
| ផ្នែកសេវាកម្មភេសជ្ជៈ | ៥ | ២ | ១ | | |
| ៣. កម្មន្តសាល | ៩ | ១ | 3 | ៤ | ២ |
| ផ្នែករោងកិនផលិតផលគ្រាប់ធញ្ញជាតិ | ៤ | ១ | ២ | ២ | ១ |
| ផ្នែកសំលៀកបំពាក់ | ៣ | | ១ | ១ | ១ |
| ផ្នែកតម្បាញ | ១ | | | ១ | |
| ផ្នែកផលិតស្ករ | ១ | | | | |
| ៤. អាជីវកម្មលក់ដុំនិងរាយ | ១៤ | ២ | ១ | ១ | ១ |
| ផ្នែកលក់រាយផ្សេងៗ ក្នុងវិស័យមិនតាមផ្នែក | ៨ | ២ | ១ | ១ | ១ |
| ផ្នែកលក់រាយតាមស្តង់ និងផ្សារលក់ម្ហូបអាហារ ភេសជ្ជៈ និង ផលិតផលថ្នាំជក់ | ៣ | | | | |
| ផ្នែកលក់រាយលើម្ហូបអាហារតាមផ្នែក | ២ | | | | |
| ផ្នែកលក់រាយតាមស្តង់ និងផ្សារគ្រឿងណាត់ សំលៀកបំពាក់ និង ទ្រនាប់ជើង | ១ | | | | |
| ៥. សេវាកម្មហិរញ្ញវត្ថុ | ២ | ១ | ១ | ១ | ១ |
| សេវាកម្មហិរញ្ញវត្ថុផ្សេងៗ លើកលែងធានារ៉ាប់រង និង មូលនិធិប្រាក់សោធនវត្ត | ២ | ១ | ១ | ១ | ១ |

ក្រុមស្រាវជ្រាវទាំងអស់ បានទទួលនូវការណែនាំច្បាស់លាស់និងលម្អិត លើកម្រងសំណួរស្ទង់មតិ និងសេចក្តីណែនាំក្នុងការធ្វើបទសម្ភាសន៍។ លើសពីនេះទៅទៀត កម្រងសំណួរស្ទង់មតិ ត្រូវបានបង្កើតឡើងដោយមានការសហការគ្នារវាងក្រុមស្រាវជ្រាវ និងក្រុមការងាររបស់អង្គការតម្លាភាពកម្ពុជា ក្រោមការ

ទទួលខុសត្រូវរបស់ប្រធានទីប្រឹក្សា ព្រមទាំងចងចាំជានិច្ចនូវសារៈសំខាន់នៃការទទួលបាននូវចម្លើយពីនាយកប្រតិបត្តិក្នុងទំរង់ដូចគ្នា ដែលត្រូវបានអនុវត្តចំពោះពួកគេ។

កម្រងសំណួរស្ទង់មតិនេះ ផ្តោតលើក្រុមហ៊ុនផ្ទាល់ ក៏ដូចជាលើការយល់ឃើញរបស់នាយកប្រតិបត្តិទាំងអស់លើបរិស្ថានអាជីវកម្មក្នុងប្រទេសកម្ពុជា និងជាពិសេសលើបញ្ហាពុករលួយ។ សំណួរបន្ថែមផ្សេងៗទៀតអាចត្រូវបានលើកឡើងប្រសិនបើមានភាពចាំបាច់។ ជាទូទៅ អ្នកសម្ភាសអាចធ្វើការបន្ថែម ឬកែសំរួលឃ្លាសំណួរ ឬមិនបាច់សួរសំណួរខ្លះក៏បាន (ឧទាហរណ៍ ប្រសិនបើចំលើយត្រូវបានផ្តល់ក្នុងសំណួរមុនដោយឯកឯងរួចហើយ)។ ជារួម អ្នកសម្ភាសជាទូទៅ ត្រូវគោរព និងអនុវត្តទៅតាមទំរង់បែបបទនៃកម្រងសំណួរ និងការណែនាំដែលបានផ្តល់ជូន។

កិច្ចសម្ភាស ត្រូវបានធ្វើឡើងជាបឋម ដោយជំនួបផ្ទាល់ ឬ តាមទូរស័ព្ទ (ផ្អែកតាមការស្នើសុំរបស់អ្នកដែលទទួលយកបទសម្ភាសន៍) ហើយកិច្ចសម្ភាស អាចមានរយៈពេលចន្លោះពី ២០ ទៅ ១២០ នាទី។ គ្រប់សំណួរទាំងអស់ ត្រូវបានសួរក្នុងភាសាណាដែលអ្នកទទួលយកបទសម្ភាសន៍ងាយស្រួលក្នុងការឆ្លើយដោយអាចជ្រើសរើសរវាង ភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។ កំណត់ត្រាចម្លើយ ត្រូវធ្វើភ្លាមៗក្នុងភាសាដើមដើម្បីធានានូវការបាត់ព័ត៌មានតិចតួចបំផុត។

សមាសធាតុចុងក្រោយនៃអ្នកទទួលយកបទសម្ភាសន៍ មិនស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់ក្រុមស្រាវជ្រាវនោះទេ ដោយហេតុថាការស្វែងរកនូវចំនួនអ្នកផ្តល់ចម្លើយគ្រប់គ្រាន់ មានការពិបាកយ៉ាងខ្លាំង។ ពិតណាស់ អ្នកផ្តល់ចម្លើយជាច្រើន មិនចង់ចូលរួមធ្វើបទសម្ភាសន៍នោះទេ ដោយសារតែប្រធានបទនៃការសិក្សា (ឧទាហរណ៍ដូចជាអ្នកខ្លះមិនព្រមលើកទូរស័ព្ទ ឬឆ្លើយតបសារអេឡិចត្រូនិច ដែលអញ្ជើញពួកគាត់អោយចូលរួមធ្វើបទសម្ភាសន៍នោះទេ។)។ អ្នកដែលបានយល់ព្រមអោយធ្វើបទសម្ភាសន៍ពីដំបូងខ្លះ បែរជាមិនមានពេលវេលាផ្តល់អោយនាពេលសម្ភាសទៅវិញ (ឧទាហរណ៍ដូចជាពួកគាត់បដិសេធមិនធ្វើសម្ភាសន៍នៅនាទីចុងក្រោយ ឬធ្វើប្រតិភូកម្មអោយបុគ្គលិកដែលធ្វើការក្នុងស្ថាប័នគាត់ធ្វើបទសម្ភាសន៍ទៅវិញ)។ ដូចនេះហើយ ក្នុងករណី ដែលយុទ្ធសាស្រ្តធ្វើបទសម្ភាសន៍តាមគោលដៅ[១៥] មិនទទួលបានជោគជ័យនោះ ក្រុមស្រាវជ្រាវត្រូវបានបង្ខំអោយប្រើយុទ្ធសាស្រ្តឱកាសនិយមវិញ[១៦]។

[១៥] យុទ្ធសាស្រ្តគំរូទូទៅរបស់យើង អាចពិពណ៌នាថាជាយុទ្ធសាស្រ្តតាមគោលដៅ។

[១៦] ឱកាសនិយម ក្នុងន័យថាឆ្លៀតយកឱកាសដែលមាននៅពេលចុះសម្ភាស (ឧទាហរណ៍ដូចជាការធ្វើបទសម្ភាសន៍ដល់អ្នកដែលមានការពេញចិត្ត នឹងផ្តល់បទសម្ភាសន៍នៅតាមតំបន់ និងតាមប្រភេទនៃវិស័យ ខណៈពេលដែលក្រុមសម្ភាសកំពុងចុះអនុវត្តការងារ)។

## សីលធម៌នៃការសិក្សាស្រាវជ្រាវ

មុនពេលចាប់ផ្តើមធ្វើការសម្ភាសន៍ ក្រុមស្រាវជ្រាវបានពន្យល់ទៅកាន់អ្នកទទួលយកបទសម្ភាសន៍នូវព័ត៌មាននៃការសិក្សាស្រាវជ្រាវ ក៏ដូចជាការប្រើប្រាស់ដែលអាចមានចំពោះទិន្នន័យ និងចម្លើយដែលគាត់បានឆ្លើយ។ បទសម្ភាសន៍នោះមិនត្រូវបានថតទុកនោះទេ ដើម្បីធានាថា អ្នកដែលផ្តល់បទសម្ភាសន៍មានអារម្មណ៍ថាមានសេរីភាពក្នុងការចែករំលែកនូវការគិតរបស់គាត់ដោយបើកចំហក្នុងអំឡុងពេលសម្ភាសន៍។

អ្នកដែលផ្តល់បទសម្ភាសន៍ បានផ្តល់នូវការយល់ព្រមយ៉ាងច្បាស់លាស់ក្នុងការទទួលយកនូវបទសម្ភាសន៍ ហើយក៏ត្រូវបានប្រាប់អោយដឹងដែរថា ពួកគាត់មានសិទ្ធិអាចមិនឆ្លើយសំណួរណាមួយក៏បាន ដែលពួកគាត់មិនចង់ឆ្លើយ ឬបញ្ឈប់បទសម្ភាសន៍នាពេលណាក៏បាន នៅក្នុងអំឡុងពេលផ្តល់បទសម្ភាសន៍។

ទិន្នន័យបទសម្ភាសន៍ត្រូវបានកត់ត្រាទុកដោយឈរលើមូលដ្ឋានអនាមិកភាព ដើម្បីធានាថាអ្នកផ្តល់បទសម្ភាសន៍ខ្លួនឯងផ្ទាល់ ឬអង្គភាព ឬបុគ្គលផ្សេងៗ ដែលអ្នកផ្តល់បទសម្ភាសន៍បានលើកឡើងនៅក្នុងកិច្ចសម្ភាស មិនអាចកំណត់អត្តសញ្ញាណបាន។

## បទវិភាគទិន្នន័យ និង របាយការណ៍លទ្ធផល

សមាជិកក្រុមស្រាវជ្រាវម្នាក់ៗ ដែលធ្វើបទសម្ភាសន៍ មានតួនាទីក្នុងការធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរនៃបទសម្ភាសន៍របស់ខ្លួន។ នៅថ្ងៃដដែល ឬថ្ងៃបន្ទាប់ពីការជួបរួចហើយនោះ គ្រប់កំណត់ត្រានៅអំឡុងពេលធ្វើបទសម្ភាសន៍នោះ ទោះសរសេរជាភាសាខ្មែរក្តី ឬជាភាសាបារាំងក្តី ត្រូវបានបកប្រែទៅជាភាសាអង់គ្លេស បន្ទាប់មកត្រូវបានផ្ញើជូនទៅប្រធានទីប្រឹក្សាសំរាប់ធ្វើការចងក្រងទុក។ ការបកប្រែភ្លាមៗបន្ទាប់ពីការធ្វើបទសម្ភាសន៍នេះ គឺដើម្បីកាត់បន្ថយនូវភាពដែលអាចភ្លេចភ្លាំង ឬបាត់បង់ព័ត៌មាន ដែលបានសម្ភាស។ ក្នុងករណីដែលបទសម្ភាសន៍ ត្រូវបានធ្វើឡើងជាភាសាអង់គ្លេស គឺមានតែកំណត់ត្រាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះដែលត្រូវបានធ្វើឡើង។ បន្ទាប់មក ប្រធានទីប្រឹក្សា នឹងធ្វើការពិនិត្យឡើងវិញនូវកំណត់ត្រាទាំងនោះ។

គ្រប់ព័ត៌មានពីបទសម្ភាសន៍ទាំងអស់ នឹងត្រូវបានកំណត់ត្រាជាលាយលក្ខណ៍អក្សរក្នុងទំរង់ហ្គូដហ្គោល (Google) ដែលអាចអនុញ្ញាតអោយ ព័ត៌មានទាំងអស់នោះចងក្រងចេញជាទិន្នន័យដោយស្វ័យប្រវត្តិ។

ទិន្នន័យនៃបទសម្ភាសន៍ ត្រូវបានវិភាគដោយបែកចែងព័ត៌មានទៅតាមការអនុវត្ត និងផ្នែកទ្រឹស្តី។ វិស័យ និងប្រធានបទដែលសំខាន់បំផុតដែលរកឃើញ ត្រូវបានបកស្រាយបញ្ជាក់ក្នុងរបាយការណ៍នេះ។

## សុពលភាព ភាពអាចជឿជាក់ និង ឧភាសកម្មនៃលទ្ធផល

នីតិវិធីច្រើនបែប ត្រូវបានអនុវត្តនៅក្នុងអំឡុងពេលនៃការសិក្សានេះ ដើម្បីធានានូវសុពលភាព និងភាពអាចជឿជាក់បាននៃការរកឃើញ ហើយជាទូទៅគឺដើម្បីធានានូវតម្លាភាពនៃដំណើរការសិក្សាស្រាវជ្រាវទាំងអស់។

*សុពលភាព* ត្រូវបានធានាដោយ៖

- ការផ្តល់នូវសំណួរស្ទង់មតិដូចៗគ្នាទៅកាន់អ្នកទទួលយកបទសម្ភាសន៍
- ការផ្តល់នូវការណែនាំដល់សមាជិកក្រុមស្រាវជ្រាវទាំងអស់ នាគ្រប់ជំហាននៃការប្រមូលទិន្នន័យ
- ការកត់ត្រាជាលាយលក្ខណ៍អក្សរ និងការវិភាគ យ៉ាងរហ័សលើកំណត់ត្រាបទសម្ភាសន៍ និង
- ការពិនិត្យដោយស្វ័យប្រវត្តិនៃទិន្នន័យបទសម្ភាសន៍ទាំងអស់ដោយប្រធានទីប្រឹក្សា។

នីតិវិធីទាំងនេះ បានធានានូវភាពត្រួតស៊ីគ្នា និងសង្គតភាពក្នុងការប្រមូលទិន្នន័យ។

ដើម្បីធានាបាននូវ*ភាពអាចជឿជាក់បាន* ក្រៅពីការប្រមូលទិន្នន័យ ការពង្រាងនូវរបាយការណ៍គុណភាព និងផ្តល់ជាអនុសាសន៍ដំបូង (ដែលជាទំនួលខុសត្រូវរបស់ក្រុមស្រាវជ្រាវ) វិធីសាស្ត្រប្រឹក្សាជាមួយអង្គការតម្លាភាពកម្ពុជា ត្រូវបានអនុម័ត ដើម្បីធានានូវការពិនិត្យច្រើនដំណាក់កាល និងសុពលភាពនៃការរកឃើញ។ ដរាបណាការផ្តល់យោបល់តបពីក្រុមការងារអង្គការតម្លាភាពកម្ពុជា ត្រូវបានបញ្ចូលក្នុងសេចក្តីពង្រាងរបាយការណ៍ដោយក្រុមស្រាវជ្រាវហើយនោះ របាយការណ៍ត្រូវបានផ្ញើទៅកាន់ក្រុមប្រឹក្សាយោបល់របស់ការសិក្សានេះ។ ក្រុមប្រឹក្សាយោបល់នេះ ដែលមានអ្នកជំនាញ៥រូបពីផ្នែកធុរកិច្ច អប់រំ និងសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា បានផ្តល់នូវយោបល់តបលំអិតលើរបាយការណ៍ តាមរយៈកិច្ចប្រជុំប្រឹក្សា និងតាមរយៈការបញ្ជូនឯកសារជាលាយលក្ខអក្សរ។ ក្រុមស្រាវជ្រាវ បានបញ្ចូលនូវយោបល់តបតាមដែលអាចធ្វើទៅបាន ទៅក្នុងសេចក្តីពង្រាងចុងក្រោយ ហើយរបាយការណ៍ដែលបានបញ្ចប់រួច

ត្រូវបានផ្ញើចេញទៅកាន់អង្គការតម្លាភាពកម្ពុជាជាថ្មីម្តងទៀត សំរាប់មតិយោបល់តបចុងក្រោយមុនពេលធ្វើការបោះពុម្ពផ្សាយ។

ចំពោះ*ឧភាសកម្ម*នៃការរកឃើញវិញ យើងអាចសន្និដ្ឋានបានថា ការរកឃើញតាមលក្ខណៈគុណភាពរបស់យើង ភាគច្រើនមានភាពត្រឹមត្រូវជាងទិន្នន័យគំរូរបស់យើងទៅទៀត ដោយហេតុថាមានភាពដូចគ្នាខ្ពស់ ក្នុងចំណោមចម្លើយពីសំណាក់អ្នកផ្តល់ចម្លើយ។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនអាចស្ថិតក្នុងជំហរមួយដែលសន្មត់ថាចម្លើយដែលយើងទទួលបានពីអ្នកដែលយើងបានសម្ភាសទាំង១០០នាក់នោះអាចយកទៅអនុវត្តជាទូទៅលើសហគ្រាសធុនតូច និងមធ្យមទាំងអស់ ក្នុងន័យនៃការរកឃើញតាមបែបបរិមាណនោះទេ ដោយហេតុថាសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជា មានចំនួនរហូតដល់ទៅជាង ១០ ០០០ សហគ្រាសឯណោះ។ ដោយសារតែឧបសគ្គពេលវេលា និងហិរញ្ញវត្ថុ យើងចាំបាច់កម្រិតនូវការស្រាវជ្រាវរបស់យើង នៅត្រឹមតាមតំបន់ និង វិស័យពាណិជ្ជកម្មសំខាន់ៗក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

# ៣. ទិដ្ឋភាពទូទៅនៃសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា

## ក. គុណវុឌ្ឍិនៃសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា

មកទល់នឹងឆ្នាំ ២០០៥ ប្រទេសកម្ពុជានៅមិនទាន់មាននិយមន័យផ្លូវការណាមួយនៃសហគ្រាសធុនតូច និងមធ្យមនៅឡើយទេ។ ពិតណាស់ ក្រសួងដែលពាក់ព័ន្ធនីមួយៗរបស់រាជរដ្ឋាភិបាល មាននូវនិយមន័យអំពីសហគ្រាសធុនតូចនិងមធ្យម ដោយឡែកពីគ្នាតាមការកំណត់របស់ខ្លួន ហើយក៏គ្មានចំណាត់ការរួមណាមួយដែរ។ ឧទាហរណ៍៖ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានឲ្យនិយមន័យ សហគ្រាសធុនតូច និងមធ្យមថា ជាសហគ្រាសដែលមានបុគ្គលិកតិចជាង ៥០នាក់ ខណៈដែលក្រសួងពាក់ព័ន្ធដទៃទៀត បានកំណត់និយមន័យរបស់ខ្លួនដោយឈរលើមូលដ្ឋានទ្រព្យសកម្មរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ។ ដោយឡែក វិទ្យាស្ថានជាតិស្ថិតិ ចាត់ទុកថាសហគ្រាសធុនតូចនិងមធ្យម ជាសហគ្រាស ដែលមាននិយោជិតតិចជាង ១១នាក់ និងសហគ្រាសធុនធំ ជាសហគ្រាស ដែលមាននិយោជិតច្រើនជាង ១១នាក់ (Baily ឆ្នាំ២០០៧)។ ហេតុដូចនេះហើយ វាពិតជាពិបាកក្នុងការធ្វើការសិក្សាស្រាវជ្រាវណាមួយ ជាមួយទិន្នន័យដែលមានបច្ចុប្បន្នភាពរបស់សហគ្រាសធុនតូច និងមធ្យម ។

នៅឆ្នាំ ២០០៥ អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យមនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបង្កើតឡើង និងបានស្នើ នៅក្នុងក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ដែលត្រូវបានរៀបចំឡើងសម្រាប់គោលដៅស្ថិតិនិងការអភិវឌ្ឍនក៏ដូចជាការអនុវត្តគោលនយោបាយ នូវនិយមន័យដូចខាងក្រោមសម្រាប់ក្រសួងនិងស្ថាប័នទាំងអស់ប្រើប្រាស់ ។ និយមន័យនេះ គឺជានិយមន័យ ដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ។

**តារាងទី៥ ៖ និយមន័យនៃសហគ្រាសធុនតូចនិងមធ្យមក្នុងប្រទេសកម្ពុជា**

| ប្រភេទគ្រឹះស្ថាន | និយមន័យស្ថិតិឈរលើមូលដ្ឋាននៃចំនួននិយោជិត | និយមន័យស្ថិតិឈរលើមូលដ្ឋានហិរញ្ញវត្ថុសម្រាប់ទ្រព្យសកម្ម (គិតជាដុល្លារ ស.រ.អ) ដោយមិនរាប់បញ្ចូល "ដី" |
|---|---|---|
| មីក្រូ | ១០ នាក់ ឬតិចជាងនេះ | តិចជាង ៥០.០០០ |

| | | |
|---|---|---|
| តូច | រវាង ១១ នាក់ ទៅ ៥០ នាក់ | ៥០.០០០ ដល់ ២៥០.០០០ |
| មធ្យម | រវាង ៥១ នាក់ ទៅ ១០០ នាក់ | ២៥០.០០០ ដល់ ៥០០.០០០ |
| ធំ | ច្រើនជាង ១០០ នាក់ | ច្រើនជាង ៥០០.០០០ |

ជំរឿននៅក្នុងប្រទេសកម្ពុជា បានផ្អែកមូលដ្ឋានទិន្នន័យរបស់ខ្លួនលើនិយមន័យស្ថិតិនៃសហគ្រាសធុនតូច និងមធ្យម ដែលតំណាងដោយចំនួននៃនិយោជិតពេញម៉ោង (រាជរដ្ឋាភិបាលកម្ពុជា ២០០៥, ទំព័រ ១៣)។ និយមន័យដោយឈរលើមូលដ្ឋានហិរញ្ញវត្ថុសំរាប់ទ្រព្យសកម្ម ត្រូវបានប្រើប្រាស់ជារឿយៗ នៅក្នុងករណី ដែលចំនួននិយោជិតពេញម៉ោង មិនមានស្ថេរភាពឬមិនអាចរកបាន។

## ខ. ចំណែកនៃសហគ្រាសធុនតូចនិងមធ្យមក្នុងទីផ្សារកម្ពុជា

សហគ្រាសធុនតូចនិងមធ្យម បង្កើតបានជាក្រុមវិសេសមួយ ហើយធ្វើការនៅក្នុងវិស័យអាជីកម្មផ្សេងៗគ្នា។ យោងតាមជំរឿនសេដ្ឋកិច្ចកម្ពុជា [១៧] គិតត្រឹមឆ្នាំ ២០១១ សហគ្រាសនៅក្នុងប្រទេសកម្ពុជា មានចំនួនសរុប ៥០៥ ១៣៤ គ្រឹះស្ថាន[១៨] ដែលក្នុងនោះ ១០ ៨០៩ គ្រឹះស្ថាន គឺជាសហគ្រាសធុតូច និងមធ្យម។ ជិតបីភាគបួន នៃចំនួនសហគ្រាសធុនតូចនិងមធ្យម បានចុះបញ្ជីពាណិជ្ជកម្ម ហើយចំនួននៅសេសសល់ ជាក្រុមហ៊ុនក្រៅផ្លូវការ។ ជារួម សហគ្រាសធុនតូចនិងមធ្យម បានផ្តល់នូវការងារចំនួនប្រមាណ ២៤៥ ៦៧១ ការងារនៅក្នុងប្រទេស។ ចំនួននិយោជិត ដែលត្រូវបានជួលអោយធ្វើការងារដោយសហគ្រាសធុនតូចនិងមធ្យមនីមួយៗ មានលក្ខណៈតិចតួច ពោលគឺ ភាគច្រើនបំផុតមាននិយោជិតចំនួនពី ១១ នាក់ ដល់ ៣០ នាក់ (៨០.៧%) ខណៈពេលដែលប្រភេទធំបំផុតទីពីរ មានចំនួននិយោជិតពី ២១ នាក់ ដល់ ៣០ នាក់ (ស្មើនឹង ១៧.៦%)។ លើសពីនេះទៅទៀត ពាក់កណ្តាលនៃសហគ្រាសធុនតូច និងមធ្យម (៥៤.៣%) ត្រូវបានបង្កើតឡើងនៅទសវត្សចុងក្រោយ

[១៧] រាល់ចំនួនតួលេខទាំងអស់ត្រូវបានយកចេញពីជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១១, ការវិភាគលើលទ្ធផលជំរឿន, របាយការណ៍ទី ៤ ការវិភាគលើឧស្សាហកម្មធុនមីក្រូ តូច មធ្យម និង ធំ ដែលអាចស្វែងរកបាននៅលើគេហទំព័រៈ http://www.stat.go.jp/info/meeting/cambodia/pdf/c11ana.pdf [បានចូលធ្វើការស្រាវជ្រាវនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៥]។

[១៨] នៅឆ្នាំ ២០១៤ សហគ្រាសនៅក្នុងកម្ពុជា មានចំនួន ៥១៣.៧៥៩ គ្រឹះស្ថាន ដែលត្រូវចាត់ទុកថាបានកើនឡើងពីឆ្នាំ ២០១១ (វិទ្យាស្ថានស្ថិតិជាតិ ឆ្នាំ២០១៥)។

នេះ ដែលការណ៍នេះបង្ហាញថាស្ថានភាពពាណិជ្ជកម្មនៅប្រទេសកម្ពុជា មានការកើនឡើងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។

**តារាងទី ៦៖ ចំនួនគ្រឹះស្ថាននៅកម្ពុជាជាមួយនឹងចំនួនក្រុមហ៊ុនចុះបញ្ជី និងចំនួននិយោជិត**

| | សរុប | មីក្រូ | តូច និង មធ្យម | ធំ |
|---|---|---|---|---|
| ចំនួនគ្រឹះស្ថាន | ៥០៥ ១៣៤ | ៤៩៣ ៥៤៤ | ១០ ៨០៩ | ៧៨១ |
| ចំនួនគ្រឹះស្ថានចុះបញ្ជី | ៣៩ ២១២ | ៣០ ៧៨០ | ៧៦៨៨ | ៧៤៤ |
| ភាគរយនៃគ្រឹះស្ថានចុះបញ្ជី | ៧.៧៦ % | ៦.២៤% | ៧១.១២% | ៩៥.២៦% |
| ចំនួននិយោជិតតាមមាត្រដ្ឋាន | ១ ៦៧៣ ៣៩០ | ៩៧៥ ៩៨០ | ២៤៥ ៦៧១ | ៤៥១.៧៣៩ |

រូបភាពទី១ បង្ហាញថា ការអប់រំគឺជាវិស័យអាជីវកម្មសំខាន់បំផុតរបស់សហគ្រាសធុនតូចនិងមធ្យមរបស់ប្រទេសកម្ពុជា ដោយបន្ទាប់មកមាន វិស័យសេវាស្នាក់នៅ និងម្ហូបអាហារ (ដែលក្នុងនោះរួមបញ្ចូលនូវសេវាសុរានិងភេសជ្ជៈផងដែរ)។ វិស័យកម្មន្តសាល និងអាជីវកម្មលក់ដុំនិងរាយ គឺស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ៣ និងទី ៤ ក្នុងចំណោមវិស័យអាជីវកម្មសំខាន់ជាងគេរបស់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងប្រទេសកម្ពុជា។

ការចែករំលែកទីផ្សាធំរបស់វិស័យអប់រំ អាចត្រូវបានពន្យល់ដោយហេតុដែលសមាមាត្រភាគច្រើននៃចំនួនប្រជាជនកម្ពុជាគឺមានវ័យក្មេង។ ចំពោះវិស័យសេវាស្នាក់នៅ និងម្ហូបអាហារវិញ ការកើនឡើងនៃសហគ្រាសធុនតូចនិងមធ្យមនៅក្នុងវិស័យនេះ ជាប់ពាក់ព័ន្ធនឹងការកើនឡើងនៃចំនួនទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។

**រូបភាពទី ១៖ វិស័យសកម្មភាពពាណិជ្ជកម្មនៃសហគ្រាសធុនតូច និងមធ្យមក្នុងប្រទេសកម្ពុជា**



សហគ្រាសធុនតូចនិងមធ្យមភាគច្រើន មានទីតាំងនៅទីក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តបាត់ដំបង ដែលជាតំបន់ដែលការស្ទង់មតិត្រូវបានធ្វើឡើងសំរាប់ការស្រាវជ្រាវនេះ។ (រូបភាពទី ២)

**រូបភាពទី ២៖ ទីតាំងភូមិសាស្រ្តនៃសហគ្រាសធុនតូចនិងមធ្យមនៅក្នុងប្រទេសកម្ពុជា**




# គ. គំនិតផ្តួចផ្តើមសម្រាប់ការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា

## គោលនយោបាយ និងយុទ្ធសាស្រ្តថ្នាក់ជាតិ

ចាប់តាំងពីឆ្នាំ ២00៤ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា សហគ្រាសធុនតូចនិងមធ្យម មានសក្តានុពលខ្លាំងចំពោះការដឹកនាំសេដ្ឋកិច្ចប្រទេសទៅរកភាពរីកចំរើន និងបង្កើតការងារសំរាប់ប្រជាជន។ ដោយសារហេតុផលនេះ ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ត្រូវបានចាត់ទុកជាកត្តាអាទិភាពក្នុងគោលនយោបាយនិងយុទ្ធសាស្រ្តអភិវឌ្ឍន៍ធំៗ ដែលរៀបរៀងឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដូចជា យុទ្ធសាស្រ្តចតុកោណ (យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី១ ដល់ទី៣) និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (គំរោងអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ ១, ២ និង ៣)។

ខណៈដែល យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ ចាត់ទុកការលើកស្ទួយរបស់សហគ្រាសធុនតូចនិងមធ្យម ជាសសរគ្រឹះសំខាន់សំរាប់ការអភិវឌ្ឍវិស័យឯកជន ហើយបញ្ជាក់ថា "ហិរញ្ញប្បទាន ការគ្រប់គ្រង

និងបច្ចេកវិទ្យា គឺជាបញ្ហាប្រឈមដ៏ធំចំពោះសហគ្រាសធុនតូចនិងមធ្យមនៅក្នុងប្រទេសកម្ពុជា” ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិដំណាក់កាលទី៣ ទទួលស្គាល់ថា ការអភិវឌ្ឍបន្ថែមលើវិស័យ សហគ្រាសធុនតូចនិងមធ្យម ផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់សហគមន៍តាមជនបទ ក្នុងទំរង់ជាការកែច្នៃ និងការបន្ថែមតំលៃលើផលិតផល ក៏ដូចជាបង្កើនការងារ។ គោលដៅមួយរបស់ផែនការនេះ គឺបង្កើនការភ្ជាប់ទំនាក់ទំនងដ៏សំខាន់ជាមួយនឹងវិស័យពាណិជ្ជកម្ម ក៏ដូចជាជាមួយនឹងសហគ្រាសធុនធំដែរ។

ក្រៅពីយុទ្ធសាស្រ្ត និងគោលនយោបាយខាងលើនេះ អនុគណៈកម្មាការអន្តរក្រសួងទទួលបន្ទុកសហគ្រាសធុនតូចនិងមធ្យម ដែលបានបង្កើតឡើងនៅឆ្នាំ ២០០៤ ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រសហគ្រាសធុនតូចនិងមធ្យម បានអនុម័តលើក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមដំបូងបង្អស់ នៅឆ្នាំ ២០០៥ (២០០៥-២០១០)[១៩]។ ក្របខណ្ឌនេះ បានទទួលស្គាល់នូវចំនុចសំខាន់ ៤ ដែលជាឧបសគ្គចំពោះការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម៖ ក្របខណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិ ការទទួលបាននូវហិរញ្ញវត្ថុ សកម្មភាពគាំទ្រសហគ្រាសធុនតូចនិងមធ្យម និងដំណើរការអនុវត្តក្របខណ្ឌគោលនយោបាយសហគ្រាសធុនតូច និងមធ្យម។

ទាក់ទងទៅនឹងក្របខណ្ឌគតិយុត្តិនិងបទប្បញ្ញត្តិ បញ្ហាធំៗចំនួន៣ ត្រូវបានលើកឡើង៖ (i) តម្រូវការធ្វើឲ្យប្រសើរនូវនីតិវិធី និងកាត់បន្ថយនូវការចំណាយលើការចុះបញ្ជីក្រុមហ៊ុន (ដែលនៅតែជាធាតុគន្លឹះមួយត្រូវ តែដោះស្រាយ)។ (ii) តម្រូវការបង្កើតដំណើរការត្រួតពិនិត្យបទប្បញ្ញត្តិ និងយន្តការ ដែលផ្តោតសំខាន់លើការកាត់បន្ថយចំនួនអាជ្ញាប័ណ្ណដែលចេញជាន់គ្នាដោយក្រសួងពាក់ព័ន្ធ (ស្ថានភាពដែលដាក់បន្ទុកបន្ថែមលើសហគ្រាសធុនតូច និងមធ្យម) និង (iii) តម្រូវការបង្កើតក្របខណ្ឌគតិយុត្តិ និងពាណិជ្ជកម្ម។

បញ្ហាសំខាន់ទី ២ គឺការទទួលបាននូវហិរញ្ញវត្ថុ។ ការណ៍នេះ ជាបញ្ហាសំខាន់សម្រាប់អាជីវកម្មទាំងអស់ ហើយវានៅតែបន្តជាបញ្ហា ជាពិសេសចំពោះសហគ្រាសធុនតូចនិងមធ្យម។ បញ្ហាសំខាន់៥យ៉ាង ដែលត្រូវដោះស្រាយនៅក្នុងបញ្ហាទី ២ នេះ រួមមាន (១) ការដាក់ទ្រព្យធានា និងការធ្វើប័ណ្ណកម្មសិទ្ធិ (២) ការជួល (៣) ការចែករំលែកព័ត៌មានឥណទាន (៤) ការបង្កើនភាពងាយស្រួលដល់គណនីសំរាប់សហគ្រាសធុនតូចនិងមធ្យម និង (៥) វិទ្យាស្ថានហិរញ្ញវត្ថុដែលមិនមែនជាធនាគារ។

---

[១៩] សូមយោងទៅគេហទំព័រកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំរាប់ព័ត៌បន្ថែម៖ http://www.mef.gov.kh/documents/PFM/7cg_documents/draft_outline_sme.htm [បានចូលធ្វើការស្រាវជ្រាវនៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១៥]។

បញ្ហាសំខាន់ទី៣ គឺការធ្វើអោយប្រសើរនូវសកម្មភាពគាំទ្រចំពោះសហគ្រាសធុនតូចនិងមធ្យម តាមរយៈសេវាកម្មអភិវឌ្ឍន៍អាជីវកម្ម ការទទួលបាននូវទីផ្សារ បច្ចេកវិទ្យា និងការបង្កើនធនធានមនុស្ស និងការទំនាក់ទំនងគ្នា។ ដើម្បីអនុវត្តនូវសកម្មភាពទាំងនោះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានមួយចំនួនដែលនឹងត្រូវរៀបរាប់លម្អិតនៅក្នុងផ្នែកខាងក្រោម។ ទោះបីជាសកម្មភាពគាំទ្រមួយចំនួនត្រូវបានអភិវឌ្ឍប៉ុន្តែតម្រូវការបន្ថែមទៀតត្រូវតែធ្វើ ដោយហេតុថាប្រទេសកម្ពុជានៅតែស្ថិតនៅលំដាប់ថ្នាក់ក្រោមបំផុតនៅក្នុងចំណោមប្រទេសនានារបស់អាស៊ាន និងមានចំណាត់ថ្នាក់លើសតែប្រទេសឡាវមួយគត់ (ERIA ឆ្នាំ ២០១៤ ទំព័រ)។

បញ្ហាទី ៤ គឺទាក់ទងទៅនឹងដំណើរការអនុវត្តនៃក្របខណ្ឌគោលនយោបាយសហគ្រាសធុនតូចនិងមធ្យម ដែលនៅក្នុងក្របខណ្ឌនេះ រដ្ឋាភិបាលកម្ពុជា ត្រូវការធ្វើការអភិវឌ្ឍនូវការសម្របសម្រួលស្ថាប័នមួយរវាងភ្នាក់ងារសំខាន់ៗរបស់រដ្ឋាភិបាល ដើម្បីបង្កើតនិងអនុវត្ត នូវគោលនយោបាយ ដែលមានការសំរបសំរួល និងមានប្រសិទ្ធិភាព ហើយព្រមទាំងលើកកម្ពស់ការសហការដៃគូវិស័យឯកជននិងសាធារណៈ ជាមួយនឹងការអភិវឌ្ឍនូវដំណើរការប្រឹក្សាយោបល់ជាមួយសមាគមពាណិជ្ជកម្មនិងភាគីពាក់ព័ន្ធដទៃទៀត។

នៅឆ្នាំ២០១០ ក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមដំណាក់កាលទី២ (២០១០-២០១៥) ត្រូវបានបង្កើតឡើង ដើម្បីធ្វើពិពិធកម្មឧស្សាហកម្ម ការបង្កើតថ្មី ការប្រើប្រាស់បច្ចេកវិទ្យា និងកំណើនផលិតផល ក៏ដូចជាដើម្បីភ្ជាប់ទំនាក់ទំនងសហគ្រាសធុនតូចនិងមធ្យម ជាមួយនិងសហគ្រាសពហុជាតិដទៃទៀតដែរ។ ទោះបីជាបញ្ហា ដែលត្រូវបានលើកឡើងនៅក្នុងក្របខណ្ឌគោលនយោបាយឆ្នាំ ២០០៥ នៅតែជាបញ្ហានាពេលបច្ចុប្បន្នសំរាប់សហគ្រាសធុនតូចនិងមធ្យមក្នុងប្រទេសកម្ពុជា ក្របខណ្ឌគោលនយោបាយឆ្នាំ២០១០ មានលក្ខណៈធំទូលាយ និងមិនដាក់ចេញនូវគោលនយោបាយ ឬមធ្យោបាយ ដើម្បីដោះស្រាយបញ្ហាជាក់ស្តែងដដែល។ ជាក់ស្តែង ទោះបីជារដ្ឋាភិបាលបានធ្វើអោយមានការរីកចំរើនខាងផ្នែកលើកកម្ពស់ការផ្សព្វផ្សាយបច្ចេកវិទ្យាក៏ដោយ តែបញ្ហាប្រឈមនៅតែមាននៅក្នុងវិស័យស្រាវជ្រាវនិងអភិវឌ្ឍន៍ ចង្កោមបច្ចេកវិទ្យា និងហិរញ្ញវត្ថុនិងបច្ចេកវិទ្យា។ ឧទាហរណ៍៖ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាមានតែមជ្ឈមណ្ឌលបច្ចេកវិទ្យាដ៏តូចមួយប៉ុណ្ណោះ សំរាប់សិស្សប្រតិបត្តិការស្រាវជ្រាវ និងគំរង់ការសាកល្បងរបស់ខ្លួន ក៏ដូចជាការផ្តល់នូវសេវាសំរាប់ក្រុមហ៊ុនឯកជនដទៃទៀត ប្រសិនបើមានការស្នើសុំ។

## ស្ថាប័នគ្រប់គ្រងសហគ្រាសធុនតូចនិងមធ្យម

ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឲ្យមាននូវវេទិការដ្ឋាភិបាល-ផ្នែកឯកជន ដែលមានសមាសភាគក្រុមការងារបច្ចេកទេស ៨ ក្រុម។ ក្រុមការងារបច្ចេកទេសផ្នែកកម្មន្តសាល និងសហគ្រាសធុនតូចនិងមធ្យម មានក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអ្នកតំណាងនៃសភាពាណិជ្ជកម្មកម្ពុជាម្នាក់ជាសហអធិបតី។ អនុគណៈកម្មាការអន្តរក្រសួងសហគ្រាសធុនតូច

និងមធ្យម ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍសហប្រតិបត្តិការក្នុងចំណោមស្ថាប័នផ្សេងៗនានា តាមរយៈការតំណាងរបស់វិស័យឯកជន។ លេខាធិការដ្ឋានរបស់គណៈកម្មាការ ដែលមានទីតាំងនៅក្នុងបរិវេណក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានតួនាទីទទួលបន្ទុកលើការងារលេខាធិការដ្ឋាននេះ និងសម្របសម្រួលសកម្មភាពនានា។

ក្នុងនាមជាស្ថាប័ន និងភ្នាក់ងាររដ្ឋាភិបាលគ្រប់គ្រងបញ្ហាសហគ្រាសធុនតូចនិងមធ្យម នៅក្នុងប្រទេសកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានរៀបចំនូវច្រកចេញចូលតែមួយដើម្បីធ្វើអោយមានប្រសិទ្ធិភាពនូវនីតិវិធីរដ្ឋបាលរបស់សហគ្រាសធុនតូចនិងមធ្យម។ ម៉្យាងវិញទៀត មជ្ឈមណ្ឌលអភិវឌ្ឍន៍អាជីវកម្មច្រកចេញចូលតែមួយសម្រាប់សហគ្រាសធុនតូចនិងមធ្យម ត្រូវបានបង្កើតឡើងផងដែរដើម្បីផ្តល់នូវសេវាប្រឹក្សាខ្លះៗ ដូចជាការបណ្តុះបណ្តាល ការផ្តល់ការប្រឹក្សា និងការផ្តល់យោបល់លើការចុះបញ្ជីពាណិជ្ជកម្មរបស់សហគ្រាសធុនតូចនិងមធ្យម និងលើបញ្ហាច្បាប់និងបញ្ញត្តិដទៃទៀត។ ទូរស័ព្ទទំនាក់ទំនងក៏ត្រូវរៀងចំផងដែរ ដើម្បីទទួលនូវបណ្តឹងពីម្ចាស់សហគ្រាសធុនតូចនិងមធ្យម ចំពោះការប្រព្រឹត្តខុសរបស់មន្ត្រីរដ្ឋាភិបាល។ សេវាកម្មនេះ ត្រូវបានកំណត់នៅក្នុងតំបន់ភ្នំពេញ ហើយមិនផ្សព្វផ្សាយទូលំទូលាយទេ។ ដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម ដូចជាវិធាន និងនីតិវិធីជាដើម គេហទំព័របណ្តាញអ៊ីនធឺណែតមួយ ក៏ត្រូវបានបង្កើតឡើងដែរ។

បន្ទាប់ពីការបោះឆ្នោតចុងក្រោយនៅឆ្នាំ ២០១៣ រដ្ឋាភិបាលបានសំរេចបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលកើតចេញពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល[២០]។ ក្នុងចំណោមទំនួលខុសត្រូវទាំងអស់របស់ក្រសួង គឺមានការលើកម្ពស់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងគោលនយោបាយឧស្សាហកម្មថ្មីដែលនឹងត្រូវអភិវឌ្ឍដោយក្រសួង[២១]។

## កិច្ចសហប្រតិបត្តិការក្នុងវិស័យឯកជន

សមាគមជាច្រើន ត្រូវបានបង្កើតឡើងនៅក្នុងវិស័យឧស្សាហកម្មផ្សេងៗគ្នានៅក្នុងវិស័យឯកជន ដើម្បីលើកតម្កើងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម និងចែករំលែកព័ត៌មាននិងសំរួលការដោះស្រាយ

---

[២០] រាជក្រឹត្យលេខ នស/រកម/១២១៣/០៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម (រាជកិច្ច ឆ្នាំ២០១៣ លេខ ៩៤ ចុះថ្ងៃទី ២៣ ធ្នូ ២០១៣)។

[២១] អនុក្រឹត្យលេខ ៥៧៥ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម (រាជកិច្ច ឆ្នាំ ២០១៤ លេខ ០១ ចុះថ្ងៃទី ០៤ មករា ២០១៤)។

បញ្ហា។ លើសពីនេះទៅទៀត ក៏មានសភាពាណិជ្ជកម្មតាមបណ្តាខេត្តនានា និងសភាពាណិជ្ជកម្មបរទេសជាច្រើនផងដែរ ដែលចូលរួមនៅក្នុងការធ្វើឲ្យរីកចំរើនសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា។

ក្នុងចំណោមសមាគមដែលធំៗនិងមានឥទ្ធិពលជាងគេ គឺមានសម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា (បង្កើតឡើងក្នុងឆ្នាំ ២០១០) សមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា (បង្កើតឡើងក្នុងឆ្នាំ ២០០៦) សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ (បង្កើតឡើងឆ្នាំ ២០០៤) សហគមសហគ្រិនស្រ្តីកម្ពុជា (បង្កើតឡើងឆ្នាំ ២០១១) ។ល។ សមាគមនីមួយៗ មានចំនួនសមាជិកប្រមាណ ១០០ សមាជិក។ សមាគមទាំងនោះ មានកម្មវត្ថុដើម្បីដើរតួនាទីជាក់លាក់ នៅក្នុងចំណោមធាតុផ្សំដទៃទៀត ពោលគឺផ្តល់ព័ត៌មាននិងបណ្តុះបណ្តាលសមាជិករបស់ខ្លួន ដែលជាក្រុមហ៊ុនអន្តរជាតិ ឬសហគ្រាសក្នុងស្រុក។ ប៉ុន្តែ សមាគមទាំងអស់នេះ មិនមែនសុទ្ធតែសកម្ម និងធ្វើការយ៉ាងប្រសិទ្ធិភាពចំពោះសមាជិករបស់ខ្លួនទាំងអស់នោះទេ ដោយហេតុថាសេវាដែលបានផ្តល់ឲ្យទៅសមាជិកនៅមានកម្រិត ទំនាក់ទំនងជាបណ្តាញរវាងសមាគមនានាក៏នៅមានកម្រិត និងសមត្ថភាពបច្ចេកទេសនិងស្រាវជ្រាវក៏នៅមានកម្រិតផងដែរ។ សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា គឺជាគំនិតផ្តួចផ្តើមថ្មី និងត្រូវបានបង្កើតដោយពាណិជ្ជករ២រូប ដោយមានការគាំទ្រពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ តួនាទីរបស់សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា រួមមានការប្រមូលផ្តុំសមាគមពាណិជ្ជកម្ម និងសហគ្រាសពាណិជ្ជកម្មផ្សេងៗគ្នានៅទូទាំងប្រទេស។ សមាជិកចែករំលែកនូវទស្សនៈដូចគ្នា ហើយសមាគមនេះ គឺជាសមាគមដែលសកម្មជាងគេសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

សមាគមនិងសភាពាណិជ្ជកម្មទាំងអស់នេះ កំពុងដើរតួនាទីយ៉ាងសំខាន់តាមរយៈការតំណាងអោយវិស័យឯកជននៅក្នុងវេទិការដ្ឋាភិបាល-ផ្នែកឯកជន ហើយនិងតាមរយៈការលើកឡើងនូវបញ្ហានិងការប្រឈមដែលត្រូវបានជួបប្រទះដោយសហគ្រាសធុនតូចនិងមធ្យម ជូនដល់ស្ថាប័នរដ្ឋាភិបាល ឬនាយករដ្ឋមន្ត្រីក្នុងករណីចាំបាច់។

## ឃ. វិធាននិងក្របខណ្ឌគតិយុត្តិអនុវត្តចំពោះសហគ្រាសធុនតូច និងមធ្យម

នៅប្រទេសកម្ពុជា គ្មានក្របខណ្ឌគតិយុត្តិ ឬបទប្បញ្ញត្តិណាមួយ ចំពោះសហគ្រាសធុនតូចនិងមធ្យមជាពិសេសនោះទេ។ ដូចនេះ សហគ្រាសធុនតូចនិងមធ្យម ត្រូវបានគ្រប់គ្រងដោយក្របខណ្ឌច្បាប់ពាណិជ្ជកម្មទូទៅ ដែលមានជាធរមាននៅក្នុងប្រទេស។ ក្នុងចំណោមក្របខណ្ឌច្បាប់ទាំងនោះ ច្បាប់ និង

បទប្បញ្ញត្តិធំៗ ដែលពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម រួមមាន ច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពផលិតផលនិងសេវាកម្ម ច្បាប់ស្តីពីពាណិជ្ជសញ្ញា ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្តីពីសហគ្រាសពាណិជកម្ម ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ក្ស័យធន។

មុននឹងសហគ្រាសធុនតូចនិងមធ្យម អាចប្រតិបត្តិការដោយស្របច្បាប់ ដោយអនុលោមតាមក្របខណ្ឌគតិយុត្តិនិងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា សហគ្រាសធុនតូចនិងមធ្យម ត្រូវតែគោរពតាមនីតិវិធី និងកាតព្វកិច្ចមួយចំនួន ដូចជាការបំពេញការចុះបញ្ជីពាណិជ្ជកម្មជាមួយនឹងអាជ្ញាប័ណ្ណនិងលិខិតអនុញ្ញាតដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្ម និងរក្សានូវការអនុលោមតាមច្បាប់ក្រុមហ៊ុន ដែលជាកម្មវត្ថុនៃអធិការកិច្ច។ ដំណើរការដូចគ្នានេះ ក៏ត្រូវអនុវត្តផងដែរចំពោះការបិទអាជីវកម្ម។ ផ្នែកខាងក្រោមនេះ និងផ្តល់នូវទិដ្ឋភាពទូទៅនៃនីតិវិធី និងកាតព្វកិច្ចទាំងនោះ។

## ការចុះបញ្ជីពាណិជ្ជកម្ម

យោងតាមច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា រាល់អាជីវកម្មទាំងអស់ត្រូវចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬតាមរយៈមន្ទីពាណិជ្ជកម្មខេត្តឬក្រុង ឬទីតាំងដទៃទៀតដែលត្រូវកំណត់ដោយក្រសួង។ ចាប់តាំងពីមានការអនុម័តក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម នៅឆ្នាំ ២០០៥ មកចំនួននៃក្រុមហ៊ុនដែលបានចុះបញ្ជី មានការកើនឡើងជារៀងរាល់ឆ្នាំ។ រហូតដល់ឆ្នាំ ២០១១ ៧១.១២% នៃចំនួនសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជាទាំងអស់ បានចុះបញ្ជីពាណិជ្ជកម្ម (វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១៣)[២២]។ កត្តានេះកើតឡើងដោយហេតុថា រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយរយៈពេលចុះបញ្ជី តំរូវការឯកសារសំរាប់ចុះបញ្ជីពាណិជ្ជកម្មរបស់សហគ្រាសធុនតូចនិងមធ្យម និងតម្លៃនៃការចុះបញ្ជី ដើម្បីជាការលើកទឹកចិត្តដល់សហគ្រិនទាំងអស់ ជាពិសេសម្ចាស់សហគ្រាសធុនតូចនិងមធ្យមក្នុងការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនពួកគេ ហើយនិងប្តូរសហគ្រាសធុនតូចនិងមធ្យមរបស់ពួកគេពីវិស័យក្រៅផ្លូវការមកជាវិស័យផ្លូវការ។ កំណែទំរង់នៃនីតិវិធីពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មរបស់សហគ្រាសធុនតូចនិងមធ្យម ត្រូវបានធ្វើឡើងនាពេលថ្មីៗនេះ បន្ទាប់ពីការប្រជុំលើកទី ១៧ របស់វេទិការដ្ឋាភិបាល–ផ្នែកឯកជន ដែលធ្វើឡើងនៅ ខែ មីនា ឆ្នាំ ២០១៤។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានប្រគល់ការទទួលខុសត្រូវផ្ទាច់មុខលើការសំរបសំរួលជាមួយនឹងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំនីតិវិធី

[២២] កំណាត់ចំណាំ៖ ព័ត៌មានសំរាប់ឆ្នាំ ២០១៤ នឹងអាចចូលមើលបាននៅខែកក្កដា ឆ្នាំ ២០១៥។

អោយមានលក្ខណៈសាមញ្ញ និងបន្ថយនូវផលលំបាកដែលប្រឈមដោយសហគ្រាសធុនតូចនិងមធ្យម។ ជាមួយនឹងកំណែទំរង់នេះ រយៈពេលនៃការចុះបញ្ជីពាណិជ្ជកម្មត្រូវបានកាត់បន្ថយជាមធ្យមមកត្រឹមប្រហែលជា ៣ ទៅ ៥ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីដាក់នូវឯកសារតំរូវទាំងអស់។ នាពេលបច្ចុប្បន្ននេះ ក្រសួងក៏កំពុងធ្វើការដាក់ចេញនូវនីតិវិធីចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអ៊ិនធើណេតផងដែរ។ ឯកសារ ដែលតំរូវសំរាប់ចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ក៏ត្រូវបានកាត់បន្ថយផងដែរ។ បន្ថែមពីនេះទៀត តំរូវការនៃលិខិតថ្កោលទោស និងលិខិតបញ្ជាក់អាស័យដ្ឋានរបស់ក្រុមហ៊ុន មិនតំរូវឲ្យមានទៀតទេ។ ដើមទុនតំរូវឲ្យមានក្នុងទម្រង់ជាលិខិតបញ្ញើប្រាក់នៅធនាគារសំរាប់ចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ក៏ត្រូវបានកាត់បន្ថយពី ២០លានរៀល មកត្រឹម ៤លានរៀលដែរ។ នាពេលបច្ចុប្បន្ន តម្លៃរដ្ឋបាលសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម មានចំនួន ១.៨លាន រៀល និងតម្លៃរដ្ឋបាលសំរាប់ក្រុមហ៊ុនឯកកម្មសិទ្ធិគឺ ៣០ម៉ឺនរៀល។

## អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត

វាជាការលំបាកណាស់សំរាប់ពាណិជ្ជកម្មថ្មី ដើម្បីឲ្យដឹងថាតើអាជ្ញាប័ណ្ណអ្វីដែលតំរូវឲ្យមាន។ ពិតណាស់ អាជ្ញាប័ណ្ណ មានជាង ៧៥ ប្រភេទ និងអាចអនុវត្តចំពោះសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជា ហើយអាជ្ញាប័ណ្ណទាំងនេះ ត្រូវបានចេញដោយក្រសួងផ្សេងៗគ្នា ទៅតាមវិស័យពាណិជ្ជកម្ម។ គេហទំព័រអនុគណៈកម្មាការនៃសហគ្រាសធុនតូចនិងមធ្យម ដែលមានផ្ទុកព័ត៌មានទាំងអស់ ដែលពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណចំពោះសហគ្រាសធុនតូចនិងមធ្យម ត្រូវបានរាយនាមជាបញ្ជី។

នាពេលថ្មីៗនេះ រដ្ឋាភិបាលកំពុងតែមានភាពសកម្មនៅក្នុងការលើកកំពស់សេវាកម្មតាមប្រព័ន្ធអ៊ិនធើណេត ដើម្បីសំរួល និងបង្កើនល្បឿន នៃនីតិវិធីរដ្ឋបាលសំរាប់ការស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត។ ឧទាហរណ៍៖ នៅខែមេសា ឆ្នាំ២០១៥ ក្រសួងទេសចរណ៍ បានដាក់ឲ្យដំណើរការចុះបញ្ជីដើម្បីសុំអាជ្ញាប័ណ្ណទេសចរណ៍តាមរយៈប្រព័ន្ធអ៊ិនធើណេត[២៣]។ លើសពីលើនេះទៀត ក្រសួងពាក់ព័ន្ធ បានដាក់ចេញរួមគ្នាជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវប្រកាសអន្តរក្រសួងស្តីពីតម្លៃសេវាសាធារណៈសំរាប់ការចុះបញ្ជីស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត ក៏ដូចជារយៈពេលសំរាប់ចុះបញ្ជីផងដែរ។ ដើម្បីធានានូវតម្លាភាព ប្រកាសទាំងនេះ ត្រូវបានដាក់ជាសាធារណៈ និងអាចចូលមើលបាននៅលើគេហទំព័ររបស់អង្គភាពប្រឆាំងអំពើពុករលួយ (www.acu.gov.kh)។

---

[២៣] គេហទំព័រផ្លូវការរបស់ក្រសួងទេសចរណ៍៖ http://www.cambodiatourismindustry.org/។

## ការចុះបញ្ជីពន្ធដារ និងកាតព្វកិច្ចចុះបញ្ជីផ្សេងៗទៀត

បន្ទាប់ពីចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬ ទទួលបានការចុះបញ្ជីពាណិជ្ជកម្មពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលធានានូវដំណើរការចុះបញ្ជីសំរាប់សហគ្រាសធុនតូចនិងមធ្យម សហគ្រាសធុនតូច និងមធ្យម មានរយៈពេល ១៤ ថ្ងៃដើម្បីចុះបញ្ជីពន្ធរបស់ខ្លួន។ នីតិវិធីអាចខុសគ្នាទៅតាមទំហំ ចំណូល និងរបរពន្ធ ដែលសហគ្រាសធុនតូចនិងមធ្យម មានអត្ថិភាព។

ស្របតាមច្បាប់ការងារ សហគ្រាសធុនតូចនិងមធ្យម ដែលជួលបុគ្គលិកឲ្យបំរើការនៅប្រទេសកម្ពុជា ត្រូវចុះបញ្ជីជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មុននឹងចាប់ផ្តើមប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

## អធិការកិច្ច

នៅពេលចុះបញ្ជីពាណិជ្ជកម្មដើម្បីប្រតិបត្តិការនៅប្រទេសកម្ពុជារួច ដូចជាអាជីវកម្មផ្សេងទៀតដែរ សហគ្រាសធុនតូចនិងមធ្យម ត្រូវគោរពទៅតាមដំណាក់កាលខាងក្រោមនៃបទប្បញ្ញត្តិកម្ពុជា ដែលពាក់ព័ន្ធនឹងការអនុលោមតាមច្បាប់របស់ក្រុមហ៊ុន៖

- ការប្រកាសប្រតិវេទ៍ប្រចាំឆ្នាំ៖ វាជាការប្រកាសប្រតិវេទ៍ចុងឆ្នាំនៃឆ្នាំសារពើពន្ធលើស្ថានភាពដៃគូអាជីវកម្មរបស់ក្រុមហ៊ុនទៅដល់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដែលនៅទីនោះ គំរូនៃបែបបទប្រកាសប្រតិវេទ៍ប្រចាំឆ្នាំអាចត្រូវទទួលយកបាន។
- ការថែរក្សាប្រព័ន្ធគណនេយ្យឲ្យត្រឹមត្រូវ៖ សហគ្រាសទាំងអស់ ត្រូវបានតំរូវឲ្យថែរក្សា និងរៀបចំនូវកំណាត់ត្រាហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (ចាប់ផ្តើមពីថ្ងៃទី ០១ មករា នឹងបញ្ចប់ថ្ងៃទី ៣១ ធ្នូ ជារៀងរាល់ឆ្នាំ)។ កំណត់ត្រា ត្រូវធ្វើជាប្រាក់រៀលខ្មែរ និងជាភាសាខ្មែរ ហើយត្រូវផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងរយៈពេល ៣ ខែ បន្ទាប់ពីការបិទឆ្នាំសារពើពន្ធ។ ទោះជាយ៉ាងណាក៏ដោយ សហគ្រាសធុនតូចនិងមធ្យម មិនជាប់កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមបែបស្តង់ដារប្រទេសកម្ពុជា ដូចជាអ្វីដែលបានតម្រូវសំរាប់ក្រុមហ៊ុនធំឡើយ។
- ការបង់ពន្ធ៖ ជាទូទៅមានពន្ធធំៗបួនដែលសហគ្រាសធុនតូចនិងមធ្យម ត្រូវតែបង់ ពោលគឺពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក (តំរូវឲ្យអ្នកបង់កាត់ទុកភាគរយនៃការបង់ប្រាក់ពីអ្នកទទួលបង់ពីព្រោះប្រព័ន្ធប្រមូលពន្ធនាពេលបច្ចុប្បន្ននេះ មិនមានយន្តការដើម្បីប្រមូលដោយផ្ទាល់ពីបុគ្គលទេ) ពន្ធលើតំលៃអាករបន្ថែម និងពន្ធលើប្រាក់ចំណូល។

- ការសុំបន្តអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតជាថ្មី៖ សហគ្រាសធុនតូចនិងមធ្យម ត្រូវស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតជាថ្មី។ នីតិវិធី ត្រូវធ្វើឡើងនៅក្រសួង និស្ថាប័នពាក់ព័ន្ធ ដូចនៅពេលដំណើរការចុះបញ្ជីដែរ។
- ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការផ្លាស់ប្តូររចនាសម្ព័ន្ធក្រុមហ៊ុន៖ ការនេះជាកាតព្វកិច្ច ដែលសហគ្រាសធុនតូចនិងមធ្យម ត្រូវជូនដំណឹងដល់ក្រសួងពាណិជ្ជកម្ម នៅពេលដែលមានការផ្លាស់ប្តូររចនាសម្ព័ន្ធនៅក្នុងក្រុមហ៊ុន ដូចជាវិសោធនកម្មលក្ខន្តិកៈក្រុមហ៊ុន ឬក្នុងករណីក្រុមហ៊ុនបញ្ចូលគ្នា ឬការទិញក្រុមហ៊ុន។

ដើម្បីធានាការអនុលោមតាមច្បាប់ក្រុមហ៊ុនទាំងអស់នេះ ភ្នាក់ងាររដ្ឋាភិបាលត្រូវធ្វើអធិការកិច្ចពីព្រោះការបរាជ័យក្នុងការអនុលោមតាមកាតព្វកិច្ចទាំងនេះ អាចនាំឲ្យសហគ្រាសធុនតូចនិងមធ្យមប្រឈមនឹងការផាកពិន័យ និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

ក្រៅពីអធិការកិច្ចទាំងនេះ សហគ្រាសធុនតូចនិងមធ្យមខ្លះ ក៏ត្រូវជាកម្មវត្ថុនៃការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មរបស់ខ្លួនដែរ។ ឧទាហរណ៍៖ សហគ្រាសធុនតូចនិងមធ្យម នៅក្នុងវិស័យសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ ឬកម្មន្តសាល ជាធម្មតា តែងតែមានការធ្វើអធិការកិច្ចផ្នែកអនាម័យពីក្រសួងសុខាភិបាល។

## ការបិទក្រុមហ៊ុន

ម្ចាស់សហគ្រាសធុនតូចនិងមធ្យម អាចរំលាយក្រុមហ៊ុនរបស់ខ្លួនជាផ្លូវការ (មានន័យថាក្រុមហ៊ុនអាចបញ្ឈប់ភាពជានីតិបុគ្គល) ដោយស្នើសុំទៅក្រសួងពាណិជ្ជកម្ម។ សំណើរ ត្រូវបានផ្ញើរទៅម្ចាស់បំណុលនិងម្ចាស់ភាគហ៊ុនទាំងអស់សំរាប់ទូទាត់បំណុលខ្លះៗ ឬបំណុលទាំងស្រុងរបស់ក្រុមហ៊ុន ក្នុងរយៈពេលជាក់លាក់ណាមួយ។ កត្តានេះ អនុញ្ញាតជាញឹកញាប់ ឲ្យក្រុមហ៊ុនបន្តសកម្មភាពពាណិជ្ជកម្មរបស់ខ្លួនបាន។ ហើយវាក៏អាចឲ្យក្រុមហ៊ុនជៀសវាងនូវតំរូវការដំណើរការបិទក្រុមហ៊ុនតាមរយៈការជម្រះបញ្ជី។ ដំណើរការនេះ ត្រូវចំណាយពេល ៥ ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីដាក់ឯកសារ និងចេញនូវលិខិតលប់ឈ្មោះពីការចុះបញ្ជីពាណិជ្ជកម្ម។

# ៤. ការរកឃើញ៖ សហគ្រាសធុនតូច និងមធ្យម និងបញ្ហាអំពើពុករលួយក្នុងប្រទេសកម្ពុជា

## ក. អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយ

ក្នុងចំណោមអ្នកដែលត្រូវបានសម្ភាសទាំង១០០នាក់ ៥២នាក់ ជាម្ចាស់ក្រុមហ៊ុន (ហើយក៏បំពេញតួនាទីជានាយកប្រតិបត្តិផងដែរ) ១៦នាក់ ជានាយកប្រតិបត្តិឬនាយក និង៣២នាក់ ជានាយកគ្រប់គ្រងទូទៅ ឬមានមុខនាទីផ្សេងទៀតក្នុងសហគ្រាសរបស់ខ្លួន។ ទោះបីជាគោលដៅដំបូង គឺធ្វើការសម្ភាសតែនាយកប្រតិបត្តិក៏ដោយ ក៏ការធ្វើបែបនេះនៅតែមិនអាចធ្វើទៅរួចដោយសារហេតុផលជាច្រើន។ នៅក្នុងសហគ្រាសជាច្រើន នាយកប្រតិបត្តិ ឬម្ចាស់ក្រុមហ៊ុន ដើរតួនាទីមិនសូវសកម្មនៅក្នុងការងារប្រចាំថ្ងៃ ហើយនាយកគ្រប់គ្រងទូទៅ ស្ថិតក្នុងស្ថានភាពប្រសើរជាងនៅក្នុងការចូលរួមក្នុងការស្រាវជ្រាវនេះ។ បន្ថែមលើនេះទៅទៀត នាយកប្រតិបត្តិ ឬម្ចាស់ក្រុមហ៊ុន ច្រើនតែមានភាពមមាញឹកខ្លាំង ហើយមិនចង់ចូលរួមក្នុងការស្រាវជ្រាវបែបនេះទេ ដូចនេះហើយពួកគេបានធ្វើប្រតិភូកម្មអោយអ្នកតំណាងម្នាក់ចេញមុខជំនួសពីស្ថាប័នរបស់ពួកគាត់។ ការនេះ បានធ្វើអោយមានផលប៉ះពាល់ដល់ការប្រមូលទិន្នន័យ ដោយហេតុថាអ្នកតំណាង ដែលផ្តល់បទសម្ភាសន៍នោះ ពុំមែនជាអ្នក ដែលអាចឆ្លើយតបទៅសំណួរទាំងអស់បានទេ។ នៅពេលដែលអ្នកផ្តល់បទសម្ភាសន៍មិនអាចឆ្លើយសំណួរបាន ក្រុមស្រាវជ្រាវបានកត់ចំលើយថា "គ្មានព័ត៌មាន"។ នៅពេលដែលអ្នកផ្តល់បទសម្ភាសន៍មិនមានយោបល់ណាមួយ ឬសំរេចចិត្តថាមិនឆ្លើយ ព្រោះពួកគាត់គិតថាគាត់មិនមានព័ត៌មានដើម្បីឆ្លើយទៅនឹងសំណួរ ឬសំរេចចិត្តថានៅស្ងៀមមិនឆ្លើយនឹងសំណួរនោះ ក្រុមស្រាវជ្រាវបានធ្វើការកត់ចំលើយថា "គ្មានយោបល់"។

ដោយគោរពតាមនិយមន័យនៃសហគ្រាសធុនតូចនិងមធ្យម ដែលបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវនេះ ២២ សហគ្រាស ដែលមាននិយោជិត ១០ នាក់ និងតិចជាងនេះ ព្រមទាំង ៥ សហគ្រាស ដែលមាននិយោជិតច្រើនជាង ១០០ នាក់ ត្រូវបានរក្សាទុកក្នុងគម្រោងនេះ ព្រោះតំរូវការទុនដើមរបស់ពួកគេឆ្លើយតបនឹងលក្ខណៈរបស់សហគ្រាសធុនតូចនិងមធ្យម (មើលតារាងទី ៧)។ ការនេះ ក៏ត្រូវបានអនុវត្តដូចគ្នាចំពោះ ២៨ សហគ្រាស ដែលមានទុនដើមតិចជាង ៥០០០០ ដុល្លារសហរដ្ឋអាមេរិច និង ៤ សហគ្រាសទៀត ដែលមានទុនដើមច្រើនជាង ៥០០០០០ ដុល្លារសហរដ្ឋអាមេរិច។ ហេតុផលនេះបង្ហាញថា ក្នុងស្ថានភាពសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន លក្ខណៈវិនិច្ឆ័យផ្អែកលើចំណូល គួរតែត្រូវយកមក

ពិចារណាផងដែរសំរាប់ការបែកចែកចំណាត់ថ្នាក់របស់សហគ្រាសធុនតូចនិងមធ្យម ដែលវិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ផងដែរដោយធនាគារពិភពលោក។ ចំណូលគឺជារង្វាស់មួយ ដែលមានភាពជាក់លាក់បំផុតរវាងវិស័យពាណិជ្ជកម្មផ្សេងៗ ហើយជួយកាត់បន្ថយភាពមិនច្បាស់លាស់និងភាពមិនជាក់លាក់ ក្នុងការកំណត់និយមន័យសហគ្រាសធុនតូចនិងមធ្យម។

**តារាងទី ៧៖ ប្រភេទសហគ្រាសដែលនាយកប្រតិបត្តិឬអ្នកតំណាងត្រូវបានសម្ភាស**

| ប្រភេទសហគ្រាស | ចំនួន |
|---|---|
| **បុគ្គលិកតិចជាង៥នាក់** | ៣ |
| **បុគ្គលិកពី ៥ ទៅ ១០ នាក់** | ១៩ |
| **បុគ្គលិកពី ១១ ទៅ ៥០ នាក់** | ៦៣ |
| **បុគ្គលិកពី ៥១ ទៅ ១០០ នាក់** | ១៥ |
| **បុគ្គលិកច្រើនជាង ១០០ នាក់** | ៥ |
| **សរុប** | ១០០ |

| ប្រភេទសហគ្រាស | ចំនួន |
|---|---|
| **ទុនតិចជាង ៥០ ០០០ ដុល្លារអាមេរិក** | ២៨ |
| **ទុនចន្លោះពី ៥០ ០០០ ទៅ ២៥០ ០០០ ដុល្លារអាមេរិក** | ៣៨ |
| **ទុនចន្លោះពី ២៥០ ០០០ ដល់ ៥០០ ០០០ ដុល្លារអាមេរិក** | ១២ |
| **ទុនច្រើនជាង ៥០០ ០០០ ដុល្លារអាមេរិក** | ៤ |
| **គ្មានព័ត៌មាន** | ១៨ |
| **សរុប** | ១០០ |

ច្រើនជាងនេះទៅទៀត ក្នុងចំណោមសហគ្រាសទាំង ១០០ ដែលនាយកប្រតិបត្តិ ឬអ្នកតំណាងអោយសហគ្រាស ត្រូវបានសម្ភាសនោះ សហគ្រាសចំនួន ៨៤ ត្រូវបានបង្កើតឡើងក្នុងអំឡុងពេល ១០ ឆ្នាំកន្លងទៅនេះ។ ការនេះ បញ្ជាក់ថា សហគ្រាសធុនតូចនិងមធ្យមដ៏ច្រើន នៅក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្នទើបតែត្រូវបានបង្កើតឡើងថ្មីៗប៉ុណ្ណោះ ដូចដែលបានបកស្រាយក្នុងផ្នែកទី៣ ស្តីពីបរិស្ថាននៃសហគ្រាសធុនតូចនិងមធ្យមនៅក្នុនប្រទេសកម្ពុជានេះ។ តថភាព ដែលសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជា ភាគច្រើនជាសហគ្រាសវ័យក្មេង ហើយនឹងមាននូវក្រុមហ៊ុនមួយចំនួនធំ ដែលមិនបានចុះបញ្ជីពាណិជ្ជកម្មនោះ ធ្វើអោយប្រទេសកម្ពុជាមានភាពទន់ខ្សោយក្នុងការប្រកួតប្រជែងជាមួយប្រទេសដទៃ។

លើសពីនេះទៅទៀត ភាគច្រើន (៧០%) នៃសហគ្រាស ដែលនាយកប្រតិបត្តិ ឬបុគ្គលិក ត្រូវបានសម្ភាស គឺជាសហគ្រាសគោល ហើយមានក្រុមហ៊ុនតែ ៣៤ ប៉ុណ្ណោះ ដែលមានសាខាផ្សេងៗទៀតក្នុងប្រទេសកម្ពុជា។ ពុំមានអ្នកផ្តល់បទសម្ភាសន៍ណាម្នាក់ មានសកម្មភាពអាជីកម្មអាហារ័ណនីហារ័ណនោះទេ។

ដូចដែលបានបង្ហាញនៅក្នុងរូបភាពខាងក្រោមនេះ ម្ចាស់សហគ្រាសភាគច្រើនគឺជាបុរស។ ទោះបីជាមានការសិក្សាស្រាវជ្រាវកាលពីមុនបានបង្ហាញថា នាយកប្រតិបត្តិដែលជាស្ត្រីភាគច្រើន ជួបបញ្ហាប្រឈមច្រើនជាងនាយកប្រតិបត្តិដែលជាបុរសពេលធ្វើជំនួញ បងហាញនេះមិនត្រូវបានបង្ហាញទេនៅក្នុងការសិក្សានេះ។

**រូបភាពទី ៣៖ ភេទនៃម្ចាស់សហគ្រាស**




# ខ. ការយល់ឃើញនិងចំណេះដឹងអំពីអំពើពុករលួយរបស់សហគ្រាសធុនតូច និងមធ្យម

## និយមន័យនៃអំពើពុករលួយ

ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ ២០១១ និងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៃប្រទេសកម្ពុជា មិនបានផ្តល់និយមន័យលើអំពើពុករលួយទេ។ អង្គការតម្លាភាពអន្តរជាតិ កំណត់និយមន័យអំពើពុករលួយថា ជា "ការរំលោភលើអំណាចដែលបានផ្តល់ឲ្យសម្រាប់ប្រយោជន៍ឯកជន"។.[២៤]

---

[២៤] អង្គការតម្លាភាពអន្តរជាតិ, គេហទំព័រស្ថាប័ន, សំណួរចម្លើយស្តីអំពើពុករលួយ ដែលអាចស្វែងរកបាននៅលើគេហទំព័រ៖ http://www.transparency.org/whoweare/organisation/faqs_on_corruption [បានចូលធ្វើការស្រាវជ្រាវនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥]។

ដោយហេតុថាការស្រាវជ្រាវនេះផ្តោតលើការយល់ឃើញអំពីអំពើពុករលួយ គ្មាននិយមន័យលើអំពើពុករលួយជាក់លាក់ណាមួយត្រូវបានបង្កើតនោះទេ។ គោលបំណង គឺដើម្បីស្វែងយល់ថា តើនាយកប្រតិបត្តិគិត និងយល់អំពីអំពើពុករលួយយ៉ាងណាដែរ។ ទោះបីជាការអោយនិយមន័យផ្ទាល់ខ្លួនរបស់អ្នកដែលត្រូវបានសម្ភាសលើអំពើពុករលួយ អាចនឹងខុសៗគ្នាពីម្នាក់ទៅម្នាក់ ដោយផ្អែកលើសាវតានិងតម្លៃរបស់ពួកគាត់ និងកន្លែងដែលពួកគាត់ធ្លាប់រស់នៅនិងបទពិសោធន៍របស់ពួកគាត់ក៏ដោយ ក៏មានធាតុខ្លះបានលេចឡើងជារឿយៗក្នុងនិយមន័យ ហើយវាអាចកំណត់ពីនិន្នាការខ្លះនៅក្នុងនិយមន័យ ដែលបានផ្តល់ឲ្យ។

អំពើពុករលួយ ជាពាក្យមួយដែលម្ចាស់ជំនួញជាច្រើន មានការខ្លាចរអា ហើយពួកគាត់ភាគច្រើនមិនចង់ពិភាក្សាអំពីបញ្ហានេះទេ។ ពិតណាស់ ប្រហែលជា១ភាគ៤ នៃមនុស្សដែលបានទាក់ទងទាំងអស់ប៉ុណ្ណោះដែលបានយល់ព្រមផ្តល់បទសម្ភាសន៍នៅក្នុងគម្រោងនេះ។ ការនេះ អាចដោយសារពួកគាត់មិនមានអារម្មណ៍ស្រួលក្នុងការនិយាយអំពីអំពើពុករលួយ។ លើសពីនេះទៅទៀត អ្នកចូលរួមជាច្រើន មិនចង់ចែករំលែកពីមតិយោបល់របស់ពួកគាត់លើបញ្ហាអំពើពុករលួយ ឬក៏បដិសេធក្នុងការឆ្លើយសំណួរភាគច្រើនដែលបានសួរទៅកាន់ពួកគាត់តែម្តង។ នៅពេលដែលត្រូវបានសួរឲ្យកំណត់ន័យរបស់ “អំពើពុករលួយ” អ្នកចូលរួម២២នាក់ មិនចង់និយាយអំពីអំពើពុករលួយ ឬនិយាយថាពួកគាត់មិនអាចកំណត់ន័យនៃអំពើពុករលួយទេ។ អ្នកចូលរួម ៤ នាក់ បាននិយាយថា អំពើពុករលួយគឺជាប្រាក់ក្រោមតុ ហើយ ៦ នាក់ ទៀតអោយនិយមន័យថាជាការសូកប៉ាន់ ព្រមទាំង ៧ នាក់ ទៀតថាជាអ្វីដែលប្រឆាំងនឹងច្បាប់។

អ្នកចូលរួមខ្លះពិពណ៌នាថា អំពើពុករលួយជាអ្វីដែលអ្នកត្រូវតែធ្វើដើម្បីសម្រេចការងារមួយ ឬដើម្បីសម្រេចការងារណាមួយឲ្យបានលឿនជាងមុន។ ចម្លើយមួយ ដែលដូចគ្នាបំផុតអំពីនិយមន័យនៃអំពើពុករលួយនោះគឺ ជាអ្វីដែលត្រូវបង់ ហើយជាអ្វីដែលប្រឆាំងនឹងច្បាប់ មានន័យថាវាជាការចំណាយបន្ថែម ដែលមិនត្រូវបានទាមទារដោយច្បាប់នោះទេ។ ទោះបីជាអ្នកចូលរួមភាគច្រើន យល់ស្របគ្នាលើសញ្ញាណនេះក៏ដោយ ក៏ភាគច្រើនបានសារភាពថា ពួកគាត់មិនបានដឹងអំពីច្បាប់ដែលអនុវត្តសម្រាប់សហគ្រាសធុនតូចនិងមធ្យមដូចជាសហគ្រាសរបស់ពួកគាត់នោះទេ។ អ្នកដែលត្រូវបានសម្ភាស ច្រើនតែគិតថាច្បាប់មានភាពស្មុគស្មាញ និងពិបាកក្នុងការយល់ ហើយមានអារម្មណ៍ថាពុំមានឯកសារដែលពាក់ព័ន្ធ និងដែលអាចរកបានយ៉ាងងាយស្រួលណាស្តីពីច្បាប់អនុវត្តនោះទេ។ នាយកប្រតិបត្តិមួយចំនួន ដែលត្រូវបានសម្ភាសក្នុងការស្រាវជ្រាវនេះ បានអោយនិយមន័យអំពើពុករលួយថាជាអ្វីដែលពួកគេត្រូវបានបង្ខំអោយធ្វើ ហើយជាអ្វីដែលប្រឆាំងនឹងច្បាប់ទៀត។ លើសពីនេះទៅទៀត ពួកគេគិតថា អំពើពុករលួយ គឺជាអ្វីដែលពាក់ព័ន្ធជាមួយនិងទឹកប្រាក់ចំនួនច្រើន ជាជាង “ប្រាក់ទឹកតែ”។

យោងតាមមតិយោបល់របស់នាយកប្រតិបត្តិ ដែលបានរៀបរាប់ខាងលើ អំពើពុករលួយអាចមានទាំងការសូកប៉ាន់ ការចំណាយក្រៅផ្លូវការ ឬ ការបង់ប្រាក់ផ្សេងៗ។ វាអាចជា “ការយកលុយក្រៅផ្លូវការ” (ឧទាហរណ៍៖ ស្ថានភាពជំនួញ ដែលម្ចាស់ជំនួញនោះ ត្រូវបានទាមទារអោយបង់ច្រើនជាងចំនួនទឹកប្រាក់ដែលត្រូវបង់ដើម្បីទទួលបានសេវាសាធារណៈ ដូចជានីតិវិធីរដ្ឋបាល ឬច្បាប់ ឬឯកសារផ្សេងៗ ជាដើម) ឬ “ការបង់ប្រាក់ក្រៅផ្លូវការ” (ឧទាហរណ៍៖ ការបង់ប្រាក់ ដែលត្រូវបានធ្វើឡើងក្រៅផ្លូវការតាមទម្រង់ជាសាច់ប្រាក់ ឬតាមរូបភាពផ្សេងទៀត ទៅកាន់បុគ្គល ឬស្ថាប័ន ដែលផ្តល់សេវាកម្មដើម្បីទទួលបានជាគុណប្រយោជន៍ពីមន្ត្រីសាធារណៈ ដូចជាការជៀសវាងការបង់ពន្ធជាដើម)។

## មូលហេតុនៃអំពើពុករលួយ

វាអាចមានមូលហេតុជាច្រើនដែលបណ្តាលអោយមានអំពើពុករលួយកើតឡើង។ ក្នុងចំណោមសហគ្រាសទាំង ១០០ ដែលនាយកប្រតិបត្តិ ឬបុគ្គលិក ត្រូវបានសម្ភាសនោះ ៨៦សហគ្រាស ជាសហគ្រាសដែលមានម្ចាស់ជាខ្មែរ។ ការនេះ អនុញ្ញាតអោយយល់ដឹងពីមូលហេតុពិតប្រាកដ ដែលបណ្តាលអោយមានអំពើពុករលួយក្នុងចំណោមសហគ្រាសធុនតូចនិងមធ្យមកម្ពុជាទាំងអស់។ ខាងក្រោមនេះជាមូលហេតុចំបងៗនៃអំពើពុករលួយ ដែលបានលើកឡើងដោយអ្នកចូលរួម។

**រូបភាពទី ៤៖ តើអ្វីជាកត្តាដែលបណ្តាលអោយមានការបង់កម្រៃសេវាក្រៅផ្លូវការក្នុងវិស័យឯកជន?**



## *វប្បធម៌នៃអំពើពុករលួយ*

អ្នកចូលរួម៤៧នាក់ បានចាត់ទុកវប្បធម៌ពុករលួយថាជាមូលហេតុដ៏ធំមួយនៃការបង់កំរៃសេវាក្រៅផ្លូវការ។ លើសពីនេះទៅទៀត នៅពេលដែលត្រូវបានសួរអោយកំណត់ពីនិយមន័យនៃអំពើពុករលួយ អ្នកចូលរួម ៦ នាក់ បានបកស្រាយថាមានវប្បធម៌ទូទៅនៃការប្រព្រឹត្តអំពើពុករលួយក្នុងប្រទេសកម្ពុជា។ ក្នុងចំនោម អ្នកចូលរួមទាំងនោះ មានតែអ្នកចូលរួម ២ នាក់ ប៉ុណ្ណោះ ដែលបាននិយាយយ៉ាងច្បាស់ថា វាជារឿង សាមញ្ញក្នុងការអោយ "ប្រាក់ទឹកតៃ"[២៥] ហើយការបង់កំរៃក្រៅផ្លូវការនេះមិនចមែនជាអំពើពុករលួយនោះទេ។ អ្នកចូលរួមម្នាក់ ក៏បានិយាយដែរថា កំរៃក្រៅផ្លូវការនេះ គ្រាន់តែជាអំណោយដល់មន្ត្រីសាធារណៈតែប៉ុណ្ណោះ។ នាពេលដែត្រូវសួរអោយកំណត់និយមន័យនៃកំរៃក្រៅផ្លូវការ អ្នកចូលរួមតែចំនួន ២៣ នាក់ ប៉ុណ្ណោះ ដែលយល់ព្រមថាការអោយកំរៃក្រៅផ្លូវការ គឺជាអំពើពុករលួយ ឬជា "ប្រាក់ទឹកតៃ"។ អ្នកចូលរួម ១៤ នាក់ ផ្សេងទៀត មិនអាច ឬមិនចង់ផ្តល់និយមន័យណាមួយនោះទេ ខណៈដែលអ្នកចូលរួម ៧ នាក់ទៀត ឯកភាពថា វាជាកំរៃបន្ថែម ដែលត្រូវបង់ដើម្បីទទួលបានការងាររួចរាល់លឿនជាងមុន ជាមួយនិង ដំណើរការរដ្ឋបាលមិនសូវពិបាក។ អ្នកចូលរួមមួយចំនួន បានអោយទឹកប្រាក់តិចល្មមទៅអធិការដោយ មិនចាំបាច់ត្រូវបានទាមទារអោយធ្វើដូច្នោះ ប្រសិនបើអធិការចិត្តល្អ និងអធិការកិច្ចដំណើរការទៅល្អ។ អ្នកចូលរួមខ្លះ បានលើកឧទាហរណ៍ពីការជូនអំណោយទៅមន្ត្រីសាធារណៈនៅពេលដែលពួកគេទៅជួប មន្ត្រីទាំងនោះដើម្បីសួរសំណួរផ្សេងៗ។ ពួកគេនិយាយថាប្រាក់សគុណនោះយ៉ាងតិចបំផុតអាចកាតកោស បញ្ចូលលុយទូស័ព្ទពី ៥ដុល្លារឡើងទៅ។ អំណោយ ដែលបានលើកឡើងនោះ អាចតិចតួចដូចជា ការអោយកាតបញ្ចូលទូរស័ព្ទដៃ ចំនួន ៥ ដុល្លាសហរដ្ឋអាមេរិក ជាដើម ។ ក្នុងករណីនេះ ទឹកប្រាក់បញ្ចូល ទូរស័ព្ទ ត្រូវបានអោយទៅមន្ត្រីសាធារណៈក្នុងន័យថ្លែងអំណរគុណចំពោះពួកគេ។ ប្រជាជនកម្ពុជា យល់ ឃើញថា ការនេះជារឿងធម្មតា ខណៈពេលដែលជនបរទេសចាត់ទុកថា ការនេះជាទ្រង់ទ្រាយមួយនៃអំពើ ពុករលួយ។

អ្នកដែលត្រូវបានសម្ភាសម្នាក់ បានប្រើភាសិតខ្មែរដើម្បីធ្វើការអត្ថាធិប្បាយនូវមូលហេតុដែលម្ចាស់ជំនួញ ចាំបាច់ត្រូវតែបង់ប្រាក់ទឹកតៃ (ជាពិសេសក្នុងបរិបទនៃ "ការយកលុយក្រៅផ្លូវការ") ៖ "អារសាច់ជូនខ្លា ទើបនៅស្រុកបាន" (ការបកប្រែន័យត្រង់)។ ដោយផ្អែកតាមការសម្ភាសន៍ ការបង់ និង ការទទួលយក ការសូកប៉ាន់ ហាក់ដូចជារឿងធម្មតានៅក្នុងវិស័យជំនួញ។

---

[២៥] នៅក្នុងប្រទេសកម្ពុជា ប្រាក់ទឹកតៃ គឺសំដៅដល់កម្រៃក្រៅផ្លូវការ ដែលត្រូវបានផ្តល់អោយមន្ត្រីសាធារណៈក្នុងការផ្លាស់ប្តូរ នូវសេវាកម្ម។

## *ច្បាប់ និង បទប្បញ្ញត្តិ មិនច្បាស់លាស់*

បើទោះជាច្បាប់ និងវិធានការមួយចំនួន ត្រូវបានដាក់ចេញនៅក្នុងឆ្នាំថ្មីៗកន្លងទៅនេះដើម្បីបង្កើននូវបរិយាកាសអាជីវកម្មរបស់សហគ្រាសធុនតូច និងមធ្យមក៏ដោយ ក៏នៅមានការងារជាច្រើនទៀត ដែលត្រូវសម្រេច ហើយសហគ្រាសធុនតូចនិងមធ្យមរបស់កម្ពុជា នៅតែជួបប្រទះជាមួយបញ្ហាប្រឈមជាច្រើននៅក្នុងការបង្កើតក្រុមហ៊ុន និងជាទូទៅនៅក្នុងការធ្វើជំនួញប្រចាំថ្ងៃ។

ភាគច្រើននៃម្ចាស់សហគ្រាសធុនតូចនិងមធ្យម មិនយល់ច្បាស់ពីច្បាប់ និងបទប្បញ្ញត្តិ ដែលអនុវត្តលើពួកគេនោះទេ។ នៅពេលដែលចុះបញ្ជីពាណិជ្ជកម្មសហគ្រាសធុនតូចនិងមធ្យមរបស់ពួកគេ ម្ចាស់អាជីវកម្មភាគច្រើនជឿថា ច្បាប់មានភាពស្មុគស្មាញ ហើយចូលចិត្តអោយតតិយជនជួយសំរាប់ដំណើរការចុះបញ្ជីពាណិជ្ជកម្ម។

នាយកប្រតិបត្តិបរទេសម្នាក់ បានចែករំលែកថា គាត់ចង់បំពេញដំណើរការចុះបញ្ជីពាណិជ្ជកម្មដោយខ្លួនឯងដែរ តែគាត់បានដឹងយ៉ាងឆាប់រហ័សថា ការនេះវាមានភាពស្មុគស្មាញណាស់សំរាប់ជនបរទេសដូចជារូបគាត់។ ដូចនេះគាត់ ក៏បានជួលមេធាវីម្នាក់អោយជួយដល់ដំណើរការចុះបញ្ជីពាណិជ្ជកម្ម ហើយមេធាវីនោះ បានប្រាប់គាត់ថា កំរៃក្រៅផ្លូវការ គឺត្រូវតែបង់។ គាត់បន្ថែមទៀតថា ប្រសិនបើគាត់ចុះបញ្ជីពាណិជ្ជកម្មសហគ្រាសដោយខ្លួនឯង នោះគាត់នឹងត្រូវបង់កំរៃក្រៅផ្លូវការនោះច្រើនជាងធម្មតាទៅទៀត ព្រោះថាកត្តាមួយក្នុងចំណោមកត្តាជាច្រើនទៀត គឺគាត់ជាជនបរទេស។

របៀបដែលអធិការកិច្ចប្រព្រឹត្តទៅ ដូចដែលបានបកស្រាយដោយអ្នកចូលរួម គឺជាឧទាហរណ៍យ៉ាងច្បាស់ថាតើច្បាប់ និងបទប្បញ្ញត្តិ មានភាពមិនច្បាស់លាស់យ៉ាងដូចម្តេចខ្លះ។ បើទោះជាអធិការកិច្ចខ្លះ ជាកាតព្វកិច្ច និងបញ្ញត្តិដោយច្បាប់ក៏ដោយ ក៏អ្នកដែលត្រូវបានសម្ភាសជាច្រើន បានចែករំលែកនូវបទពិសោធន៍របស់ពួកគេ ទាក់ទងនឹងអធិការកិច្ច ដែលពួកគេមិនដែលត្រូវបានស្នើអោយបង់កំរៃក្រៅផ្លូវការនោះទេ។

អ្នកដែលត្រូវបានសម្ភាសជាច្រើន បានទទួលនូវការចុះទស្សនៈកិច្ចពីក្រសួងផ្សេងៗ ដោយអាស្រ័យលើវិស័យជំនួញ និងទីតាំងដែលពួកគេបានចុះបញ្ជីពាណិជ្ជកម្ម។ ៤០% នៃអ្នកចូលរួម បានបង់កំរៃក្រៅផ្លូវការជាមួយនឹងអធិការកិច្ច ខណៈដែលអ្នកចូលរួម ៣០% មិនបានបង់អ្វីសោះឡើយ។ អ្នកចូលរួម ១២ នាក់មិនបានដឹងថាតើពួកគេត្រូវបង់កំរៃនេះឬទេ ហើយ ១៨ នាក់ទៀត មិនបានឆ្លើយសំណួរនេះទេ។

អធិការកិច្ចទូទៅបំផុត គឺធ្វើឡើងដោយមន្ត្រីមកពីក្រសួងអប់រំសម្រាប់សាលាឯកជន ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានពន្ធដារ និងតំណាងមកពីសង្កាត់។

អ្នកដែលត្រូវបានសម្ភាសខ្លះ បាននិយាយថា ពួកគេបានទទួលការចុះទស្សនៈកិច្ចពីនគរបាលនិងអ្នកតំណាងអោយសង្កាត់ច្រើនជាងធម្មតា គឺក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរ។ គោលដៅនៅក្នុងទស្សនៈកិច្ចទាំងនោះ គឺដើម្បីសួររកអំណោយបន្ថែម ដោយហេតុថាជាបុណ្យចូលឆ្នាំថ្មី។ ម្ចាស់ជំនួញមួយចំនួនបានជូនជាកញ្ចប់ស្រាបៀរ ឬភេសជ្ជៈផ្សេងទៀត។

បានីយដ្ឋាន និងភោជនីយដ្ឋាន ដែលត្រូវបានសម្ភាសនៅក្នុងគម្រោងនេះ បានទទួលនូវការចុះអធិការកិច្ចម្តង ឬពីរដង ក្នុង១ឆ្នាំ ដើម្បីចុះពិនិត្យឧបករណ៍បំពង់ពន្លត់អគ្គីភ័យ។ លើសពីនេះទៅទៀត បានីយដ្ឋាននិងភោជនីយដ្ឋានភាគច្រើន ត្រូវបានប្រាប់ថាពួកគេត្រូវតែទិញឧបករណ៍ពន្លត់អគ្គីភ័យពីមន្ត្រីនគរបាលដោយផ្ទាល់ ដោយសារច្បាប់តម្រូវ ហើយដែលតំលៃថ្លៃជាងតម្លៃធម្មតារហូតដល់ទៅ ៣ ដង។

សាលាឯកជនជាច្រើន បានទទួលនូវអធិការកិច្ចពីក្រសួងអប់រំទាក់ទងការបង្រៀនរបស់គ្រូ។ យោងតាមចម្លើយរបស់នាយកសាលា និងម្ចាស់សាលា អធិការកិច្ចរបស់ក្រសួងអប់រំ ជាធម្មតាត្រូវបានធ្វើឡើងដោយក្រុមមនុស្សដែលមានសមាជិកពី ៤ ទៅ ៦ នាក់ ដែលពេលខ្លះអ្នកទាំងនោះ បានសួររក "ប្រាក់ទឹកតែ" សំរាប់ការធ្វើដំណើររបស់ពួកគេ ដែលមានចំនួនទឹកប្រាក់ជាធម្មតាបន្តិចបន្តួចដែរ។

ម្ចាស់សាលាម្នាក់ ដែលជួលគ្រូបរទេសជាច្រើននោះ បាននិយាយថា ពួកគាត់បានទទួលទស្សនៈកិច្ច ជារឿយៗពីនាយកដ្ឋានអន្តោប្រវេសន៍ ទាក់ទងនឹងលិខិតអនុញ្ញាតការងារសំរាប់គ្រូបរទេស។ សាលាទាំងអស់នោះ មាននូវកូតាសម្រាប់គ្រូបរទេស ដែលពួកគេអាចជួល ហើយក្នុងករណី ដែលមានចំនួនលើសកូតា ទឹកប្រាក់ផាកពិន័យនឹងត្រូវស្នើអោយបង់ ឬពួកគេអាចបង់ប្រាក់បន្ថែមដើម្បីទទួលបានការអនុញ្ញាតពិសេស។ ក្នុងករណីទាំងនេះ នាយកសាលាបាននិយាយថា គាត់មិនបានទទួលវិក័យប័ត្រទទួលប្រាក់ផ្លូវការណាមួយនោះទេ ហើយគាត់ចាត់ទុកថា នោះជាការ "ចរចារ" ដោយផ្ទាល់តែម្តងជាមួយអធិការ។ ភាគច្រើននៃអ្នកដែលត្រូវបានសម្ភាស ដែលបានបង់ប្រាក់អធិការកិច្ច មិនបានទទួលវិក័យប័ត្រណាមួយទេ ទោះបីជាពួកគាត់បានស្នើសុំក៏ដោយ។

នៅពេលដែលសួរថាតើនិយោជិតរបស់ពួកគាត់ដឹងថាតើត្រូវធ្វើយ៉ាងណាឬអត់នាពេលពួកគេជួបនឹងបញ្ហាណាមួយ អ្នកទទួលសម្ភាសភាគច្រើនបានបញ្ជាក់ថា និយោជិតភាគច្រើនរបស់ពួកគាត់ តែងរុញបញ្ហានោះ អោយទៅម្ចាស់ឬ នាយកប្រតិបត្តិតែម្តង។ ជាក់ស្តែង អ្នកចូលរួម ៤៨ នាក់ បាននិយាយថា ម្ចាស់ឬនាយកប្រតិបត្តិក្រុមហ៊ុនគឺជាបុគ្គលដែលត្រូវរ៉ាប់រ៉ងលើអធិការកិច្ចទាំងអស់ក្នុងសហគ្រាសរបស់ខ្លួន។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងបោះផ្សាយនូវការណែនាំស្តីពីអធិការកិច្ចសំរាប់សហគ្រាសធុនតូច និងមធ្យម។[២៦] ការណែនាំនេះ ត្រូវបានរំពឹងថានឹងចេញអនុវត្តក្នុងឆ្នាំ២០១៤ តែដោយសារបញ្ហាមូលនិធិ ការណែនាំទាំងនោះ មិនទាន់ត្រូវបានបោះពុម្ពផ្សាយនោះទេ បើទោះជាក្រសួងបាននិយាយថា ឯកសារទាំងអស់នេះ បានធ្វើរួចរាល់ហើយក្តី។ ការណែនាំទាំងនេះ នឹងក្លាយជាឧបករណ៍ដ៏មានប្រយោជន៍សំរាប់សហគ្រាសធុនតូចនិងមធ្យម ដោយសារតែវា ត្រូវបានសន្មត់ថាបានគ្របដណ្តប់ យ៉ាងទូលំទូលាយលើអធិការកិច្ចពាណិជ្ជកម្ម ។

## *កង្វះការអនុវត្តច្បាប់*

អ្នកចូលរួម ៥៣ នាក់ គិតថា កង្វះនៃការអនុវត្តច្បាប់ គឺជាកត្តាមួយដែលធ្វើអោយមានការបង់កំរៃក្រៅផ្លូវការ។ កង្វះនៃការអនុវត្តច្បាប់ បង្កើតអោយមាននូវការបង់ប្រាក់ក្រៅផ្លូវការក្នុងអាជីវកម្មពីមួយថ្ងៃទៅមួយថ្ងៃ ឧទាហរណ៍ដូចជាជាមួយនឹងអធិការកិច្ច និង ដំណើរការចុះបញ្ជីជាដើម។ កង្វះនៃការអនុវត្តច្បាប់ បានចូលរួមយ៉ាងខ្លាំងផងដែរនៅក្នុងហេតុ ដែលក្រុមហ៊ុនមួយចំនួនធំមិនបានចុះបញ្ជី និងមិនបានបង់ពន្ធ។ ក្នុងចំណោមអ្នកចូលរួមទាំង ១០០ នាក់ នៅក្នុងការស្រាវជ្រាវនេះ ក្រុមហ៊ុន ៦១ បានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ឬនាយកដ្ឋានពាណិជ្ជកម្មខេត្ត។ អ្នកចូលរួមភាគច្រើន ដែលមិនបានចុះបញ្ជីក្រុមហ៊ុនបានបកស្រាយថាការចុះបញ្ជីនោះមានភាពស្មុគស្មាញ ឬថ្លៃពេកលើសពីការនាំប្រយោជន៍ដែលការចុះបញ្ជីនោះនាំអោយពួកគាត់អាចទទួលបាន។ ជាការពិតណាស់ សហគ្រាសធុនតូច និងមធ្យមជាច្រើន កំពុងដំណើរការក្រៅផ្លូវការ ដែលត្រូវបានយោគយល់ដោយមន្ត្រី។ លើសពីនេះ ក្នុងចំណោមអ្នកចូលរួមទាំងអស់ មានក្រុមហ៊ុនតែ៣១ប៉ុណ្ណោះ បានចុះបញ្ជីជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រុមហ៊ុនជាច្រើន មិនបានចុះបញ្ជីនោះទេ ព្រោះជំនួញដែលពួកគេធ្វើជាជំនួញគ្រួសារ ឬនិយោជិតរបស់ពួកគេ ជារឿយៗមិនធ្វើការក្នុងរយៈពេលយូរជាមួយពួកគេទេ។

នាយកប្រតិបត្តិជាច្រើន ធ្វើការជាមួយអ្នកតំណាងក្រសួងពាក់ព័ន្ធ ឬការិយាល័យក្នុងស្រុក ហើយពេលដែលត្រូវបានសួរពីដំណើរការចុះបញ្ជី ពួកគាត់មិនអាចឆ្លើយដោយច្បាស់លាស់បាននោះទេ។ អ្នកដែល

---

[២៦] Inspection guide for SMEs waits for funding (សៀវភៅណែនាំស្តីពីអធិការកិច្ចសម្រាប់សហគ្រាសធុនតូច និងមធ្យមរង់ចាំការផ្តល់មូលនិធិ) កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៥ អាចចូលមើលបាននៅលើទំព័រៈ http://www.phnompenhpost.com/inspection-guide-smes-waits-funding [បានចូលធ្វើការស្រាវជ្រាវនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥]។

ត្រូវបានសម្ភាស ដែលបានប្រើប្រាស់សេវាកម្មអន្តរការីនោះ បានឯកភាពថា កំរៃក្រៅផ្លូវការ ត្រូវបានរាប់បញ្ចូលក្នុងចំនួនទឹកប្រាក់សរុប ដែលពួកគេបានបង់ តែបានបញ្ជាក់ថា ពួកគេមិនអាចដឹងពីចំនួនពិតប្រាកដជាក់ស្តែងថាតើពួកគេចំណាយលើកំរៃផ្លូវការ ឬក្រៅផ្លូវការប៉ុន្មាននោះទេ។ ការប្រើប្រាស់សេវាកម្មអន្តរការី ដែលធ្វើការនៅក្រសួង គឺជាភាពទូទៅរបស់អ្នកដែលត្រូវបានសម្ភាស។

លើសពីនេះទៅទៀត អ្នកដែលត្រូវបានសម្ភាសជាច្រើន បានចែករំលែកនូវបទពិសោធន៍ក្នុងការចរចាការបង់ពន្ធរបស់ពួកគាត់ជាមួយអ្នកតំណាងពីនាយកដ្ឋានពន្ធដារ។ ក្នុងករណីខ្លះ ពួកគាត់អាចសម្រេចបាននូវការចរចាដើម្បីទទួលបានការបង់ពន្ធក្នុងតំលៃថេរ មានន័យថាពួកគេ ត្រូវបង់ពន្ធនូវតំលៃមួយថេរជារៀងរាល់ខែ ដោយមិនគិតពីចំនួននៃប្រាក់ចំណេញនោះទេ។

### *កង្វះឯករាជ្យភាព និងប្រសិទ្ធិភាពប្រព័ន្ធតុលាការ*

អ្នកដែលត្រូវបានសម្ភាស ៥៣ នាក់ មានមតិយោបល់ថា ប្រព័ន្ធតុលាការទុនខ្សោយក្នុងប្រទេសនេះ គឺជាហេតុផលសំខាន់មួយដែលធ្វើអោយមានការបង់កំរៃក្រៅផ្លូវការ។ លើសពីនេះ ១ភាគ៣ នៃអ្នកចូលរួមតែប៉ុណ្ណោះ ដែលបាននិយាយថា ពួកគាត់នឹងប្រើប្រព័ន្ធតុលាការ ប្រសិនបើពួកគាត់ជួបបញ្ហាអំពើពុករលួយធំ។ ដូច្នេះ កង្វះប្រសិទ្ធិភាពប្រព័ន្ធតុលាការ បណ្តាលអោយមានកង្វះខាតគណនេយ្យភាពរបស់មនុស្សជាច្រើន។

### *បញ្ហាប្រាក់បៀវត្សន៍វិស័យសាធារណៈទាប*

អ្នកដែលត្រូវបានសម្ភាស ៥៣ នាក់ បានគិតថា ប្រាក់បៀវត្សន៍ទាបរបស់មន្ត្រីសាធារណៈ គឺជាកត្តាដែលបណ្តាលអោយកើតមានការបង់កំរៃក្រៅផ្លូវការយ៉ាងច្រើន។ អ្នកដែលត្រូវបានសម្ភាសខ្លះ បាននិយាយថា ការអោយប្រាក់ទឹកតែទៅមន្ត្រី គឺជាការជួយគាត់ ឬការអនុគ្រោះ ដោយសារតែប្រាក់បៀវត្សន៍របស់មន្ត្រីទាំងនោះទាប។ ការបង់ការចំណាយលើអធិការ ត្រូវបានចាត់ទុកថាជារឿងសាមញ្ញ។ អ្នកចូលរួមជាច្រើន ត្រូវបានស្នើអោយបង់ "ប្រាក់ទឹកតែ" ដើម្បីគ្រប់គ្រងដល់ការចំណាយទាក់ទងនឹងទស្សនៈកិច្ចរបស់អធិការ ដូចជាមធ្យោបាយធ្វើដំណើរ និងការចំណាយលើអាហារពេលព្រឹកឬពេលថ្ងៃជាដើម។

### *កង្វះតម្លាភាពនិងគណនេយ្យភាព*

អ្នកដែលត្រូវបានសម្ភាស ៤៨ នាក់ បានគិតថា ពួកគាត់ត្រូវតែបង់កំរៃក្រៅផ្លូវការនៅអំឡុងពេលដំណើរការចុះបញ្ជី ហើយ ២២ នាក់ ក្នុងចំណោមពួកគេនោះ គិតថា ពួកគេមិនចាំបាច់ធ្វើដូចនេះទេ ខណៈដែល

អ្នកដែលនៅសល់មិនដឹងអំពីដំណើរការនៃការចុះបញ្ជីនោះទេ។ អ្នកដែលត្រូវបានសម្ភាសមួយចំនួន បានបញ្ជាក់ថា ពួកគាត់ នឹងធ្វើការចុះបញ្ជីពាណិជ្ជកម្ម នៅពេលណាដែលដំណើរការចុះបញ្ជីលើអ៊ីនធើណែតត្រូវបានដាក់ចេញអោយប្រើប្រាស់។ អ្នកដែលត្រូវបានសម្ភាសម្នាក់ ក្នុងចំណោមអ្នកដែលត្រូវបានសម្ភាសទាំងអស់នោះ បានធ្វើការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនរបស់ខ្លួនដោយខ្លួនឯង ដោយបំពេញទំរង់បែបបទតាមរយៈប្រព័ន្ធអ៊ីនធើណែត តែបានបញ្ជាក់ថាវាមិនដំណើរការទេ។ ការអនុវត្តអំពើពុករលួយជាច្រើន ដែលត្រូវបានចែករំលែកជាមួយនឹងក្រុមស្រាវជ្រាវនោះ គឺបានកើតឡើងនៅក្នុងដំណើរការចុះបញ្ជីពាណិជ្ជកម្ម ហើយនៅដំណាក់កាលខុសៗគ្នា។ ការអនុវត្តទាំងនេះ មានភាពខុសគ្នាអាស្រ័យលើថា តើម្ចាស់ក្រុមហ៊ុន ប្រើប្រាស់សេវាកម្មអន្តរការី (មេធាវី ឬអន្តរការីពីខាងរាជរដ្ឋាភិបាល) ដែលនៅក្នុងករណីទាំងនេះ ម្ចាស់សហគ្រាសអាចនឹងមិនមានព័ត៌មានណាមួយទាក់ទងនឹងការបង់កំរៃក្រៅផ្លូវការ។ តំលៃនៃការចុះបញ្ជីនោះ ក៏ខុសៗគ្នាផងដែរ អាស្រ័យលើបុគ្គលពីនាយកដ្ឋាន ដែលសហគ្រាសទាក់ទង ហើយក៏អាស្រ័យលើមុខតំណែងរបស់បុគ្គលនោះផងដែរ។ អ្នកដែលត្រូវបានសម្ភាស បាននិយាយថា បុគ្គលមួយចំនួន ដែលបំរើការងារមានមុខនាទីតូចតាច អាចនឹងសុំការសូកប៉ាន់តិចតួច សម្រាប់នីតិវិធីណាមួយ តែនៅពេលសួរថាតើច្បាប់តម្រូវអោយធ្វើដូចនេះជាចាំបាច់ដែរទេ ពួកគេមិនអាចឆ្លើយបានឡើយ។ ការស្គាល់អ្នកដែលមានអំណាចមុននាទីធំក៏ជាគុណប្រយោជន៍សំខាន់សំរាប់ក្រុមហ៊ុនដើម្បីធ្វើជំនួញប្រចាំថ្ងៃផងដែរ។ ទង្វើបែបនេះ នាំអោយមានភាពលំបាកក្នុងការមានកម្រឹតទីលានប្រកួតមួយ សម្រាប់សហគ្រាសធុនតូចនិមធ្យមក្នុងប្រទេសកម្ពុជា។ អវត្តមាននៃទីលានប្រកួតនេះ បានបង្កើតអោយមាននូវទម្រង់នៃការប្រកួតប្រជែងមិនស្មោះត្រង់ដល់ម្ចាស់ពាណិជ្ជកម្ម ដែលចង់គោរពតាមការទាមទារទាំងឡាយរបស់ច្បាប់ ហើយវាក៏មានផលប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថានពាណិជ្ជកម្មផងដែរ។

## *កង្វះនូវប្រព័ន្ធចុះបញ្ជីមានប្រសិទ្ធិភាព*

អ្នកដែលត្រូវបានសម្ភាស ១៩ នាក់ បានធ្វើការជាមួយបុគ្គលម្នាក់ធ្វើការនៅក្រសួង ដើម្បីចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនរបស់ខ្លួន។ អ្នកដែលត្រូវបានសម្ភាសភាគច្រើន ហៅបុគ្គលនោះថាជាអ្នករត់ការ (អន្តរការី) ដែលបំពេញបែបបទឯកសារជូនដល់ពួកគេ។ បើទោះជាកំរៃក្រៅផ្លូវការត្រូវតែបង់ក៏ដោយ ពួកគេបានឯកភាពថា វាសមរម្យនឹងបង់ ព្រោះថាការចុះបញ្ជីដោយខ្លួនឯង នឹងធ្វើអោយពួកគេខាតបង់ពេលវេលា និងកំលាំងច្រើន។ អ្នកចូលរួម ១៣ នាក់ បានចុះបញ្ជីក្រុមហ៊ុនរបស់ពួកគេដោយខ្លួនឯង។ អ្នកដែលបានចុះបញ្ជីដោយខ្លួនឯងនោះ បានចែករំលែកថា ពួកគេត្រូវទៅការិយាល័យច្រើនកន្លែងដើម្បីទទួលបាននូវឯកសារពាក់ព័ន្ធ ហើយនៅក្នុងករណីខ្លះ ពួកគេត្រូវបានសុំអោយបង់កំរៃបន្ថែម ប្រសិនបើពួកគេចង់អោយដំណើរការនោះទៅបានលឿន។

អ្នកដែលត្រូវបានសម្ភាសតែ ១៤ នាក់ ប៉ុណ្ណោះ ដែលបានប្រើប្រាស់សេវាកម្មការិយាល័យមេធាវី ឬការិយាល័យគណនេយ្យ សម្រាប់ដំណើរការចុះបញ្ជីពាណិជ្ជកម្ម។ ការប្រើប្រាស់សេវាកម្មវិជ្ជាជីវៈសំរាប់ការចុះបញ្ជី អាចនឹងបង្កើតអោយមានការចំណាយបន្ថែម តែអ្នកដែលត្រូវបានសម្ភាស ដែលបានធ្វើបែបនេះ ហាក់ដូចជាទទួលស្គាល់ទាំងអស់គ្នាថាការធ្វើបែបនេះសមនឹងតម្លៃរបស់វា។

**រូបភាពទី ៥៖ តើអ្នកចូលរួមបទសម្ភាសន៍ បានចុះបញ្ជីក្រុមហ៊ុនរបស់ពួកគេ ដោយរបៀបណា?**




*ក្រៅពីក្រុមហ៊ុនដែលបានចុះបញ្ជីទាំង ៥៤

ប្រព័ន្ធចុះបញ្ជី ដែលមិនមានប្រសិទ្ធិភាព ហើយគួបផ្សំនឹងកង្វះនៃការអនុវត្តច្បាប់ អាចនាំអោយដំណើរការនៃការចុះបញ្ជីសំរាប់ក្រុមហ៊ុនមួយ មានភាពខុសគ្នាយ៉ាងខ្លាំង ដូចដែលបានបង្ហាញក្នុងតារាងទី ៨។

**តារាងទី ៨៖ ពេលវេលាត្រូវការសំរាប់ដំណើរការចុះបញ្ជី**

| រយៈពេល | ចំនួនក្រុមហ៊ុន |
|---|---|
| តិចជាង១សប្តាហ៍ | ៥ |
| ចន្លោះពី ១ ទៅ ២ សប្តាហ៍ | ២ |
| ចន្លោះពី ២ សប្តាហ៍ទៅ ១ ខែ | ៩ |
| ចន្លោះពី១ខែទៅ២ខែ | ១៥ |
| ចន្លោះពី២ខែទៅ៣ខែ | ១១ |
| ច្រើនជាង៣ខែ | ៨ |

## ផលប៉ះពាល់នៃអំពើពុករលួយលើសហគ្រាសធុនតូចនិងមធ្យម

ក្រៅពីភាពជាក់ស្តែងដែលអ្នកត្រូវបានសម្ភាស បានចែករំលែកថាពួកគាត់ធ្លាប់បានបង់ប្រាក់កំរៃក្រៅផ្លូវការក៏ដោយ (បើទោះជាប្រាក់កំរៃនោះតិចយ៉ាងណាក៏ដោយ) ក៏ភាគច្រើននៃអ្នកត្រូវបានសម្ភាស បានគិតថាពួកគាត់មិនបានជួបការអនុវត្តអំពើពុករលួយក្នុងការធ្វើជំនួញរបស់ពួកគេទេ។

អ្នកចូលរួម ៤៧ នាក់ បាននិយាយថា ពួកគេធ្លាប់បានឮ ឬ ធ្លាប់បានឆ្លងកាត់បទពិសោធន៍បញ្ហាអំពើពុករលួយក្នុងជំនួញរបស់ពួកគាត់ តែពួកគាត់ភាគច្រើនមិនមានអារម្មណ៍ស្រួលក្នុងការផ្តល់នូវឧទាហរណ៍ជាក់ស្តែងលើអំពើពុករលួយទេ លើកលែងតែទាក់ទងទៅនឹងអធិការកិច្ច ដូចដែលបានពិភាក្សាខាងលើក្នុងផ្នែកបទសម្ភាសន៍។ អ្នកចូលរួម ៥៧ នាក់ បានឆ្លើយថាអំពើពុករលួយ គឺជាកត្តាខាងក្រៅមួយដែលមានផលប៉ះពាល់ដល់ភាពរីកចម្រើនក្រុមហ៊ុនរបស់ពួកគេ។ ភាពមិនស៊ីគ្នារវាងសំណួរពីនេះ អាចបណ្តាលមកពីកត្តាដែលគេមិនចង់និយាយពីបញ្ហាអំពើពុករលួយ។

វាមានសារៈសំខាន់ណាស់ក្នុងការកត់សម្គាល់ថា បើទោះជាអ្នកចូលរួមបានផ្តល់នូវនិយមន័យពីអំពើពុករលួយ និងកំរៃក្រៅផ្លូវការ បានល្អយ៉ាងណាក៏ដោយ ពួកគេភាគច្រើនមិនអាចយកនិយមន័យនោះទៅអនុវត្តក្នុងជីវិតពិតបាននោះទេ ពោលគឺមានន័យថានៅពេលដែលសួរថាពួកគេធ្លាប់ជួបប្រទះបញ្ហាអំពើពុករលួយក៏អត់ ភាគច្រើនពួកគេឆ្លើយថាអត់ តែបើសួរថាពួកគេធ្លាប់បង់ប្រាក់ "ទឹកតែ" ឬក៏អត់ ពួកគេនឹងអោយចំលើយវិជ្ជមានភ្លាម។

**តារាងទី៩ ៖ ចំនួនអ្នកឆ្លើយតប ដែលមាននូវបទពិសោធន៍ជួបនឹងបញ្ហាអំពើពុករលួយ និងផលប៉ះពាល់លើសហគ្រាសធុនតូចនិងមធ្យម**

| សំណួរ | បាទ/ចាស | ទេ | គ្មានចំលើយ ឬមិនអាចប្រើការបាន |
|---|---|---|---|
| តើក្រុមហ៊ុនរបស់អ្នក ធ្លាប់បានលឺ ឬមានបទពិសោធន៍ទាក់ទងទៅនឹងអំពើពុករលួយ ក្នុងអាជីវកម្មរបស់អ្នកនៅក្នុងប្រទេសកម្ពុជាដែរទេ ? | ៤៧ | ៣១ | ២២ |
| តើអំពើពុករលួយគឺជាកត្តាក្រៅ ដែលបង្អាក់ការរីកចម្រើនរបស់ក្រុមហ៊ុនអ្នកឬទេ ? | ៥៧ | ២៥ | ១៨ |

អ្នកជំនួញស្ត្រីម្នាក់ បានចែករំលែកជាមួយពួកយើងថា គាត់ស្គាល់ម្ចាស់ជំនួញមួយចំនួនដែលមានតូបនៅផ្សារ ហើយដែលត្រូវបានស្នើអោយបង់ពន្ធក្នុងតំលៃមួយដ៏ច្រើនលើសលប់ ហើយគាត់ពិពណ៌នាថា ពាណិជ្ជករមួយចំនួនមិនអាចបន្តអាជីវកម្មរបស់ពួកគាត់បានដោយសារទ្រាំទ្រនឹងកំរៃទាំងនោះបាន។

**តារាងទី១០៖ កំរិតនៃភាពប៉ះពាល់លើជំនួញរបស់ពួកគេ**

អ្នកដែលត្រូវបានសម្ភាស បានកំណត់កម្រិតប៉ះពាល់របស់អំពើពុករលួយមកលើក្រុមហ៊ុនរបស់ពួកគេដូចខាងក្រោម។

| | ១ ផលប៉ះពាល់តិចបំផុត | ២ | ៣ | ៤ | ៥ ផលប៉ះពាល់ធំ | គ្មានមតិយោបល់ | គ្មានព័ត៌មាន |
|---|---|---|---|---|---|---|---|
| %នៃក្រុមហ៊ុន | ៣% | ៣% | ១៨% | ១៥% | ១៦% | ១៦% | ២៩% |

នៅក្នុងរយៈពេលវែង អំពើពុករលួយអាចមានផលប៉ពាល់យ៉ាងធ្ងន់ធ្ងរលើសហគ្រាសធុនតូច និងមធ្យម។ ក្រុមហ៊ុន ដែលចង់ស្ថិតនៅវិស័យក្រៅផ្លូវការ ហើយនិងក្រុមហ៊ុនដែលបានបង់ការសូកប៉ាន់តាំងពីការបង្កើតមក បើទោះជាទំហំកំរៃដែលត្រូវបង់នោះតូចយ៉ាងណាក៏ដោយ ក៏នឹងជួបការលំបាកក្នុងការក្លាយខ្លួនជាក្រុមហ៊ុនអនុលោមតាមច្បាប់ ដើម្បីរីកធំធាត់ជាងមុន។ លើសពីនេះទៅទៀត វានឹងមិនមានលទ្ធភាពតែម្តងសំរាប់ក្រុមហ៊ុនដែលមិនអនុលោមតាមច្បាប់ ក្នុងការទទួលបានឥណទាន ឬដើមទុន ឬដើមទុនវិនិយោគពីក្រៅប្រទេស។ ការនេះអាចជាឧបសគ្គដ៏ធំលើការលូតលាស់សេដ្ឋកិច្ច និង ការប្រកួតប្រជែងរបស់កម្ពុជា ជាពិសេសក្រោយសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។

## សុច្ចរិតភាព និងសីលធម៌ធុរកិច្ច

ការកំណត់និយមន័យអោយសញ្ញាណ សុច្ចរិតភាពធុរកិច្ច ឬធុរកិច្ចស្អាតស្អំ មានភាពលំបាកស្មុគស្មាញសំរាប់អ្នកដែលត្រូវបានសម្ភាសភាគច្រើន។

ផ្អែកតាមបទសម្ភាសន៍ វាមានភាពច្បាស់ណាស់ដែលថាសញ្ញាណនៃសុច្ចរិតភាពធុរកិច្ច ឬធុរកិច្ចស្អាតស្អំមិនទាន់ត្រូវបានយល់ដឹងក្នុងចំណោមនាយកប្រតិបត្តិខ្មែរនោះទេ។ ជាក់ស្តែង អ្នកចូលរួម ៦៣ មិនធ្លាប់ធ្វើការពិភាក្សាលើសញ្ញាណនេះក្នុងក្រុមហ៊ុនរបស់ខ្លួនឡើយ។ ក្នុងចំណោមចំលើយដែលស្រដៀងគ្នាបំផុត

នោះ អ្នកចូលរួម ២៣ នាក់ បាននិយាយថា ធុរកិច្ចស្អាតស្អំគឺជាធុរកិច្ចមួយដែលធ្វើឡើងទៅតាមច្បាប់ ហើយ៦នាក់ទៀតបានអោយនិយមន័យសុច្ចរិតភាពធុរកិច្ចថាជាធុរកិច្ចមួយដែលមិនមានភាពពុករលួយ ព្រមទាំង១៩នាក់ទៀត មិនបានដឹងថាធុរកិច្ចស្អាតស្អំជាអ្វីនោះទេ ឬក៏មិនចង់ឆ្លើយតែម្តង។ អ្នកដែលត្រូវបានសម្ភាសមួយចំនួន ក៏បាននិយាយដែរថា ធុរកិច្ចស្អាតស្អំ គឺជាអ្វីដែលពួកគេកំពុងតែអនុវត្តក្នុងសហគ្រាសរបស់ពួកគេ។

ខាងក្រោមនេះគឺជាវិធានការដែលមានចែងក្នុងច្បាប់របស់កម្ពុជា ដើម្បីសំរេចបាននូវសុច្ចរិតភាពធុរកិច្ច។

## *បទល្មើស*

នៅក្រោមច្បាប់របស់កម្ពុជា ការសូកប៉ាន់ជាអំពើខុសច្បាប់ ហើយក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បង្កើតអោយមានបទល្មើសទាំងសំរាប់រូបវន្តបុគ្គល និងនីតិបុគ្គល។ ភាគច្រើននៃបទល្មើសសូកប៉ាន់ ដែលត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ គឺទាក់ទងនឹងរូបវន្តបុគ្គល។ ទោសទាំងនោះ ត្រូវបានចែងក្នុងមាត្រាដូចតទៅនេះ៖ មាត្រា ២៧៨ (ការទាមទារ ឬការទទួល ការសូកប៉ាន់ដោយនិយោជិតម្នាក់) មាត្រា ២៧៩ (ការសូកប៉ាន់ទៅនិយោជិត) មាត្រា ២៨០ (ការសូកប៉ាន់ដោយអភិបាល) មាត្រា ២៨១ (ការប៉ុនប៉ងក្នុងការអោយសំណូក) មត្រា ២៨២ (ទណ្ឌកម្មបន្ថែមសំរាប់ការសូកប៉ាន់) និង មាត្រា ៣០៥ (បទបរិហារកេរ្តិ៍)។

ក្រោមមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នីតិបុគ្គលដូចជាក្រុមហ៊ុន អាចទទួលខុសត្រូវលើបទព្រហ្មទណ្ឌចំពោះសកម្មភាពរបស់តំណាងរបស់ខ្លួន ដែលបំពេញការងារក្នុងនាមរបស់ខ្លួន។ និយាយអោយច្បាស់ទៅ នីតិបុគ្គលអាចនឹងត្រូវផ្តន្ទាទោសព្រហ្មទណ្ឌពីបទរំលោភបំពានលើមាត្រា ២៧៩ (ការអោយសំណូកទៅនិយោជិត)។

មាត្រា ៤៦ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានចែងថា ក្រុមហ៊ុននឹងទទួលការផ្តន្ទាទោសសំរាប់ការទទួលផលបន្តពីបទល្មើសពុករលួយ ដែលត្រូវបានកំណត់និយមន័យថាជាអំពើលាក់បំបាំង រក្សាទុក ឬជញ្ជូនរបស់អ្វីមួយ ដោយដឹងថារបស់នោះជាផលបន្តពីបទល្មើសពុករលួយ។ ដូចនេះក្រុមហ៊ុនមួយអាចនឹងទទួលខុសត្រូវ សម្រាប់សកម្មភាពរបស់និយោជិត បុត្រសម្ព័ន្ធ ឬភ្នាក់ងាររបស់ខ្លួន ប្រសិនបើមានករណីទទួលផលបន្តពីបទល្មើសពុករលួយ ដែលបានហាមឃាត់ដោយច្បាប់ប្រឆាំងអំពើពុករលួយ។ លើសជាងនេះទៅទៀត យោងតាមសញ្ញាណទូទៅនៃច្បាប់សំរាប់ភ្នាក់ងារនៅក្នុងប្រទេសកម្ពុជា គ្រឹះស្ថានដើមត្រូវទទួលខុសត្រូវសម្រាប់អ្វីៗដែលទទួលបានការអនុញ្ញាតរបស់ភ្នាក់ងារខ្លួន។ ម៉្យាងទៀតក្រោមមាត្រា៣៦៩ នៃក្រមរដ្ឋប្បវេណី គ្រឹះស្ថានដើម ត្រូវទទួលខុសត្រូវសម្រាប់អ្វីៗដែលមិនទទួលបាន

ការអនុញ្ញាតរបស់ភ្នាក់ងារខ្លួន ប្រសិនបើស្ថាប័នដើមបានផ្តល់សច្ចានុម័តលើអ្វីៗទាំងនោះ។ ដូចនេះ ការទទួលយកផលលាភពីអំពើពុកលុយ អាចអោយក្រុមហ៊ុនមួយទទួលខុសត្រូវក្រោមក្រមរដ្ឋប្បវេណី ផងដែរ។ ពុំទាន់មានច្បាប់ក្នុងប្រទេសកម្ពុជាមួយណា ដែលចែងជាពិសេសពីការទទួលខុសត្រូវរបស់ អភិបាលនោះទេ។ ប៉ុន្តែ មាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ បានចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការរំលោភលើទំនុកចិត្ត។ ការរំលោភលើទំនុកចិត្ត ត្រូវបានអោយនិយមន័យថា ជាអំពើគៃបំបាត់ មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ដែលគេបានប្រគល់ឱ្យ និងរបស់ដែលទទួលបាន ដោយមានលក្ខខណ្ឌ ប្រគល់ សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។ លើសពីនេះទៅទៀត អភិបាលជនជាតិបរទេស ឬសហគ្រាសធុនតូចនិងមធ្យមរបស់បរទេស ដែលកំពុងតែធ្វើការ និងដំណើរការក្នុងប្រទេសកម្ពុជា ក៏ត្រូវគោរពច្បាប់នីតិវិធីក្នុងប្រទេសរបស់ពួកគេ ផងដែរ។

ច្រើនជាងនេះទៅទៀត ទាំងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ក៏អាចយក ទៅប្រើប្រាស់លើវិស័យសាធារណៈផងដែរ។ មាត្រា ៣០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានអោយ និយមន័យដល់ "មន្ត្រីសាធារណៈ" ថាជា៖ (ក) បុគ្គល ដែលត្រូវតែងតាំងដោយលិខិតបទដ្ឋានគតិយុត្តិ ទោះជាបណ្តោះអាសន្នឬអចិន្ត្រៃយ៍ក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិត ពីឋានៈ អាយុ និងការបម្រើការនៅក្នុង ស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ ឬតុលាការដ៏ដោយ (ខ)បុគ្គល ឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ឬស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានអោយនិយមន័យលើមន្ត្រីសាធារណៈ ថាជាបុគ្គល ដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ ដែលត្រូវបានតែងតាំង ដោយលិខិតគតិយុត្តិ ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ ឈ្នួលក្តី ដោយមិនគិតពីឋានៈ ឬអាយុរបស់បុគ្គលនោះឡើយ។ ការនេះ ក៏អនុវត្តផងដែរចំពោះ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ក៏បានអោយនិយមន័យដល់មន្ត្រីសាធារណៈបរទេស និងថៅក្រម ផងដែរ។ មន្ត្រីសាធារណៈបរទេស ត្រូវបានអោយនិយមន័យក្នុងមាត្រា៤ ថា ជាបុគ្គលដែលកាន់តំណែង ក្នុងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ របស់ប្រទេសក្រៅ ទោះជាត្រូវបានតែងតាំងឬ បោះឆ្នោតក៏ដោយ និងជនបរទេសណា ដែលអនុវត្តមុខងារសាធារណៈសម្រាប់ប្រទេសក្រៅណាមួយ

រួមមានទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ។ ចៅក្រម ត្រូវបានអោយនិយមន័យថាជា ចៅក្រមអាសនៈ និង ចៅក្រមអយ្យការ។

ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មានអានុភាពអនុវត្តក្រៅដែនដី ដោយផ្អែកលើ សញ្ជាតិ បទល្មើសប្រឆាំងនឹង បុគ្គលសញ្ជាតិកម្ពុជា ហើយនឹងបទល្មើសដែលធ្វើឡើងប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា ឧទាហរណ៍ ដូចជាការក្លែងបន្លំក្រដាសប្រាក់ជាដើម។

ពុំមានបទប្បញ្ញត្តិណាមួយជាក់លាក់ ទាក់ទងនឹងការការពារនៃការអនុលោមតាមច្បាប់ នៅក្នុងច្បាប់របស់ ប្រទេសកម្ពុជានោះទេ។ យ៉ាងណាមិញ ជំពូក២នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលចែងគ្រប់គ្រងលើ មូលហេតុនៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬការបន្ថយនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ផ្តល់ នូវកាលៈទេសៈ ដែលរូបវន្តបុគ្គលម្នាក់អាចកាត់បន្ថយនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនបាន។ កាលៈទេសៈទាំងនោះ អាចជាវិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ការការពារខ្លួន ការការពារ ដោយភាពចាំបាច់ និងការបង្ខិតបង្ខំ។ ច្រើនជាងនេះ គោលការណ៍ “គ្មានទោសប្រសិនបើគ្មានចេតនាបង្ក” ត្រូវបានចែកក្រោមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ក៏អាចមោឃៈ ឬ សម្រាលការទទួលខុសត្រូវ ព្រហ្មទណ្ឌផងដែរ។

ក្រមព្រហ្មទណ្ឌ និង ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ហាមឃាត់យ៉ាងតឹងរ៉ឹងចំពោះ ការបង់ប្រាក់ថ្លៃរត់ការដល់មន្ត្រីសាធារណៈ (បរទេសឬក្នុងស្រុក) ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ។ ក្រោមច្បាប់កម្ពុជា ការជូនអំណោយ មិនថាស្ថិតក្នុងទំហំទឹកប្រាក់ប៉ុណ្ណានោះទេ សម្រាប់គោលដៅអំពើ ពុករលួយ ត្រូវបានហាមឃាត់ជាដាច់ខាត។ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អោយនិយមន័យ អំណោយថាជាទ្រព្យសម្បត្តិ ឬ ជាសេវាកម្ម ដែលបានផ្តល់អោយឬសំរាប់ផលប្រយោជន៍របស់បុគ្គល ណាម្នាក់ ដែលមិនមែនជាអំណោយតាមទំនៀមទំលាប់ ឬប្រពៃណី។ លើពីនេះ ច្បាប់ស្តីពីការប្រឆាំងអំពើ ពុករលួយ ក៏បានរួមបញ្ចូលនូវបញ្ញត្តិជាច្រើនពីក្រមព្រហ្មទណ្ឌ ដែលធ្វើការហាមឃាត់អោយអំណោយទៅ កាន់មន្ត្រីរដ្ឋាភិបាល ដើម្បីជះឥទ្ធិពលលើការបំពេញការងាររបស់ពួកគេ។ ដូចនេះហើយ គោលបំណងនៃ ការជូនអំណោយទៅកាន់មន្ត្រីរដ្ឋាភិបាល មានសារៈសំខាន់ជាងតម្លៃនៃអំណោយនោះ។

ទំនៀមទំលាប់នៃការជូនអំណោយ គឺជារឿងទូទៅនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានចាត់ទុកថាអាច ទទួលយកបានក្នុងកំរិតជាក់លាក់មួយ។ វាក៏ជារឿងទូទៅផងដែរក្នុងការអញ្ជើញមន្ត្រីរដ្ឋាភិបាលទៅ បរិភោគអាហារល្ងាច ឬពិធីជប់លៀង ជាពិសេសការធ្វើពិធីជប់លៀងនៅថ្ងៃឈប់សំរាក ឬពីធីបុណ្យទាន ណាមួយ។ ទាក់ទងនឹងការអោយទ្រព្យសម្បត្តិផ្ទាល់ខ្លួន វាជារឿងសាមញ្ញសំរាប់ជនបរទេសក្នុងការអោយ ជាអំណោយពីប្រទេសពួកគេរៀងៗខ្លួន ឬ ប្រជាជនកម្ពុជាជូនអំណោយក្រោយពីត្រឡប់មកពីដំណើរ

ទស្សនកិច្ចនៅបរទេស។ ក្នុងករណីនេះ អង្គភាពប្រឆាំងអំពើពុករលួយបានរៀបចំនូវការណែនាំសំរាប់មន្ត្រីសាធារណៈរបស់ខ្លួន។

### *ទោសពិន័យ*

ខាងក្រោមនេះជាទោសពិន័យមួយចំនួនដែលត្រូវបានបង្កើតឡើងដោយអង្គភាពប្រឆាំងអំពើពុករលួយ និងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

ទាំងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងក្រមព្រហ្មទណ្ឌ ធ្វើការផ្តន្ទាទោស លើការទទួលយកការសូកប៉ាន់ ដោយមន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ ដោយការជាប់ពន្ធនាគារពី ៧ ទៅ ១៥ឆ្នាំ។

ក្រោមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការរំលោភបំពានដោយប្រើអំណាច កើតឡើងនូវពេលមន្ត្រីសាធារណៈម្នាក់ ក្នុងពេលបំពេញមុខនាទី មានបំណងចង់កេងផលចំនេខុសច្បាប់ណាមួយ។ ការរំលោភបំពានដោយអំណាចនេះ ជាបទល្មើសដែលអាចផ្តន្ទាទោសជាប់ពន្ធនាគារពី ២ ដល់ ៥ឆ្នាំ និង ការពិន័យជាទឹកប្រាក់ផងដែរ។ ប្រសិនបើមានភាពធ្ងន់ធ្ងរជាងនេះ គឺអាចត្រូវជាប់ពន្ធនាគារពី ៥ ទៅ ១០ ឆ្នាំ។

ការមានបានដោយមិនស្របច្បាប់ គឺអាចផ្តន្ទាទោសជាមួយនឹងការដកហូតទ្រព្យសម្បត្តិដែលមិនអាចពន្យល់ពីប្រភពបាន។ ប្រសិនបើមនុស្សម្នាក់ ត្រូវបានទាមទារអោយប្រកាសអំពីទ្រព្យសម្បត្តិរបស់ខ្លួនក្រោមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ តែមិនអាចធ្វើបាននោះ ជននោះអាចនឹងត្រូវផ្តន្ទាទោសពី ១ ខែ ទៅ១ ឆ្នាំ ជាមួយនឹងទឹកប្រាក់ពិន័យផងដែរ។

បទល្មើសពុករលួយតូចតាច អាចត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដោយជាប់ពន្ធនាគារ ពី ១ សប្តាហ៍ ទៅ ៥ឆ្នាំ ។

ក្រោមក្រមព្រហ្មទណ្ឌ ការសូកប៉ាន់ទៅមន្ត្រីសាធារណៈ អាចត្រូវផ្តន្ទាទោសអោយជាប់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ។

ការអោយសំណូកទៅនិយោជិត ឬ និយោជិតដែលស្នើ ឬ ទទួលយកសំណូក ត្រូវមានទោសជាប់ពន្ធនាគារពី ៦ ខែ ដល់ ២ឆ្នាំ ព្រមទាំងប្រាក់ពិន័យផងដែរ។ ការស៊ីសំណូករបស់ចៅក្រម ត្រូវជាប់ពន្ធនាគារពី ៧ ទៅ ១០ឆ្នាំ ហើយការស៊ីសំណូករបស់សាក្សី អាចត្រូវផ្តន្ទាទោសពី ៥ ទៅ ១០ ឆ្នាំ។

### *ការរាយការណ៍ព័ត៌មាន*

ប្រទេសកម្ពុជាមិនទាន់មានច្បាប់ជាក់ណាមួយ ស្ដីពីការរាយការណ៍ព័ត៌មាននៅឡើយទេ ហើយច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយផ្ដល់នូវការការពារដែលនៅមានកំរិតនៅឡើយសំរាប់អ្នករាយការណ៍ព័ត៌មាន។ ក្រោមមាត្រា ១៣ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយ មានតួនាទីក្នុងការអនុវត្តវិធានការដើម្បីធានានូវសុវត្ថិភាពរបស់អ្នករាយការណ៍ព័ត៌មាន។ ប៉ុន្តែ ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ បានចែងក្នុងមាត្រា ៤១ ថា ពាក្យបណ្ដឹងបរិហារកេរ្តិ៍ ឬមិនពិត លើអំពើពុករលួយ ដែលដាក់ប្ដឹងទៅអង្គភាពប្រឆាំងអំពើពុករលួយ ឬទៅចៅក្រម ដែលនាំអោយមានការស៊ើបអង្កេតដោយឥតប្រយោជន៍ នឹងត្រូវផ្ដន្ទាទោសអោយជាប់ពន្ធនាគារពី ១ខែ ទៅ ៦ខែ ជាមួយនឹងពិន័យចាប់ពី ១លានរៀល ទៅ ១០លានរៀល (ប្រហែល ២៥០ ទៅ២៥០០ ដុល្លារសហរដ្ឋអាមេរិច)។ មាត្រា ៣០៥ បានចាត់ទុកការបរិហារកេរ្តិ៍ថា ជាការចោទប្រកាន់ ឬការដាក់បន្ទុកណាមួយ ដែលធ្វើឡើងក្នុងគោលបំណងមិនល្អ ដើម្បីចង់បង្អាប់បង្ខូចកេរ្តិ៍ឈ្មោះ ឬកិត្តិនាមរបស់បុគ្គលមួយរូប ឬស្ថាប័នមួយ ហើយការពិន័យជាសាច់ប្រាក់សម្រាប់ការបរិហារនេះ មានចាប់ពី ១សែនរៀល ទៅ ១០លានរៀល (ប្រហែល ២៥០០ ដុល្លារសហរដ្ឋអាមេរិច)។

## គ. វិធីសាស្ត្រប្រើដោយសហគ្រាសធុនតូចនិងមធ្យម ក្នុងការតទល់នឹងអំពើពុករលួយ

នៅពេលដែលត្រូវបានសួរថាតើសហគ្រាសធុនតូច និងមធ្យម អាចតទល់នឹងអំពើពុករលួយយ៉ាងដូចម្ដេចនោះ ភាគច្រើននៃអ្នកដែលត្រូវបានសម្ភាស មិនបានផ្ដល់មតិយោបល់អ្វីនោះឡើយ។ ពួកគាត់ជាច្រើនបានឆ្លើយថា គាត់មិនអាចធ្វើអ្វីបានទេ ឬនិយាយយ៉ាងសាមញ្ញថា មិនដែលធ្លាប់គិតពីរឿងនេះពីមុនមកទេ។ លើសពីនេះទៅទៀត មានតែអ្នកចូលរួមមួយចំនួនតែប៉ុណ្ណោះ ដែលនិយាយថា ភាគីពាក់ព័ន្ធទាំងអស់ ត្រូវតែសហការគ្នា។

### ការអនុម័តនូវវិធានផ្ទៃក្នុង

ភាគច្រើននៃអ្នកដែលត្រូវបានសម្ភាស គឺជាអ្នកដែលទទួលខុសក្នុងការតទល់ជាមួយនឹងអធិការកិច្ច និងបញ្ហាពុករលួយផ្សេងៗទៀតនៅក្នុងសហគ្រាសធុនតូចនិងមធ្យមរបស់ពួកគេ។ អ្នកដែលត្រូវបានសម្ភាស

ចំនួន ២៦ នាក់ មាននូវវិធី ឬវិធានក្នុងការទប់ទល់នឹងអំពើពុករលួយ ដែលភាគច្រើនជាការរាយការណ៍របស់និយោជិតទៅម្ចាស់សហគ្រាសផ្ទាល់ ឬចរចារតំលៃជាមួយនឹងអធិការ ឬមន្ត្រីរដ្ឋាភិបាល។

ការមាននូវក្រមប្រតិបត្តិជាមួយនឹងវិធានការជាក់លាក់លើរបៀបតទល់នឹងអំពើពុករលួយ គឺជាមធ្យោបាយដ៏ល្អមួយក្នុងការបង្ការមិនអោយមានអំពើពុករលួយកើតមានក្នុងក្រុមហ៊ុន។ តែគួរអោយសោកស្តាយ ដែលក្នុងចំណោមអ្នកដែលត្រូវបានសម្ភាសទាំង ១០០ នាក់ មានតែ ២៥ នាក់ ប៉ុណ្ណោះ ដែលមាននូវក្រមប្រតិបត្តិជាលាយលក្ខណ៍អក្សរ។ អ្នកដែលត្រូវបានសម្ភាសខ្លះ បានលើកយកនូវលក្ខខណ្ឌបំពេញការងារដែលនិយោជិតរបស់ពួកគាត់បានចុះហត្ថលេខា ដែលនៅក្នុងលក្ខខណ្ឌនោះពួកគេមានវិធានការខ្លះចំពោះការអនុវត្តនៃអំពើពុករលួយ ជាពិសេសគឺសំរាប់គ្រូបង្រៀនក្នុងសាលាឯកជនតែម្តង។ អ្នកចូលរួមតែ ១២ នាក់ប៉ុណ្ណោះ ដែលមាននូវក្រមប្រតិបត្តិ ឬក្រមសីលធម៌ ដែលមានចែងពីអំពើពុករលួយ។ អ្នកចូលរួម ៤៨ នាក់ មិនមាននូវក្រមប្រតិបត្តិ ហើយ ២៧ នាក់ទៀតមិនបានឆ្លើយសំណួរដែលបានសួរនោះទេ។

ការមាននូវក្រមប្រតិបត្តិ ត្រូវបានយល់ឃើញដោយអ្នកដែលត្រូវបានសម្ភាសជាច្រើនថា មិនមែនជាវិធីល្អដោយសារហេតុផលជាច្រើនដូចជាៈ នាយកប្រតិបត្តិ ឬនាយកគ្រប់គ្រងទូទៅ ច្រើនតែជាបុគ្គលដែលទទួលខុសត្រូវក្នុងការតទល់នឹងការទាមទារពីអំពើពុករលួយ ហើយពេលដែលជួបបញ្ហា និយោជិតតែងតែរុញទៅអោយនាយកប្រតិបត្តិ ឬនាយកគ្រប់គ្រងទូទៅរបស់ខ្លួន ដែលជាហេតុធ្វើអោយមានភាពមិនចាំបាច់ក្នុងការមានក្រមប្រតិបត្តិដែលចែងពីអំពើពុករលួយ (នេះបើយោងទៅតាមអ្នកចូលរួមជាច្រើន)។ វាហាក់បីដូចជាច្បាស់លាស់ ដែលភាគច្រើននៃនិយោជិតបំរើការក្នុងសហគ្រាសធុនតូចនិងមធ្យម ដែលត្រូវបានសម្ភាស មិនដោះស្រាយបញ្ហាអំពើពុករលួយដោយខ្លួនឯងទេ ហើយក៏មិនមានសមត្ថភាពអាចដោះស្រាយបញ្ហានេះបានដែរ។

# ការប្រើប្រាស់ស្ថាប័នសាធារណៈ

### *អង្គភាពប្រឆាំងអំពើពុករលួយ*

រដ្ឋាភិបាលបានបង្កើតនូវវិធានច្បាស់លាស់នានាដើម្បីប្រឆាំងនឹងអំពើពុករលួយ ដោយក្នុងនោះរួមមានច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និង ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ (ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ២០១០)។ បើទោះជាពុំមានអ្នកដែលត្រូវបានសម្ភាសណាមួយ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយក៏ដោយ ក៏វាមានភាពចាំបាច់ក្នុងការបញ្ជាក់ថា រហូតដក់ថ្ងៃ ២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រុមហ៊ុនចំនួន ១៧ បានចុះហត្ថលេខាលើ

អនុស្សរណៈយោគយល់ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដោយក្នុងនោះរួមមានក្រុមហ៊ុនកូកាកូឡា ដែលជាក្រុមហ៊ុនចុះហត្ថលេខាដំបូងគេបង្អស់ក្នុងឆ្នាំ ២០១៣។ [២៧]

គោលបំណងនៃអនុស្សរណៈយោគយល់ទាំងអស់នេះ ត្រូវបានបកស្រាយថា ដើម្បីប្រឆាំងនឹងអំពើពុករលួយ និងកសាងនូវបរិស្ថានតម្លាភាព ដែលក្រុមហ៊ុនទាំងអស់អាចវិវត្ត។ ក្នុងអនុស្សរណៈយោគយល់ អង្គភាពប្រឆាំងអំពើពុករលួយ និង ក្រុមហ៊ុននានា បានយល់ព្រម នៅក្នុងចំណោមធាតុផ្សេងៗ ថាៈ

១. ពួកគេប្ដេជ្ញានឹងមានភាពស្អាតស្អំ តម្លាភាព និង គោរពតាមច្បាប់របស់ប្រទេសកម្ពុជា។
២. ពួកគេបដិសេធរាល់សំណូក និង ណែនាំអោយសមាជិកបុគ្គលិករបស់ខ្លួនជៀសវាងសំណូក។
៣. ពួកគេត្រូវចាត់វិធានការដោយប្រយ័ត្ន និង ផ្ដល់ដំណឹងដល់អង្គភាពប្រឆាំងអំពើពុករលួយ ប្រសិនបើគេជួបប្រទះនូវបញ្ហាអំពើពុករលួយ។
៤. អង្គភាពប្រឆាំងអំពើពុករលួយត្រូវរក្សាទុកជាសម្ងាត់នូវប្រភព និងភស្តុតាងទាំងអស់ ដែលបានផ្ដល់ដោយភាគីចុះហត្ថលេខា ហើយអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវមានបំណងបើកការស៊ើបអង្កេតពេលដែលត្រូវបានបង្ហាញនូវមូលហេតុគ្រប់គ្រាន់។ ហើយ
៥. បើអាចទៅរួច អង្គភាពប្រឆាំងអំពើពុករលួយ និង ក្រុមហ៊ុន យល់ព្រមក្នុងការបង្កើតខ្សែទូរស័ព្ទទំនាក់ទំនងរហ័សមួយសំរាប់ការទាក់ទងសម្ងាត់ និង បន្ទាន់។

អ្នកចូលរួម ៧៨ នាក់បានឆ្លើយថា ពួកគាត់ធ្លាប់ឮអំពីអង្គភាពប្រឆាំងអំពើពុករលួយដែរ (តាមរយៈកាសែត វិទ្យុ និងតាមរយៈបណ្ដាញទំនាក់ទំនងសង្គម) ហើយ៩នាក់និយាយថាពួកគាត់មិនធ្លាប់បានឮពីអង្គភាពប្រឆាំងអំពើពុករលួយទាល់តែសោះ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកចូលរួមមួយចំនួនធំ មានការយល់ដឹងនៅមានកំរិតនៅឡើយពីអង្គភាពប្រឆាំងអំពើពុករលួយ (អ្នកឆ្លើយតប ៤១ បានអោយកំរិត ពី ១ ទៅ ២ ក្នុងចំណោមកំរិត ៥ ដែល ១ បញ្ជាក់ថាមានការយល់ដឹងតិចបំផុត ហើយ ៥ គឺមានការយល់ដឹងច្រើន)។ ច្រើនជាងនេះទៅទៀត អ្នកចូលរួមតែ ៣២ នាក់ប៉ុណ្ណោះ ដែលបាននិយាយថា ពួកគេនឹងប្ដឹងទៅអង្គភាពប្រឆាំងអំពើពុករលួយ ប្រសិនបើពួកគេជួបប្រទះបញ្ហាអំពើពុករលួយធំណាមួយ។ ភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់អង្គភាពប្រឆាំងអំពើពុករលួយនេះ គឺអាចដោយសារការការពារនៅមានកំរិតទាបនៅ

---

[២៧] អត្ថបទកាសែត the Cambodia Herald (ឌឹខេមបូឌា ហេរល់), អាចស្វែងរកបាននៅលើគេហទំព័រ http://www.thecambodiaherald.com/cambodia/anti-corruption-unit-nine-companies-sign-mou-to-fight-corruption-8224 [បានចូលស្រាវជ្រាវនៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៥]។ សូមមើលផងដែរ http://www.phnompenhpost.com/business/five-firms-sign-acu [[បានចូលស្រាវជ្រាវនៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៤] និង http://www.phnompenhpost.com/anti-corruption-unit-talks-business-association [បានចូលស្រាវជ្រាវនៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥]។

ឡើយសម្រាប់ដើមបណ្តឹង បើយោងទៅតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដូចដែលបានបកស្រាយក្នុងផ្នែកនៃការវាយការណ៍ព័ត៌មានខាងលើ។ ម៉្យាងទៀត ពុំមានច្បាប់ណាទាក់ទងទៅនឹងភាពឯកជនឬការរក្សាការសម្ងាត់នៃទិន្នន័យក្នុងប្រទេសកម្ពុជានោះទេ។ អង្គភាពប្រឆាំងអំពើពុករលួយ ច្រើនតែបង្ហោះផ្សាយតាមគេហទំព័ររបស់ខ្លួននូវឈ្មោះរបស់ដើមបណ្តឹង និងជនជាប់ចោទ ដែលអាចបណ្តាលអោយមានព្យសនកម្មផ្ទាល់ខ្លួន។ កង្វះខាតនៃភាពជឿជាក់ក្នុងស្ថាប័ននេះផ្ទាល់ គឺជាចំនុចមួយទៀត ដែលធ្វើអោយអ្នកគ្រប់គ្នាមិនចង់ប្រើប្រាស់អង្គភាពប្រឆាំងអំពើពុករលួយ ដែលនិយោជិតរបស់អង្គភាពនេះ ទើបតែត្រូវបានចោទប្រកាន់ពីអំពើពុករលួយនាពេលថ្មីៗនេះដែរ។

ក្នុងចំណោមអ្នកចូលរួមទាំងអស់ ៣៧នាក់បាននិយាយថា ពួកគេបានឃើញនូវការកែប្រែវិជ្ជមានក្នុងបរិស្ថានធុរកិច្ចចាប់តាំងពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយមក តែ២២នាក់ទៀតថាពុំបានឃើញអ្វីខុសប្លែកនោះទេ ហើយអ្នកផ្សេងទៀតមិនឆ្លើយ ឬ មិនស្ថិតក្នុងតួនាទីមួយដែលអាចឆ្លើយសំណួរនេះបានទេ។

## *ស្ថាប័នតុលាការ*

នាយកប្រតិបត្តិជាច្រើនដែលត្រូវបានសម្ភាសសំរាប់ការសិក្សាស្រាវជ្រាវនេះ មិនមានភាពជឿជាក់លើប្រព័ន្ធតុលាការនោះទេ ខណៈដែលអ្នកដែលត្រូវបានសម្ភាសចំនួន ៣៤ នាក់បានឆ្លើយថា ពួកគាត់នឹងប្រើប្រព័ន្ធតុលការប្រសិនបើជួបបញ្ហាអំពើពុករលួយ។ ការយល់ឃើញបែបនេះ គឺស្របនឹងរបាយការណ៍ខ្លះដូចជាការវាយតម្លៃលើសុច្ចរិតភាពថ្នាក់ជាតិរបស់អង្គការតម្លាភាពកម្ពុជា [២៨] ដែលបានបញ្ជាក់ថាប្រព័ន្ធតុលាការជាអង្គភាពដែលមានអំពើពុករលួយខ្លាំងជាងគេបំផុតក្នុងប្រទេសកម្ពុជា។

## *ការិយាល័យច្រកចេញចូលតែមួយ*

ការិយាល័យច្រកចេញចូលតែមួយ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៩ ក្នុងខេត្តបាត់ដំបង និង សៀមរាប ហើយមាននូវ “ការិយាល័យទោលមួយសំរាប់ផ្តល់នូវសេវាកម្មរដ្ឋបាលទូទៅ ដែលជាតំរូវការពីប្រជាជន

---

[២៨] National Integrity System Assessment (ការវាយតម្លៃលើប្រព័ន្ធសុច្ចរឹតភាពថ្នាក់ជាតិ), អង្គការតម្លាភាពកម្ពុជា, អាចចូលមើលលើ http://ticambodia.org/index.php/whatwedo/publication/nisa-report-2014 [ចូលស្រាវជ្រាវនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៥]។

និងពាណិជ្ជកម្មធុនតូចនៅក្នុងកម្រិតតំបន់”។.[២៩] “អ្វីដែលធ្វើអោយការិយាល័យច្រកចេញចូលតែមួយខុសប្លែកពីគេក្នុងប្រទេសកម្ពុជានោះគឺដោយសារតែតំលៃនៃសេវាកម្មផ្សេងៗ មានតម្លាភាព ហើយត្រូវបានបង្ហាញជូនសាធារណៈជនអោយបានដឹងនៅក្នុងការិយាល័យច្រកចេញចូលតែមួយ ហើយសេវាកម្មត្រូវបានផ្តល់ជូនក្នុងលក្ខណៈទាន់ពេលវេលា និងសង្គតភាព”។[៣០] ក្នុងឆ្នាំ ២០១៣ ការិយាល័យច្រកចេញចូលតែមួយ មានការិយាល័យចំនួន ៨ក្នុងទីក្រុងភ្នំពេញ និង ២ ទៀតនឹងត្រូវបានបើកនៅឆ្នាំក្រោយ។[៣១] អ្នកដែលត្រូវបានសម្ភាសភាគច្រើន បូករួមទាំងអ្នកដែលមានទីតាំងក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប មិនដែលបានឮពីសេវានេះនៅឡើយទេ។

## *លេខទូរសព្ទទំនាក់ទំនងរហ័សប្រឆាំងអំពើពុករលួយ*

ចំណេះដឹងនៃអ្នកចូលរួមអំពីវិធានផ្សេងៗ ដែលត្រូវបានដាក់ចេញដោយរដ្ឋាភិបាល សំរាប់ប្រឆាំងអំពើពុករលួយ គឺនៅមានកំរិតនៅឡើយ។ អ្នកចូលរួមតែ ២០ នាក់ ប៉ុណ្ណោះ ដែលបាននិយាយថា ពួកគេ ធ្លាប់ឮពីការណែនាំស្តីពីការប្រឆាំងការសូកប៉ាន់ តែពុំមាននរណាម្នាក់អាចនិយាយអោយបានច្បាស់លម្អិតពីអ្វីដែលពួកគេដឹងនោះទេ។

៣៣ នាក់ នៃអ្នកដែលត្រូវបានសម្ភាសទាំងអស់ បានឮនូវលេខទូរស័ព្ទទំនាក់ទំនងរហ័សប្រឆាំងអំពើពុករលួយ ហើយនាពេលពួកគាត់ទទួលបានការពន្យល់ថាវាជាអ្វីនោះ មានតែ ៣៣នាក់ប៉ុណ្ណោះដែលឆ្លើយថាពួកគាត់នឹងទូរស័ព្ទទៅលេខនោះប្រសិនបើចាំបាច់ ខណៈដែល៣៤នាក់ទៀតឆ្លើយថាពួកគាត់នឹងមិនទូរស័ព្ទទៅនោះទេ។

---

[២៩] គេហទំព័រការិយាល័យច្រកចេញចូលតែមួយ៖ http://www.owso.gov.kh/?page_id=1843 [ចូលស្រាវជ្រាវនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥]។

[៣០] គេហទំព័រការិយាល័យច្រកចេញចូលតែមួយ៖ http://www.owso.gov.kh/?page_id=1843 [ចូលស្រាវជ្រាវនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥]។

[៣១] ព័ត៌មានទទួលបានពីមន្ត្រីសាធារណៈ ដែលធ្វើការនៅការិយាល័យច្រកចេញចូលតែមួយនៅភ្នំពេញ។ សម្រាប់ព័ត៌មានទាក់ទងការិយាល័យនៅទីក្រុងភ្នំពេញមិនអាចរកឃើញនៅក្នុងគេហទំព័រផ្លូវការទេ (www.owso.gov.kh)។

**តារាងទី១១៖ ការយល់ដឹងរបស់ម្ចាស់សហគ្រាសធុនតូចនិងមធ្យម ពីវិធានប្រឆាំងអំពើពុករលួយដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល**

| | ចំនួនសហគ្រាស ដែលបានដឹង | សហគ្រាស ដែលមិនបានដឹង | មិនទាក់ទង |
|---|---|---|---|
| ច្បាប់ប្រឆាំងអំពើពុករលួយ | ៦៧ | ១៩ | ៦៦ |
| សេចក្តីណែនាំប្រឆាំងការសូកប៉ាន់ | ២០ | ៥៨ | ១៤ |
| លេខទូរស័ព្ទរហ័សប្រឆាំងអំពើពុករលួយ | ៣៣ | ៤៩ | ៣ |

ទាក់ទងនឹងការយល់ដឹងរបស់សហគ្រាសធុនតូច និងមធ្យម លើវិធានការ ដែលរដ្ឋាភិបាលបានអនុម័តដើម្បីប្រឆាំងអំពើពុករលួយ អ្នកចូលរួម ៣២ នាក់គិតថា សហគ្រាសធុនតូច និងមធ្យម មានការយល់ដឹងពីវិធានការទាំងនោះ ហើយ៣៦នាក់ទៀតគិតថា ពួកគេមិនបានយល់ដឹងអំពីវិធានការទាំងនោះទេ រីឯ ២២នាក់ទៀតមិនបានឆ្លើយសំណួរនេះទេ។

ចំណេះដឹងរបស់សហគ្រាសធុនតូចនិងមធ្យមលើវិធានការដែលបានអនុម័តដោយរាជរដ្ឋាភិបាល មាននូវអត្ថន័យទូលំទូលាយ៖ ដូចដែលបានបង្ហាញនៅក្នុងផ្នែកនេះ ម្ចាស់សហគ្រាសធុនតូចនិងមធ្យមជាច្រើនប្រហែលជាបានឮតែពីវិធាការតែប៉ុណ្ណោះ តែមិនអាចប្រាប់ព័ត៌មានបន្ថែមនោះទេ ហើយក៏មិនអាចចេះពីរបៀបប្រើវិធានទាំងនេះដែរ។

## ការប្រើប្រាស់គំនិតផ្តួចផ្តើមរបស់តតិយជន

### *សភាពាណិជ្ជកម្ម និងសមាគម*

អ្នកចូលរួមតែ ១៦នាក់ប៉ុណ្ណោះ ដែលជាសមាជិកសភាពាណិជ្ជកម្ម ឬសមាគម។ បើទោះជាអ្នកចូលរួមខ្លះជាពិសេសអ្នកដែលនៅក្រៅរាជធានីភ្នំពេញ បានឯកភាពថា ការចូលជាសមាជិកនៃសភាពាណិជ្ជកម្ម ឬសមាគម អាចជួយអោយពួកគាត់ប្រយុទ្ធប្រឆាំង ឬទទួលបាននូវចំណេះដឹងបន្ថែមទៀតអំពីច្បាប់ជាធរមានក៏ដោយ ក៏អ្នកដែលត្រូវបានសម្ភាសមួយចំនួនធំ មិនបានគិតថា សភាពាណិជ្ជកម្មនិងសមាគម អាចជួយពួកគាត់ជាប្រចាំថ្ងៃក្នុងការជៀសវាងពីអំពើពុករលួយនោះដែរ។

សភាពាណិជ្ជកម្ម និងសមាគម អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំសហគ្រាសធុនតូច និងមធ្យមអោយធ្វើជំនួញរបស់ពួកគាត់។ ក្លាយជាសមាជិកសកម្មមួយនៃសភាពាណិជ្ជកម្ម ពិតជាអាចជួយដល់ក្រុមហ៊ុនក្នុងការតទល់នឹងបញ្ហាអំពើពុករលួយបាន។ បើទោះជាភាគច្រើននៃសភាពាណិជ្ជកម្ម មិនមាននូវ

សកម្មភាព ឬសន្និសិទណាមួយជាក់លាក់ស្ដីពីអំពើពុករលួយក៏ដោយ ដ៏ភាពច្រើននៃសភាទាំងនោះ មានក្រុមការងារលើប្រធានបទជាក់លាក់ ហើយពិភាក្សាលើបញ្ហាអំពើពុករលួយដោយប្រយោល។ ច្រើនជាងនេះទៅទៀត នាយកប្រតិបត្តិទាំងអស់ អាចចែករំលែកពីបទពិសោធន៍ផ្ទាល់ខ្លួនលើបញ្ហាអំពើពុករលួយនេះជាមួយនឹងសមាជិកដ៏ទៃទៀតនៅក្នុងអំឡុងពេលព្រឹត្តិការណ៍បង្កើនបណ្ដាញទំនាក់ទំនងគ្នា។ ដោយមាននូវការពិភាក្សាអំពីអំពើពុករលួយ និង ចែករំលែកនូវបទពិសោធន៍គ្នា អ្នកជំនួញអាចមានការយល់ដឹងច្រើនជាងមុនពីបញ្ហានេះ ហើយអាចរៀនពីវិធីក្នុងការជៀសវាងពីអំពើពុករលួយផងដែរ។

# ៥. សេចក្តីសន្និដ្ឋាន

សហគ្រាសធុនតូច និងមធ្យម ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ ខណៈពេលដែលទីផ្សាររបស់ប្រទេសនេះបានរីកចំរើនធំជាងមុន ជាមួយនឹងសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាននៅក្នុងឆ្នាំនេះ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា នឹងត្រូវប្រឈមនឹងបញ្ហាជាច្រើន។

ការស្រាវជ្រាវនេះ បានបង្ហាញថា សហគ្រាសធុនតូច និងមធ្យម នៅប្រទេសកម្ពុជាមួយចំនួនធំ ត្រូវបានរងផលប៉ះពាល់ពីអំពើពុករលួយ។ លើសពីនេះ អ្នកផ្តល់កិច្ចសម្ភាស ដែលបានចូលរួមក្នុងការស្រាវជ្រាវ នេះមានភាពងាយស្រួលក្នុងការនិយាយអំពី "ប្រាក់ទឹកតែ" ជាជាងនិយាយអំពីអំពើពុករលួយ ទោះបីជាភាគច្រើននៃអ្នកចូលរួមធ្វើកិច្ចសម្ភាសនេះ អាចឲ្យអត្ថន័យអំពី "អំពើពុករលួយ " ក៏ដោយ ។

ទោះបីជាអ្នកផ្តល់កិច្ចសម្ភាសជាច្រើន បានដឹងថា អ្វីដែលជាអំពើពុករលួយ និងការចំណាយក្រៅផ្លូវការក៏ដោយ ក៏ភាគច្រើននៃអ្នកទាំងនោះ បានយល់ស្របថា ការសូកប៉ាន់ ត្រូវតែបង់ ដើម្បីទទួលបានការងាររួចរាល់ចំសព្វគ្រប់ ឬដើម្បីកុំឲ្យខាតពេលវាលាច្រើនពេក សម្រាប់នីតិវិធីរដ្ឋបាល ដូចជាការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនជាដើម។ លើសពីនេះទៅទៀត ការខ្វះខាតនូវចំណេះដឹងផ្នែកច្បាប់ និងវិធានច្បាប់ដែលអនុវត្តចំពោះសហគ្រាសធុនតូច និងមធ្យម របស់នាយកប្រតិបត្តិ គឺជាកត្តាមួយ ដែលរួមចំណែកយ៉ាងសំខាន់ដល់ការពិតដែលថា ពួកគេនឹងមានភាពងាយស្រួល ក្នុងការក្លាយជាគោលដៅនៃអំពើពុករលួយ ដូច្នេះហើយទើបពួកគេអាចក្លាយជាកម្មវត្ថុទៅនឹងការទាមទារឱ្យមានការសូកប៉ាន់នេះ។

ទោះបីជាមានយន្តការជាច្រើនត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីដោះស្រាយអំពីបញ្ហាអំពើពុករលួយ ដូចជាអង្គភាពប្រឆាំងអំពើពុករលួយក៏ដោយ ក៏នាយកប្រតិបត្តិជាច្រើន នៅតែមិនជឿ ឬមិនទាន់ស្គាល់ច្បាស់អំពីយន្តការទាំងនេះទេ ហើយព្រមទាំងមិនចង់អនុវត្តនូវយន្តការទាំងនេះឡើយប្រសិនបើពួកគេប្រឈមមុខនឹងបញ្ហាដែទាក់ទងនឹងអំពើពុករលួយ។

អំពើពុករលួយ ជាឧបសគ្គដល់ការអភិវឌ្ឍ និងទប់ស្កាត់នូវការរីកចំរើនរបស់សហគ្រាសធុនតូច និងមធ្យមនៅលើកម្រិតជាច្រើន រួមបញ្ចូលទាំងកំណើនសេដ្ឋកិច្ចទាំងមូលរបស់កម្ពុជាផងដែរ។ ហេតុនេះហើយ វិធានការ ត្រូវតែអនុវត្តដោយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីកំណត់អំពីផលប៉ះពាល់ដែលអាចមាននៅក្នុងរយៈពេលវែង។

# ៦. អនុសាសន៍គោលនយោបាយ

## ក. អនុសាសន៍ទូទៅ

**រួមបញ្ចូលភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងកិច្ចពិភាក្សាអំពីសុចរិតភាពអាជីវកម្ម និងអំពើពុករលួយ។**

- ធានាឲ្យមានសកម្មភាព និងកិច្ចសហការរួមគ្នា រវាងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចបាននូវការអនុវត្តដ៏មានប្រសិទ្ធិភាពនៃក្របខ័ណ្ឌ និងគោលនយោបាយ សម្រាប់សហគ្រាសធុនតូច និងមធ្យម។

**ធ្វើការកំណត់នូវភាពស្មើគ្នាសម្រាប់ភាគីដែលពាក់ព័ន្ធទាំងអស់ ដូច្នេះភាគីទាំងអស់នោះគោរពនូវច្បាប់ដូចគ្នាដែល អាចកាត់បន្ថយនូវការប្រព្រឹត្តអំពើពុករលួយ។**

- ផ្តល់ជំនួយដល់សហគ្រាសធុនតូច និងមធ្យម ដោយផ្អែកលើគោលនយោបាយ ដែលមានលក្ខណៈយូរអង្វែង ពិស្តារ ស៊ីសង្វាក់គ្នា និងមានសង្គតិភាព ដើម្បីធានាអោយបាននូវភាពស្មើគ្នាសម្រាប់ម្ចាស់អាជីវកម្មទាំងអស់។
- អនុវត្ត លើកកំពស់ និងអភិវឌ្ឍ នូវយន្តការត្រួតពិនិត្យ ព្រឹត្តិការណ៍បង្កើតបណ្តាញ និងការចែករំលែកនូវការអនុវត្តល្អៗ ដើម្បីធានាអោយបានថា គោលនយោបាយសហគ្រាសធុនតូច និងមធ្យមត្រូវបានដាក់អោយអនុវត្តប្រកបដោយប្រសិទ្ធិភាព។

## ខ. អនុសាសន៍ចំពោះវិស័យឯកជន

**ផ្តល់ព័ត៌មាន និងបង្កើនចំណាប់អារម្មណ៍ ដល់វិស័យឯកជន**

- ធ្វើការលើកទឹកចិត្តដល់ម្ចាស់អាជីវកម្ម ក្នុងការផ្តើមគំនិតសិក្សាបន្ថែមអំពីច្បាប់ បទបញ្ញា និង នីតិវិធីដែលអនុវត្តចំពោះអាជីវកម្មរបស់ខ្លួន និងចាត់វិធានការដើម្បីធានាឱ្យមានសុចរិតភាពអាជីវកម្មនៅក្នុងក្រុមហ៊ុនរបស់ខ្លួន។
- ធ្វើការអភិវឌ្ឍ ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាល នូវកម្មវិធីបណ្តុះបណ្តាល និង ខិត្តប័ណ្ណព័ត៌មានលើវិធានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដែលមានស្រាប់ ដើម្បីធានានូវចំណេះដឹងល្អប្រសើរជាងមុន ក្នុងចំណោមម្ចាស់អាជីវកម្មទាំងអស់។

- ផ្តល់សិទ្ធិអំណាចដល់ម្ចាស់អាជីវកម្ម ក្នុងការធ្វើការបដិសេធយ៉ាងសកម្មលើការបង់ប្រាក់សូកប៉ាន់ និងក្នុងការប្រើប្រាស់វិធានការដែលបានដាក់ចេញដោយរដ្ឋាភិបាល នាពេលដែលពួកគេប្រឈមនឹងបញ្ហាអំពើពុករលួយ។
- ធ្វើការកសាងសមត្ថភាពរបស់ម្ចាស់អាជីវកម្ម នៅក្នុងការប្រើប្រាស់នូវឧបករណ៍បច្ចេកវិជ្ជាព័ត៌មានវិទ្យា ដូច្នេះម្ចាស់អាជីវកម្ម អាចប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពនូវប្រព័ន្ធដែលបានបង្កើតឡើងដោយ រាជរដ្ឋាភិបាល ដូចជាការចុះឈ្មោះតាមប្រព័ន្ធអេឡិចត្រូនិច និងគោលការណ៍ណែនាំនានាដែល អាចរកបាននៅលើគេហទំព័រនានា។

**រួមបញ្ចូលសភាពាណិជ្ជកម្ម និងសមាគមផ្សេងៗ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ**

- បង្កើតឲ្យមានតំណាងនៅគ្រប់ខេត្ត-ក្រុង ដើម្បីបញ្ចូលក្រុមហ៊ុនអាជីវកម្មទាំងអស់នៅក្នុងប្រទេសកម្ពុជា ដោយមិនមែនមានតែក្រុមហ៊ុនអាជីវកម្មដែលស្ថិតនៅក្នុងរាជធានីនោះឡើយ។
- បង្កើតឲ្យមានក្រុមការងារជំនាញលើអំពើពុករលួយនៅក្នុងស្ថាប័នតំណាងទាំងនេះ ដើម្បីអោយរាល់បញ្ហាទាក់ទងនឹងអំពើពុករលួយ ត្រូវបានធ្វើការពិភាក្សាជាផ្លូវការក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។

## គ. អនុសាសន៍ចំពោះរដ្ឋាភិបាលនិងស្ថាប័នសាធារណៈ

**អនុម័ត និងអនុវត្តច្បាប់ និងក្របខ័ណ្ឌក្នុងការគាំទ្រឱ្យមានប្រសិទ្ធិភាពទៅដល់ សហគ្រាសធុនតូច និងមធ្យម**

- ធ្វើសុខដុមនីយកម្មនូវរាល់ច្បាប់ និងក្របខ័ណ្ឌនានា ដែលត្រូវអនុវត្តចំពោះសហគ្រាសធុនតូច និងមធ្យម ដើម្បីជៀសវាងនូវភាពផ្ទុយគ្នាណាមួយនៅក្នុងច្បាប់ទាំងនោះ។
- បង្កើនសមត្ថភាពមន្ត្រីរាជការ ដោយរៀបចំនូវវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនានា សម្រាប់ការអនុវត្តច្បាប់ និងក្របខ័ណ្ឌ ដែលពាក់ព័ន្ធនឹងសហគ្រាសធុនតូច និងមធ្យម ប្រកបដោយប្រសិទ្ធិភាព។

**បង្កើន និង ធ្វើឱ្យប្រសើរឡើង នូវការទទួលបានព័ត៌មាន និងបង្កើនចំណេះដឹងលើគោលនយោបាយ និងច្បាប់នានា របស់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យកាន់តែល្អប្រសើរ**

- បង្កើតឲ្យមាននូវប្រព័ន្ធទំនាក់ទំនងបច្ចេកវិទ្យា ដើម្បីផ្សព្វផ្សាយនូវព័ត៌មានដែលពាក់ព័ន្ធទាំងអស់។ រាល់ប្រព័ន្ធទំនាក់ទំនងនិងព័ត៌មានពាក់ព័ន្ធទាំងអស់ គួរតែអាចរកបាននៅលើគេហទំព័ររបស់រាល់ក្រសួងដែលពាក់ព័ន្ធ។ ព័ត៌មានទាំងនេះ គួរតែបញ្ចូលនូវគោលការណ៍ណែនាំ ស្តីពីនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម និងគោលការណ៍ណែនាំ ដែលពាក់ព័ន្ធដទៃទៀត ដែលអាចជួយសម្រួលដល់ម្ចាស់អាជីវកម្មក្នុងការប្រកបអាជីវកម្មប្រចាំថ្ងៃរបស់ខ្លួន។

- ធានា ការចូលស្វែងរកទិន្នន័យជាសាធារណៈ លើទិន្នន័យសហគ្រាសធុនតូច និងមធ្យម និងកម្រងទិន្នន័យនានា ដែលក្នុងនោះរួមមាននូវមូលដ្ឋានទិន្នន័យសហគ្រាសធុនតូច និងមធ្យម ដែលបានចុះបញ្ជីពាណិជ្ជកម្មទាំងអស់។
- បង្កើតនិងអនុវត្តក្របខ័ណ្ឌគោលនយោបាយ ដើម្បីធានាឱ្យមានការសម្របសម្រួលដ៏មានប្រសិទ្ធិភាពលើសកម្មភាពទាំងអស់ដែលទាក់ទងនឹងសហគ្រាសធុនតូច និងមធ្យម នៅគ្រប់ក្រសួងទាំងអស់ដោយរួមទាំងយន្តការស្ថាប័នសម្រាប់ទ្រទ្រង់ដល់ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។
- ធានាថា រាល់អង្គការ និងស្ថាប័ន ដែលធ្វើការជាមួយនឹងសហគ្រាសធុនតូច និងមធ្យមទាំងអស់មានប្រសិទ្ធិភាព និងតម្លាភាព ដោយក្នុងនោះរួមមានអង្គភាពប្រឆាំងអំពើពុករលួយ ក្រុមការងារបច្ចេកទេសលើវិស័យសហគ្រាសធុនតូច និងមធ្យម និងប្រព័ន្ធតុលាការ។

**ធ្វើកំណែទម្រង់លើការចុះបញ្ជីពាណិជ្ជកម្ម ការផ្តល់អាជ្ញាប័ណ្ណ និងនីតិវិធីជាធរមានផ្សេងទៀត**

- ធានាឲ្យមានអភិបាលកិច្ចល្អ និងបរិយាកាសច្បាប់កាន់តែប្រសើរឡើង តាមរយៈប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់អាជ្ញាប័ណ្ណកាន់ប្រសើរជាងមុន និងការធ្វើការអភិវឌ្ឍលើការសម្រួលនូវរាល់ប្រព័ន្ធច្បាប់ ស្ថាប័ន និងរដ្ឋបាលដែលពាក់ព័ន្ធ។
- ធ្វើឲ្យមានភាពងាយស្រួល នូវនីតិវិធីរដ្ឋបាល ដែលពាក់ព័ន្ធ (ដូចជានីតិវិធីបង់ពន្ធ)។
- បង្កើតទម្រង់បែបបទនិងគំរូទម្រង់បែបបទ ដែលពាក់ព័ន្ធ ហើយដាក់អោយសាធារណៈជនចូលប្រើប្រាស់ទម្រង់បែបបទទាំងនោះ តាមរយៈគេហទំព័រ និងការិយាល័យរបស់ក្រសួង ដែលរួមបញ្ចូលទាំងការិយាល័យនៅតាមខេត្តផងដែរ។

# គន្ថនិទ្ទេស

Baily, Peter. “Cambodian Small and Medium Sized: Enterprises: Constraints, Policies and Proposals for Their Development.” (សហគ្រាសធុនតូច និងមធ្យមរបស់កម្ពុជា៖ ឧបសគ្គ គោលនយោបាយ និងសំណើរសម្រាប់ការអភិវឌ្ឍរបស់សហគ្រាសទាំងនេះ). *SMEs in Asia and Globalization*(សហគ្រាសធុនតូច និងមធ្យមនៅអាស៊ី និងពិភពលោក), ០៥/២០០៧ ទំព័រ១-៣៦។

ERIA(វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា). “ASEAN SME Policy Index 2014-Towards Competitive and Innovative ASEAN SMEs.” (សន្ទស្សន៍គោលនយោបាយនៃអាស៊ាន ២០១៤-ការឆ្ពោះទៅរកភាពប្រកួតប្រជែងនិងច្នៃប្រឌិតនៃសហគ្រាសធុនតូចនិងមធ្យមអាស៊ាន) ហ្សាការតា ២០១៤, ២៦០ទំព័រ។

KPMG. *Investing in Cambodia* (ការវិនិយោគនៅកម្ពុជា). ភ្នំពេញ ២០១៣។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ. www.mef.gov.kh (ចូលស្រាវជ្រាវនៅថ្ងៃទី១២/០៣/២០១៥)។

វិទ្យាស្ថានស្ថិតិជាតិកម្ពុជា. “Cambodia Inter-censal Economic Survey 2014 National Report on Final Results.” (អន្តរជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១៤៖ របាយការណ៍ថ្នាក់ជាតិលើលទ្ធផលចុងក្រោយ) ភ្នំពេញ ២០១៥, VI-១៨។

វិទ្យាស្ថានស្ថិតិជាតិកម្ពុជា. “Economic Census of Cambodia 2011, Analysis of the Census Results Report No. 4, Analysis on Large, Medium & Small, and Micro Industry.” (ជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១១៖ ការវិភាគលើលទ្ធផលជំរឿន, របាយការណ៍ទី ៤ ការវិភាគលើឧស្សាហកម្មធុនមីក្រូ តូច មធ្យម និង ធំ) ភ្នំពេញ ២០១២, I-១៩១។

វិទ្យាស្ថានស្ថិតិជាតិកម្ពុជា. “Economic Census of Cambodia 2011, National Report on Final Census Results.” (ជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១១៖ របាយការណ៍ថ្នាក់ជាតិលើលទ្ធផលជំរឿនចុងក្រោយ) ភ្នំពេញ ២០១២, VI-២៣។

វិទ្យាស្ថានស្ថិតិជាតិកម្ពុជា. “Economic Census of Cambodia 2011. Analysis of the Census Results Report No. 1. Analysis on 17 Industries.” (ជំរឿនសេដ្ឋកិច្ចកម្ពុជា ២០១១៖ ការវិភាគលើលទ្ធផលជំរឿន, របាយការណ៍ទី ១ ការវិភាគលើវិស័យឧស្សាហកម្មចំនួន១៧) ភ្នំពេញ ២០១៣, ១៤៣ ទំព័រ។

OECD (អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច). "Promoting SMEs For Development." (ការលើកតម្កើងសហគ្រាសធុនតូចនិងមធ្យមសម្រាប់ការអភិវឌ្ឍ) ប៉ារីស ២០០៤, ៥៩ ទំព័រ។

Raynard, Peter, and Maya Forstater. "Corporate Social Responsibility: Implications for Small and Medium Enterprises in Developing Countries." (ទំនួលខុសត្រូវសង្គមរបស់សហគ្រាសៈ ការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងប្រទេសកំពុងអភិវឌ្ឍន៍) វីយែន ២០០២, ៧៥ ទំព័រ។

រាជរដ្ឋាភិបាលកម្ពុជា. "Small and Medium Enterprises Development Framework." (ក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម) Sub-committee on Smal and Medium Enterprises (អនុគណៈកម្មាការសហគ្រាសធុនតូចនិងមធ្យម), SME Secretariat (លេខាធិការដ្ឋានសហគ្រាសធុនតូចនិងមធ្យម), ២០០៥។

អង្គការតម្លាភាពអន្តរជាតិ "Corruption Perception Index." (សន្ទស្សន៍ស្តីពីការយល់ឃើញអំពីអំពើពុករលួយ) ២០១៤. https://www.transparency.org/cpi2014 (ចូលស្រាវជ្រាវនៅថ្ងៃទី១១/០៣/២០១៥)។

ធនាគារពិភពលោក. "Cambodia Overview." (ទិដ្ឋភាពទូទៅនៃប្រទេសកម្ពុជា) http://www.worldbank.org/en/country/cambodia/overview (ចូលស្រាវជ្រាវនៅថ្ងៃទី១៣/០៣/២០១៥)។

ធនាគារពិភពលោក. "Ease in Doing Business 2015." (ភាពងាយស្រួលក្នុងការធ្វើធុរកិច្ច២០១៥) វ៉ាស៊ីនតោន ២០១៥, ៣១៨ ទំព័រ។

# ឧបសម្ព័ន្ធ

# កម្រងសំណួរសម្រាប់នាយកប្រតិបត្តិ

## ក.ព័ត៌មានរបស់បេក្ខជនត្រូវសម្ភាស

| ១. តើអ្នកមានតំណែងអ្វីនៅក្នុងក្រុមហ៊ុន ? | |
|---|---|
| ម្ចាស់ក្រុមហ៊ុន | |
| នាយកប្រតិបត្តិ / នាយក | |
| អ្នកគ្រប់គ្រងទូទៅ | |
| ផ្សេងទៀត ៖ | |

## ខ. ប្រវត្តិរបស់ក្រុមហ៊ុន

| ២. តើក្រុមហ៊ុនរបស់អ្នកមាននិយោជិតប៉ុន្មានអ្នក ? | |
|---|---|
| តិចជាង ៥ នាក់ | |
| ពី ៥ទៅ ១០ នាក់ | |
| ពី ១១ ទៅ ៥០ នាក់ | |
| ពី ៥១ ទៅ ១០០ នាក់ | |
| ច្រើនជាង ១០០ នាក់ | |

| ៣. តើអាជីវកម្មរបស់អ្នកត្រូវការដើមទុនប៉ុន្មាន( ដោយមិនរាប់បញ្ចូលដីធ្លី ) ដើម្បីប្រតិបត្តិការ ? | |
|---|---|
| តិចជាង ៥0 000 ដុល្លាអាមេរិក | |
| ពី ៥0 000 ដុល្លាអាមេរិក ដល់ ២៥0 000 ដុល្លាអាមេរិក | |
| ពី ២៥0 000 ដុល្លាអាមេរិក ដល់ ៥00 000 ដុល្លាអាមេរិក | |
| ច្រើនជាង ៥00 000 ដុល្លាអាមេរិក | |

| | |
|---|---|
| **៤.តើសហគ្រាសរបស់លោកអ្នកត្រូវបានបង្កើតឡើងតាំងពីពេលណា?** | |

| **៥. តើក្រុមហ៊ុនរបស់អ្នកមាននីតិបុគ្គលភាពប្រភេទណា?** | |
|---|---|
| ក្រុមហ៊ុនឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) | |
| ក្រុមហ៊ុនឯកកម្មសិទ្ធិ (បានចុះបញ្ជី) | |
| ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត | |
| ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត | |
| ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ | |
| ក្រុមហ៊ុនសហកម្មសិទ្ធិមានកំរិត | |
| បុត្រសម្ព័ន្ធក្រុមហ៊ុនបរទេស | |
| សាខាក្រុមហ៊ុនបរទេស | |
| ការិយាល័យតំណាងក្រុមហ៊ុនបរទេស | |
| សហគ្រាសគ្រប់គ្រងដោយរដ្ឋ | |
| សហករណ៍ | |
| ផ្សេងទៀត ៖ | |

| **៦. តើអ្នកណាខ្លះជាអ្នកកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនអ្នក?** | |
|---|---|
| ក្រុមហ៊ុនគ្រប់គ្រងទាំងស្រុងដោយមនុស្សម្នាក់ | |
| ភាគហ៊ុនច្រើនជាង៥០%កាន់កាប់ដោយម្ចាស់ភាគហ៊ុនសញ្ជាតិខ្មែរ | |
| ភាគហ៊ុនតិចជាង៥០%កាន់កាប់ដោយម្ចាស់ភាគហ៊ុនសញ្ជាតិខ្មែរ | |
| ផ្សេងទៀត ៖ | |

| **៧. តើក្រុមហ៊ុនរបស់អ្នកមានសាខាផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាឬទេ?** | |
|---|---|
| ប្រសិនបើមាន(តើមានប៉ុន្មាន និងនៅទីណាខ្លះ?) | |
| តើមានប៉ុន្មាន? | |
| នៅទីណា? | |

| **៨.តើអ្វីជាកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអ្នក?** | |
|---|---|
| សេវាកម្មស្នាក់នៅ | |
| ការអប់រំ | |
| ផលិតកម្មចំណីអាហារ ភេសជ្ជៈ និងសំលៀកបំពាក់... | |
| សេវាកម្មផ្សេងៗ (ក្រុមហ៊ុនទេសចរណ៍ ស្ថាប័នមីក្រូហិរញ្ញវត្ថុ...) | |
| ការជួញដូរ | |
| មីក្រូហិរញ្ញវត្ថុ ហាងបញ្ចាំ និង ស្ថាប័នហិរញ្ញវត្ថុ | |
| លក់ដុំ | |
| រោងកិនស្រូវ | |
| ផ្សេងទៀត ៖ | |

| ៩. អត្តសញ្ញាណភេទម្ចាស់ក្រុមហ៊ុន | |
|---|---|
| ប្រុស | |
| ស្រី | |
| ទាំងពីរភេទ (ស្ត្រីប៉ុន្មាន និង បុរសប៉ុន្មាន ?) | |

| ១០. សញ្ជាតិរបស់ម្ចាស់ក្រុមហ៊ុន | |
|---|---|
| ខ្មែរ | |
| ចិន | |
| ជប៉ុន | |
| កូរ៉េ | |
| ថៃ | |
| វៀតណាម | |
| អឺរ៉ុប | |
| ផ្សេងទៀត ៖ | |

| ១១. តើនិយោជិតរបស់អ្នកទាំងអស់ មានចុះបញ្ជីនៅក្រសួងការងារដែរឬទេ ? | |
|---|---|
| មានចុះបញ្ជី | |
| មិនទាន់មានចុះបញ្ជីទេ | |
| ប្រសិនបើមិនទាន់ចុះបញ្ជី ហេតុអ្វី ? | |

## គ. ការចុះបញ្ជីរបស់ក្រុមហ៊ុន

| ១២. តើក្រុមហ៊ុនអ្នកមាននចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក៏នៅមន្ទីរពាណិជ្ជកម្ម នៅតាមបណ្តាខេត្ត ដែរ ឬទេ ? | |
|---|---|
| មានចុះបញ្ជី | |
| មិនមានចុះបញ្ជីទេ | |

| ១៣. តើក្រុមហ៊ុនរបស់អ្នក បានចុះបញ្ជីនៅស្ថាប័នណាផ្សេងទៀតណាខ្លះ ? (សូមជ្រើសរើសចម្លើយ ដែលពាក់ព័ន្ធ) | |
|---|---|
| ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | |
| ក្រសួងទេសចរណ៍ | |
| ក្រសួងសុខាភិបាល | |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | |
| អគ្គនាយកដ្ឋានពន្ធដារ | |
| ក្រសួងអប់រំ | |
| ផ្សេងទៀត ៖ | |

| ១៤. តើអ្នកបានចុះបញ្ជីក្រុមហ៊ុនរបស់អ្នកជាមួយនឹងក្រសួងឬស្ថាប័នចាំបាច់នានា ដែលតម្រូវអោយមានទៅតាមប្រភេទនៃអាជីវកម្មរបស់អ្នកដែរឬទេ ? |
|---|
| |
| ប្រសិនបើអ្នកមិនបានចុះបញ្ជីនៅគ្រប់ក្រសួងឬស្ថាប័នចាំបាច់ទេនោះ សូមពន្យល់ថា តើហេតុអ្វីអ្នកមិនបានចុះឈ្មោះជាមួយនឹងក្រសួងឬស្ថាប័នទាំងនោះ ? |
| |

| ១៥. តើដំណើរការចុះបញ្ជីក្រុមហ៊ុនរបស់អ្នករហូតដល់ពេលបើកដំណើរការបានមានរយៈពេលប៉ុន្មាន? | |
|---|---|
| តិចជាងមួយសប្តាហ៍ | |
| ចន្លោះពីមួយទៅពីរសប្តាហ៍ | |
| ចន្លោះពីពីរសប្តាហ៍ទៅមួយខែ | |
| ចន្លោះពីមួយខែទៅពីរខែ | |
| ចន្លោះពីពីរខែទៅបីខែ | |
| ច្រើនជាងបីខែ | |
| ផ្សេងទៀត ៖ | |

| ១៦.តើអ្នកធ្លាប់បានទទួលការជួយពីកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាលឬអង្គការអន្តរជាតិណាមួយក្នុងការបង្កើតក្រុមហ៊ុនរបស់អ្នកដែរឬទេ? | |
|---|---|
| បាទ/ចាស ធ្លាប់ | |
| ទេ មិនធ្លាប់ទេ | |

| ១៧. តើអ្នកចុះបញ្ជីក្រុមហ៊ុនរបស់អ្នកដោយរបៀបណា? (តើមានមេធាវី ឬការិយាល័យមេធាវី ឬទីប្រឹក្សាណា ជួយក្នុងដំណើរការចុះបញ្ជីនេះឬទេ? |
|---|
| |
| តើអ្នកគិតថាវាសំខាន់ឬទេ ក្នុងការមានជំនួយ ទាំងនេះ? ហេតុអ្វីបានជាអ្នកគិតថាសំខាន់? |
| |

| ១៨.តើអ្នកដឹងអំពីតម្លៃផ្លូវការក្នុងការចុះបញ្ជីក្រុមហ៊ុនរបស់អ្នករហូតដល់ក្រុមហ៊ុនអ្នកមានដំណើរការថាអស់ប៉ុន្មានដែរឬទេ ? |
|---|
| |

| ១៩.តើអ្នកមានឯកសារទាំងអស់ដែលទាក់ទងទៅនឹងតម្លៃសេវាកម្មសាធារណៈដែរឬទេ ? (វិក័យប័ត្រ និងកិច្ចសន្យា) | |
|---|---|
| មាន | |
| អត់មាន | |
| ប្រសិនបើអ្នកមានឯកសារទាំងអស់នោះ តើវាជាឯកសារអ្វីខ្លះ ? | |
| | |

| ២០. តើអ្នកគិតថា អ្នកត្រូវតែបង់តម្លៃសេវាកម្ម ដែលមិនផ្លូវការដែរឬទេ ? | |
|---|---|
| ត្រូវបង់ | |
| មិនត្រូវបង់ | |
| ប្រសិនបើអ្នកគិតថាត្រូវបង់ តើមកពីមូលហេតុអ្វី ? ហើយចំនួនប៉ុន្មានដែរ ? | |

| ២១. តើអ្នកមានជួបឧបសគ្គក្នុងការចុះបញ្ជីក្រុមហ៊ុនរបស់អ្នកដែរឬទេ ? | |
|---|---|
| មាន | |
| អត់មាន | |

| ២២. តើមានឧបសគ្គបែបណាខ្លះដែលអ្នកបានជួប ?<br>តើអ្នកគិតថាអ្វីទៅដែលជាមូលហេតុនៃឧបសគ្គទាំងនេះ ? |
|---|
| |

## ឃ. ប្រតិបត្តិការរបស់ក្រុមហ៊ុននិងឧបសគ្គ

| ២៣.តើក្រុមហ៊ុនរបស់អ្នកទទួលបានការចុះធ្វើអធិការកិច្ចច្រើនដែរឬទេ ? | |
|---|---|
| ក ).តើការធ្វើអធិការកិច្ចមានប៉ុន្មានដងក្នុងឆ្នាំដំបូងនៃដំណើរការអាជីវកម្មរបស់អ្នក ? | |
| ខ ). តើការធ្វើអធិការកិច្ចទាំងនោះមានមកពីក្រសួងណាដែរ ? | |
| គ ). តើគោលបំណងនៃការធ្វើអធិការកិច្ចទាំងនោះគឺជាអ្វី ? | |

| | |
|---|---|
| ឃ).តើនរណានៅក្នុងក្រុមហ៊ុនរបស់អ្នក ជាអ្នកទទួលខុសត្រូវលើការងារទាក់ទងទៅនឹងការធ្វើអធិការកិច្ចទាំងនេះ? | ខ្លួនអ្នកផ្ទាល់ |
| | បុគ្គលិករដ្ឋបាល |
| | ផ្សេងទៀត |
| ង). តើអ្នកទទួលខុសត្រូវនោះជាបុរស ឬជាស្ត្រី? | បុរស |
| | ស្ត្រី |
| ច). តើអ្នកត្រូវបង់កំរៃ ក្នុងការទទួលការធ្វើអធិការកិច្ចទាំងនេះទេ? | ត្រូវបង់ |
| | មិនត្រូវបង់ទេ |
| ប្រសិនបើមានការបង់ប្រាក់ តើបង់ថ្លៃប៉ុន្មានដែរ? ហើយតើអ្នកទទួលបានវិក័យប័ត្រដែរឬទេ? ឬ អ្នកបានសួររកវិក័យប័ត្រដែរ ឬទេ? | |

| ២៤. តើក្រុមហ៊ុនរបស់អ្នកមានសកម្មភាពនាំចេញឬនាំចូលដែរឬទេ? | |
|---|---|
| មាន | |
| អត់មាន | |

| ២៥. បើមានសកម្មភាពនាំចេញឬនាំចូល តើអ្នកបានទាក់ទងជាមួយអាជ្ញាធរមានសមត្ថកិច្ចណាខ្លះសម្រាប់ការនាំចេញ ឬនាំចូលរបស់ក្រុមហ៊ុនអ្នក កាលពីឆ្នាំមុន? |
|---|
| |

| ២៦. តើអ្នកបានចំណាយប៉ុន្មាន ដើម្បីបំពេញនូវតម្រូវការរដ្ឋបាល នៃការនាំចេញឬនាំចូលរបស់ក្រុមហ៊ុនអ្នក កាលពីឆ្នាំមុន? |
|---|
| |

## ខ. ការយល់ដឹងអំពីអំពើពុករលួយ

| ២៧.តើអ្នកគិតយ៉ាងណាអំពីបរិយាកាសទូទៅរបស់សហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា? | |
|---|---|
| | |

| ២៨. តើអ្នកអាចអោយចំណាត់ថ្នាក់នៃអត្រាកំណើនរបស់ក្រុមហ៊ុនអ្នកនាពេលបច្ចុប្បន្ន ដោយប្រៀប ទៅនឹង៥ឆ្នាំខាងមុខ ត្រឹមកំរិតណាដែរ? |
| --- |
| |

| ២៩. តើកត្តាអ្វីដែលមានឥទ្ធិពលទៅលើការរីកចំរើនរបស់ក្រុមហ៊ុនអ្នក នាពេល៥ឆ្នាំខាងមុខ? |
| --- |
| |

| ៣០. តើអ្នកយល់ឃើញថាក្រុមហ៊ុនអ្នកនឹងរីកចម្រើន ឬ ចុះអន់ថយ នាពេល៥ឆ្នាំខាងមុខ? (សូមពន្យល់) |
| --- |
| |

| ៣១. តើអ្វីទៅជាអត្ថន័យនៃពាក្យ" ពុករលួយ" សម្រាប់អ្នក? |
| --- |
| |

| ៣២. តើអ្វីទៅជាអត្ថន័យនៃ" ការចំណាយក្រៅផ្លូវការ" សម្រាប់អ្នក? |
| --- |
| |

| ៣៣. តើអ្វីទៅជាអត្ថន័យនៃពាក្យ "អាជីវកម្មស្អាតស្អំ" (សុចរិតភាពពាណិជ្ជកម្ម) សម្រាប់អ្នក? |
| --- |
| |

| ៣៤. តើក្រុមហ៊ុនរបស់អ្នក ធ្លាប់ពិភាក្សាអំពីបញ្ហាអាជីវកម្មស្អាតស្អំនេះ ពីមុនមកដែរឬទេ? | |
| --- | --- |
| ធ្លាប់ (ពិភាក្សាយ៉ាងដូចម្តេច?) | |
| មិនធ្លាប់ (ហេតុអ្វី?) | |

| ៣៥. តាមការដឹងរបស់អ្នក តើក្រុមហ៊ុនអ្នក ធ្លាប់ឮ ឬធ្លាប់ជួប បញ្ហាអំពើពុករលួយនៅក្នុង អាជីវកម្មខ្លួន នៅក្នុងប្រទេសកម្ពុជាដែរឬទេ? | |
| --- | --- |
| ធ្លាប់ | |
| មិនធ្លាប់ | |

| |
|---|
| ៣៦. ប្រសិនបើ អ្នកធ្លាប់ឮ ឬធ្លាប់ជួប តើអំពើពុករលួយប្រភេទណា ដែលអ្នកធ្លាប់ឮ ឬធ្លាប់ជួប នៅក្នុងវិស័យសាធារណៈ? ហើយហេតុអ្វី? (ឧទាហរណ៍ ការចំណាយក្រៅផ្លូវការសម្រាប់ការចុះបញ្ជី ឬ សម្រាប់ការត្រួតពិនិត្យប្រចាំឆ្នាំពីអាជ្ញាធរមានសមត្ថកិច្ច។ល។) |
| |

| |
|---|
| ៣៧. តើអ្នកគិតថា ហេតុអ្វីបានជាមានអំពើពុករលួយទាំងនេះកើតឡើង? (ឧទាហរណ៍ ការចំណាយក្រៅផ្លូវការសម្រាប់ការចុះបញ្ជី ឬ សម្រាប់ការត្រួតពិនិត្យប្រចាំឆ្នាំពីអាជ្ញាធរមានសមត្ថកិច្ច។ល។) |
| |

| |
|---|
| ៣៨. តើអំពើពុករលួយប្រភេទណា ដែលអ្នកធ្លាប់ឮ ឬធ្លាប់ជួប នៅក្នុងវិស័យឯកជន? តើអ្នកគិតថា ហេតុអ្វី បានជាវាកើតឡើង? (ឧទារហណ៍ ការចំណាយក្រៅផ្លូវការនៅធនាគារឯកជន ដើម្បីទទួលបានឥណទាន) |
| |

| ៣៩. តើអ្នកណានៅក្នុងក្រុមហ៊ុនអ្នក ត្រូវបានបញ្ជូនទៅដោះស្រាយបញ្ហាអំពើពុករលួយ ដើម្បីជៀសវាងនូវ ការប្រព្រឹត្តអំពើនេះ? តើអ្នកនឹងបញ្ជូនមេធាវីទៅដោះស្រាយឬទេ? តើអ្នកគិតថា មនុស្ស ឬបុគ្គល ដែលបានបញ្ជូនទៅដោះស្រាយ នឹងអាចរកដំណោះស្រាយបានដែរឬទេ? | |
|---|---|
| ខ្លួនអ្នកផ្ទាល់ | |
| និយោជិតស្រី | |
| និយោជិតប្រុស | |
| ផ្សេងទៀត ៖ | |

| ៤០.តើអំពើពុករលួយគឺជាកត្តាខាងក្រៅមួយដែលនាំអោយមានផលប៉ះពាល់ដល់ការរីកចម្រើននៃអាជីវកម្មអ្នក ដែរឬទេ? | |
|---|---|
| ប៉ះពាល់ | |
| មិនប៉ះពាល់ | |

| ៤១. ប្រសិនបើមានផលប៉ះពាល់ តើអ្នកធ្វើចំណាត់ថ្នាក់នៃផលប៉ះពាល់នោះកម្រិតណា? (១ សម្រាប់កំរិតប៉ះពាល់ទាបបំផុត និង៥សម្រាប់កំរិតប៉ះពាល់ខ្ពស់បំផុត) |
|---|
| |

| ៤២. តើអ្នកធ្វើយ៉ាងណា នៅពេលដែលអ្នកជួបប្រទះជាមួយនឹងអំពើពុករលួយ? |
|---|
| |

| ៤៣. តើអ្នកមានដំណោះស្រាយ ឬវិធីណាដើម្បីដោះស្រាយអំពើពុករលួយដែរឬទេ? | |
|---|---|
| មាន | |
| អត់មាន | |

| ៤៤. ប្រសិនបើអ្នកមានដំណោះស្រាយឬវិធីដើម្បីដោះស្រាយអំពើពុករលួយ តើអ្នកមាន វិធីអ្វីខ្លះដែរ? សូមមេត្តាជួយរៀបរាប់ |
|---|
| |

| ៤៥. តើនិយោជិតរបស់អ្នកដឹងថានឹងត្រូវធ្វើដូចម្តេចដែរឬទេ នៅពេលដែលពួលគេជួបបញ្ហាអំពើពុករលួយ? | |
|---|---|
| ដឹង | |
| អត់ដឹង | |

| ៤៦. តើក្រុមហ៊ុនរបស់អ្នកមាន ក្រមប្រតិបត្តិ ឬក្រមសីលធម៌ដែរឬទេ? | |
|---|---|
| មាន | |
| អត់មាន | |

| ៤៧. ប្រសិនបើក្រុមហ៊ុនរបស់អ្នកមានក្រមប្រតិបត្តិ ឬក្រមសីលធម៌ តើក្រមទាំងនោះ មានចែងទាក់ទងនឹងអំពើពុករលួយដែរឬទេ? | |
|---|---|
| មាន | |
| អត់មាន | |
| ប្រសិនបើមាន សូមមេត្តាជួយរៀបរាប់ | |

| ៤៨. តើក្រុមហ៊ុនអ្នកមានចូលជាសមាជិក ក្នុងសមាគម ឬ សភាពាណិជ្ជកម្មណាមួយដែរឬទេ? | |
|---|---|
| មាន | |
| អត់មាន | |
| ៤៩. ប្រសិនបើក្រុមហ៊ុនអ្នកមានចូលជាសមាជិកក្នុងសមាគម ឬសភាពាណិជ្ជកម្មណាមួយ តើស្ថាប័នទាំងនោះ មានជួយក្រុមហ៊ុនរបស់អ្នក ក្នុងការបង្ការលើបញ្ហាសូកប៉ាន់ដែរឬទេ? | |
| | |

| ៥០. តើអ្នករាយការណ៍ ករណីសូកប៉ាន់ ឬការគំរាមយកប្រាក់ ដែលអ្នកជួបប្រទះ ទៅដល់សមាគម ឬសភាពាណិជ្ជកម្ម យ៉ាងដូចម្តេចដែរ? |
|---|
| |

| ៥១.តើអ្នកធ្លាប់ទទួលបានការអន្តរាគមន៍ដែលមានលក្ខណៈវិជ្ជមានពីសមាគមនឬសភាពាណិជ្ជកម្ម ដែរឬទេ? (សូមពិពណ៌នា) |
|---|
| |

## ច. ការយល់ដឹងអំពីវិធានការរបស់រដ្ឋាភិបាល

| ៥២. តើអ្នកបានដឹងពីច្បាប់ប្រឆាំងអំពើពុករលួយដែរឬទេ ? | |
|---|---|
| បានដឹង | |
| មិនបានដឹង | |

| ៥៣. ប្រសិនបើអ្នកបានដឹង តើអ្នកដឹងអំពីច្បាប់នេះដល់កំរិតណា ?<br>( ១ សម្រាប់កំរិតដឹងទាបបំផុត និង៥សម្រាប់កំរិតដឹងខ្ពស់បំផុត ) |
|---|
| |

| ៥៤. តើអ្នកដឹងពីសេចក្តីណែនាំប្រឆាំងការសូកប៉ាន់ សម្រាប់វិស័យឯកជន (ដែលបានបង្កើតឡើងដោយ អង្គភាពប្រឆាំងអំពើពុករលួយ ) ដែរឬទេ ? | |
|---|---|
| បានដឹង | |
| មិនបានដឹង | |

| ៥៥. ប្រសិនបើអ្នកបានដឹង តើអ្នកដឹងអ្វីខ្លះអំពីសេចក្តីណែនាំនេះ ? ( សូមមេត្តារៀបរាប់ ) |
|---|
| |

| ៥៦. តើអ្នកស្គាល់អំពីអង្គភាពប្រឆាំងអំពើពុករលួយដែលមាននៅក្នុងប្រទេសកម្ពុជាដែរ ឬទេ ? | |
|---|---|
| ស្គាល់ | |
| មិនស្គាល់ | |
| ៥៧. ប្រសិនបើអ្នកស្គាល់ តើអ្នកបានស្គាល់មកពីណាដែរ អំពីអង្គភាពប្រឆាំងអំពើពុករលួយ ? | |
| | |

| ៥៨. តើអ្នកធ្វើចំណាត់ថ្នាក់យ៉ាងណា ចំពោះលទ្ធផលការងារ ដែលអង្គភាពប្រឆាំងអំពើពុករលួយកំពុងតែបំពេញដើម្បីកំចាត់អំពើពុករលួយ? |
|---|
| |

## ឆ. មតិយោបល់ និង អនុសាសន៍

| ៥៩. តាមមតិអ្នក តើអ្នកគិតថា អង្គភាពប្រឆាំងអំពើពុករលួយគួរតែធ្វើអ្វីបន្ថែមទៀត ដើម្បីលុបបំបាត់អំពើពុករលួយ? |
|---|
| |

| ៦០.តើអ្នកធ្វើចំណាត់ថ្នាក់យ៉ាងណាចំពោះការពេញចិត្តរបស់អ្នកជាមួយនឹងសកម្មភាពនានារបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាអំពើពុករលួយ?<br>(១ សម្រាប់កំរិតពេញចិត្តទាបបំផុត និង៥សម្រាប់កំរិតពេញចិត្តខ្ពស់បំផុត) |
|---|
| |

| ៦១. តើអ្នកដឹងអំពីសកម្មភាព និង គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយអំពើពុករលួយនៅក្នុងវិស័យឯកជនដែរឬទេ? ប្រសិនបើដឹង តើអ្នកដឹងអំពីអ្វីខ្លះ? |
|---|
| |

| ៦២. យោងតាមគំនិតរបស់អ្នក តើរដ្ឋាភិបាលគួរធ្វើអ្វីដើម្បីធ្វើឲ្យច្បាប់ប្រឆាំងអំពើពុករលួយកាន់តែមានប្រសិទ្ធិភាព បន្ថែមទៀត និងដើម្បីប្រឆាំងអំពើពុករលួយ? |
|---|
| |

| ៦៣.តើអ្នកបានឃើញការផ្លាស់ប្តូរវិជ្ជមាននៅក្នុងបរិយាកាសអាជីវកម្មដែរឬទេ តាំងពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយមក? | |
|---|---|
| បានឃើញការផ្លាស់ប្តូរ (យ៉ាងដូចម្តេចដែរ?) | |
| មិនបានឃើញមានការផ្លាស់ប្តូរទេ (ហេតុអ្វី) | |
| ប្រសិនបើបានឃើញការផ្លាស់ប្តូរ តើយ៉ាងដូចម្តេចដែរ?<br>ហើយប្រសិនមិនបានឃើញការផ្លាស់ប្តូរទេ ហេតុអ្វី? | |
| | |

| ៦៤. តើអ្នកគិតថា សហគ្រាសធុនតូច និងមធ្យម ដឹងពីវិធានការដែលរដ្ឋាភិបាលបានអនុម័ត ដើម្បីប្រឆាំងអំពើពុករលួយដែរឬទេ? ហេតុអ្វី? | |
|---|---|
| ដឹង | |
| មិនដឹងទេ | |

| ៦៥. តើអ្នកគិតថា រដ្ឋាភិបាលគួរតែធ្វើអ្វី ដើម្បីលុបបំបាត់អំពើពុករលួយ? |
|---|
| |

| ៦៦. ផ្អែកតាមទស្សនៈអ្នក តើអ្វីទៅជាហេតុផលសម្រាប់ការចំណាយក្រៅផ្លូវការនៅក្នុងវិស័យឯកជន នៅក្នុងប្រទេសកម្ពុជា? (សូមឆ្លើយដោយដាក់ចំណាត់ថ្នាក់ពីលេខ១ ដល់លេខ៥ តាមកម្រិតអាទិភាពនៃការប៉ះពាល់) | |
|---|---|
| ក). ប្រាក់ខែទាបរបស់និយោជិត | |
| ខ). វប្បធម៌នៃអំពើពុករលួយ | |
| គ). ការអនុវត្តច្បាប់នៅទន់ខ្សោយ | |
| ឃ).កង្វះឯករាជ្យភាព និង ប្រសិទ្ធិភាពនៃប្រពន្ធ័យុត្តាធិការ | |
| ង). កង្វះការគ្រប់គ្រង និង គណនេយ្យភាពរបស់សហគ្រាស | |
| ច). កង្វះប្រព័ន្ធកត់ត្រាឯកសារមានប្រសិទ្ធិភាព | |
| ឆ). កង្វះក្រមសីលធម៌ | |

| ៦៧. តើអ្នកគិតថាអ្វីជាមធ្យោបាយដ៏ល្អបំផុត ដើម្បីកាត់បន្ថយអំពើពុករលួយ នៅក្នុងវិស័យឯកជន នៃប្រទេសកម្ពុជា? |
|---|
| |

| ៦៨. តើអ្នកគិតថា សហគ្រាសដូចក្រុមហ៊ុនអ្នកអាចធ្វើអ្វីបានដើម្បីប្រឆាំងអំពើពុករលួយ? |
|---|
| |

| ៦៩. តើនរណា ឬ អង្គភាពណាមួយ ដែលអាចជួយអ្នកនៅក្នុងការកាត់បន្ថយការអនុវត្តអំពើពុករលួយ? |
|---|
| |

| ៧០.តើអ្នកមានមតិយោបល់ ឬអនុសាសន៍អ្វីខ្លះ លើវិធីសាស្ត្រជៀសវាងការអនុវត្តអំពើពុករលួយ ជូនដល់ សហគ្រាសធុនតូច និងមធ្យម? |
|---|
| |

| ៧១. តើអ្នកដឹងអំពីលេខទូរស័ព្ទបន្ទាន់សម្រាប់ទំនាក់ទំនងក្នុងករណីមានអំពើពុករលួយដែរឬទេ? | |
|---|---|
| ដឹង | |
| មិនដឹង | |

| ៧២. តើអ្នកនឹងទូរស័ព្ទទៅលេខនេះដែរឬទេ ប្រសិនបើអ្នកជួបប្រទះបញ្ហាអំពើពុករលួយ? | |
|---|---|
| ទូរស័ព្ទ | |
| មិនទូរស័ព្ទទេ | |

| ៧៣. តើអ្នកនឹងប្តឹងទៅអង្គភាពនេះទេ ប្រសិនបើក្រុមហ៊ុនរបស់អ្នកជួបប្រទះបញ្ហាអំពើពុករលួយ? | |
|---|---|
| ប្តឹង | |
| មិនប្តឹងទេ | |

| ៧៤. តើអ្នកនឹងប្តឹងទៅប្រព័ន្ធតុលាការដែរឬទេ ប្រសិនបើក្រុមហ៊ុនរបស់អ្នកជួបប្រទះបញ្ហាអំពើពុករលួយ? | |
|---|---|
| ប្តឹង | |
| មិនប្តឹងទេ | |

| ៧៥. យោងតាមទស្សនៈរបស់អ្នក តើដំណោះស្រាយនិងសកម្មភាពខាងក្រោមនេះ មានប្រសិទ្ធិភាពកំរិតណា សម្រាប់ប្រឆាំងអំពើពុករលួយ នៅក្នុងវិស័យឯកជននៅក្នុងប្រទេសកម្ពុជា? (សូមឆ្លើយដោយដាក់ចំណាត់ថ្នាក់ ពីលេខ១កំរិតប្រសិទ្ធភាពទាបដល់លេខ៥កម្រិតប្រសិទ្ធិភាពខ្ពស់) | |
|---|---|
| ក). ការតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ | |
| ខ). ការបង់ប្រាក់បៀវត្សន៍ និងការតម្លើងតួនាទី ដោយផ្អែកលើស្នាដៃរបស់មន្ត្រីរាជការ | |
| គ). ការបង្កើតអាជ្ញាធរឯករាជ្យដើម្បីប្រឆាំងអំពើពុករលួយ | |

| | |
|---|---|
| ឃ). ការបង្កើតប្រព័ន្ធឬបណ្តាញរាយការណ៍អំពើពុករលួយ | |
| ង). ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីរាជការ | |
| ច). សេវាច្រកចេញចូលតែមួយសម្រាប់អាជីវកម្ម | |
| ឆ).សមាគមអាជីវកម្មដ៏សកម្មជាច្រើនដែលអាចចរចាជាមួយរដ្ឋាភិបាល | |

# កម្រងសំណួរសម្រាប់សភាពាណិជ្ជកម្មនិងសមាគម

## ក.សំណួរសម្រាប់សភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម

| ១. សូមប្រាប់យើងអំពីអង្គការរបស់លោកអ្នក | |
|---|---|
| ក. តើអង្គការនេះ ត្រូវបានបង្កើតឡើងនៅពេលណា ? | |
| ខ. តើអង្គការលោកអ្នក មានសមាជិកចំនួនប៉ុន្មាន ? | |
| គ. តើលោកអ្នកមានតួនាទីជាអ្វី? តើលោកអ្នកផ្តល់នូវសេវាអ្វីខ្លះ ដល់សមាជិករបស់លោកអ្នក ? | |

| ២. តើលោកអ្នកមានយោបល់អ្វីខ្លះ អំពីបរិយាកាសអាជីវកម្មនៅក្នុងប្រទេសកម្ពុជា ? |
|---|
| |

| ៣. តើអ្វីជាបញ្ហាប្រឈមសម្រាប់សមាគមរបស់លោកអ្នក ? |
|---|
| |

| ៤. តើបញ្ហាប្រឈមអ្វីខ្លះដែលសមាជិករបស់លោកអ្នកជួបប្រទះនៅក្នុងការធ្វើអាជីវកម្មរបស់ពួកគេ ? |
|---|
| |

| ៥. តើសមាជិករបស់លោកអ្នក ធ្វើការពិភាក្សាជាមួយលោកអ្នក អំពីបញ្ហាប្រឈមរបស់ពួកគេដែរឬទេ ? |
|---|
| |

| ៦. តើលោកអ្នកបានធ្វើការពិភាក្សាអំពីការចំណាយដោយប្រយោលនិងរបៀបដើម្បីកាត់បន្ថយការចំណាយ ដោយប្រយោលនេះជាមួយសមាជិករបស់ដែរ ឬទេ ? |
|---|
| |

| ៧. តើករណីណាខ្លះដែលមានលក្ខណៈលេចធ្លោ ចំពោះការចំណាយដោយប្រយោលនេះ ? |
|---|

| ៨. តើអ្វីទៅជាវិធានការដែលត្រូវបានអនុវត្តដោយសមាគមរបស់លោកអ្នកដើម្បីប្រយុទ្ធប្រឆាំងនឹង អំពើពុករលួយ? តើមានការណែនាំអ្វីខ្លះ? ឬក្រមសីលធម៌ឬទេ? |
|---|
| |

| ៩. តើលោកអ្នកធ្លាប់បានឃើញភាពខុសគ្នាអំពីការគ្រប់គ្រងនូវការចំណាយដោយប្រយោលរបស់ សមាជិករបស់លោកអ្នក ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែរ ឬទេ? |
|---|
| |

| ១០. ហេតុអ្វីបានជាលោកអ្នកគិតថា សមាជិករបស់លោកអ្នកបានធ្វើការបង់តម្លៃសេវាដោយប្រយោល? |
|---|
| |

| ១១. តើសមាជិករបស់លោកអ្នកធ្វើយ៉ាងដូចម្តេចដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ? |
|---|
| |

| ១២. តើលោកអ្នកធ្លាប់មានការពិភាក្សាណាមួយអំពីវិធានការដែលបានអនុវត្តដោយរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដែរ ឬទេ? |
|---|
| |

| ១៣. តើលោកអ្នកគិតដូចម្តេចចំពោះអង្គភាពប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីអំពីការប្រឆាំងអំពើពុក រលួយ? តើលោកអ្នកគិតថាវានឹងអាចជួយចំពោះការប្រឆាំអំពើពុករលួយដែរ ឬទេ? |
|---|
| |

## ខ.សំណួរសម្រាប់សភាពាណិជ្ជកម្ម "អន្តរជាតិ

| ១. តើមានការលើកទឹកចិត្តណាមួយសម្រាប់អោយពាណិជ្ជកម្មអន្តរជាតិចូលមកកាន់ប្រទេសកម្ពុជា ដែរ ឬទេ? |
|---|
| |

| ២. ហេតុអ្វីបានជាលោកអ្នកគិតថា ក្រុមហ៊ុនអន្តរជាតិចង់មកធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា? |
| --- |
| |

| ៣. តើលោកអ្នកបានឃើញអំពីការកើនឡើងនៃពាណិជ្ជកម្មអន្តរជាតិ ដែលចូលមកកាន់ប្រទេសកម្ពុជា នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំដែលកន្លងទៅនេះ ដែរ ឬទេ? |
| --- |
| |

| ៤. តើលោកអ្នកគិតថាមានភាពងាយស្រួលជាងមុនសម្រាប់ពាណិជ្ជកម្មអន្តរជាតិក្នុងការចូលមកកាន់ប្រទេសកម្ពុជាដែរ ឬទេ?<br>(ជាមួយនឹងទម្រង់បែបបទអេឡិចត្រូនិច និងសេវាកម្មច្រកចេញចូលតែមួយ។ល។) |
| --- |
| |

| ៥. តើលោកអ្នកដឹងថា ក្រុមហ៊ុនបានធ្វើការបង់ចំពោះការចំណាយដោយប្រយោលចំនួនប៉ុន្មានភាគរយ ប្រសិនបើធ្វើការប្រៀបធៀបទៅនឹងប្រាក់ចំណេញប្រចាំឆ្នាំរបស់ពួកគេ? |
| --- |
| |

| ៦. តើសមាជិករបស់លោកអ្នកភាគច្រើន បានធ្វើការប្រឹក្សាយោបល់ជាមួយ មេធាវី ឬ អ្នកប្រឹក្សាយោបល់ ក្នុងការបើកអាជីវកម្ម នៅក្នុងប្រទេសកម្ពុជាដែរ ឬទេ? |
| --- |
| |

| ៧ តើលោកអ្នកគិតថា អ្វីជាវិធានការដែលត្រូវយកមកអនុវត្ត ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ? |
| --- |
| |

| ៨. នៅពេលដែលមានក្រុមហ៊ុនមួយ ដែលមានចំណាប់អារម្មណ៍មកប្រទេសកម្ពុជា ហើយពួកគេបានសាកសួរលោកអ្នកអំពីការអនុវត្តទាក់ទងនឹងអំពើពុករលួយ តើលោកអ្នកផ្តល់នូវចម្លើយយ៉ាងដូចម្តេចដែរ? |
| --- |
| |

# បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាភិបាលប្រឹក្សាយោបល់

| | **ឈ្មោះ** | **មុខងារ**<br>**អង្គការ** |
|---|---|---|
| ១ | លោកស្រី ហួសឆ្សឹរ គ្រីស្ទីន | ក្រុមប្រឹក្សាភិបាល<br>សមាគមសហគ្រិនស្ត្រីកម្ពុជា |
| ២ | លោក ហុក វិចិត្រា | មន្ត្រីប្រតិបត្តិការិយាល័យ<br>សមាគមសហគ្រិនវ័យក្មេងកម្ពុជា |
| ៣ | លោក លឹម សុកលី | អ្នកជំនាញផ្នែកត្រួតពិនិត្យ និងវាយតម្លៃ/គ្រូបង្រៀន |
| ៤ | លោក លី វិសាល | ប្រធានប្រតិបត្តិ<br>សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា |
| ៥ | លោក សៀង សុន្ទរា | សមាជិក (ប្រធានផ្នែកទីផ្សារ និងនាំចេញ)<br>សមាគមសិប្បករកម្ពុជា |

អង្គការតម្លាភាពកម្ពុជា
ផ្ទះលេខ ៩បេ ផ្លូវលេខ ៤៦៦ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ១២៣០១ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ (+៨៥៥) ២៣ ២១ ៤៤ ៣០ / ២៣ ២១ ៤២ ១១

info@ticambodia.org
www.ticambodia.org
www.facebook.com/ticambodia
www.twitter.com/ticambodia
www.youtube/ticambodia.com